អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 19-Oct-2012, 15:14

CMS/CFO: Uch Arun

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី១១៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល *(Mr. Vincent de wilde d'ESTMAEL)*

លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉ែន ពៅ

លោក ឡេ្វ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយដូចអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយ កាលពីចុងសប្តាហ៍មុនថា នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់នូវការដាក់ឯកសាររបស់តំណាងសហព្រះរាជអាជ្ញាពាក់ព័ន្ធជាមួយនឹងអង្គហេតុ នៃរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ ហើយទំនងជាអាចចប់នៅព្រឹកនេះហើយតាមមើលតំណាងសហព្រះរាជអាជ្ញា។

ដូច្នេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់ឯកសារ។

**លោក សុន អរុណ៖**

លោកប្រធាន។ ក្នុងនាមជនជាប់ចោទ នួន ជា ខ្ញុំបាទសូមធ្វើសេចក្តីថ្លែងការណ៍អំពីមរណភាពព្រះមហាក្សត្រ -- វរព្រះមហាក្សត្រ។ ពេលខ្លី ប្រហែលជាប្អូនដប់បន្ទាត់បានទេ អនុញ្ញាត។

[០៩:០៣:២៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៤:១៦]

**ប្រធានអង្គជំនុំ៖**

បាទ នេះ មិនមែនជាពេលវេលាសមស្របសម្រាប់ឲ្យ -- អនុញ្ញាតឲ្យបុគ្គលណាមួយ ធ្វើកិច្ចការនេះ នៅក្នុងកិច្ចដំណើរការសវនាការនេះទេ។ អង្គជំនុំជម្រះមិនអនុញ្ញាតទេណា៎!

សូមអញ្ជើញលោកមានបញ្ហាអីទៅ!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបលោក លោកស្រីចៅក្រម។ ខ្ញុំសង្ឃឹមថា ឃើញថាបានសម្រាក ហើយទាក់ទងនឹងបញ្ហានេះ ខ្ញុំចង់ជម្រាបតុលាការពីការរៀបចំ បឋមខ្ញុំសូមជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគីថា ប្រហែលថ្ងៃស្អែកបន្ថែមទៅលើឯកសារ ដែលខ្ញុំបានយោងនៅក្នុងអ៊ីម៉ែល

ទៅមន្ត្រីច្បាប់ជាន់ខ្ពស់នោះ គឺថា អាចនឹងពិភាក្សា E3/1568, E3/781, E3/488 ហើយនេះជាឯកសារបន្ថែមទៅលើឯកសារដែលខ្ញុំបានបញ្ជាក់ខាងដើម។

ចំណុចទី២ គឺសំណើសុំឲ្យមានការបំភ្លឺទាក់ទងទៅនឹងសវនាការនៅក្នុងដំណើរការនីតិវិធីនេះ យើងពិនិត្យឃើញថា វាទាក់ទងថាតើៗលោក នួន ជា ខ្លួនឯងត្រូវធ្វើសេចក្តីបញ្ជាក់លើឯកសារ។ ដូច្នេះអាស្រ័យទៅលើការសម្រេចរបស់អង្គជំនុំជម្រះ ថាតើឲ្យគាត់ អនុញ្ញាតជូនគាត់ ឬក៏មិនអនុញ្ញាត។ សំណួររបស់ខ្ញុំនោះ ខ្ញុំលើកឡើងជាថ្មីម្តងទៀត បន្ថែមទៅលើអ្វីដែលខ្ញុំសរសេរជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់នោះ គឺថាខ្ញុំមិនទាន់បានទទួលចម្លើយទេ។ ខ្ញុំចង់ឲ្យតុលាការកត់ត្រា បើសិនជាអង្គជំនុំជម្រះអាចប្រាប់ខ្ញុំ ដើម្បីណែនាំឲ្យខ្ញុំ ដើម្បីជួយឲ្យខ្ញុំ ហើយនិងក្រុមការងាររបស់ខ្ញុំ ដើម្បីពិភាក្សា ថាកូនក្តីរបស់ខ្ញុំ ថាដើម្បីជាអត្ថប្រយោជន៍របស់គាត់ ឲ្យគាត់បញ្ជាក់យោបល់លើឯកសារហ្នឹង។

[០៩:០៦:៣៨]

ហើយប្រសិនបើយើងត្រូវថ្លឹងថ្លែង ឬក៏ឲ្យតម្លៃទៅលើមតិរបស់ជនជាប់ចោទ លើឯកសារដែលលើកឡើងនេះគឺថា នៅក្នុងសវនាការលើឯកសារនេះ តាមមតិរបស់លោកស្រីចៅក្រម ខាតវ៉ាយថ៍ ពីខាងដើមហ្នឹង គឺនឹងការណែនាំពីជនជាប់ចោទ មិនត្រូវឲ្យតម្លៃខ្ពស់ទេ លើកលែងតែជនជាប់ចោទមិនបានប្រើសិទ្ធិមិនឆ្លើយតប លើកលែងតែគាត់ឆ្លើយនូវសំណួរមួយចំនួន។ នេះជាមតិរបស់លោក ស្រីចៅក្រម ខាតវ៉ាយថ៍ នៅថ្ងៃទី០៩ តុលា ឆ្នាំ២០១២ ជាប្រតិចារឹក។ នេះជាវិធីសាស្ត្រមួយ គឺជាការសម្រេចដែលថា មិនឲ្យតម្លៃទៅលើឯកសារ បើសិនជាមតិរបស់ជនជាប់ចោទនោះ នៅពេលដែលជនជាប់ចោទមិនដាក់សំណើ ឬក៏មិនឆ្លើយទៅនឹងសំណួរនោះទេ។

ហើយផ្អែកលើសំណើរបស់ខ្ញុំហ្នឹងគឺ អាចនឹងមានប្រយោជន៍ដែលខ្ញុំថា បើសិនជាអង្គជំនុំជម្រះអាចបំភ្លឺដល់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំអាចពិភាក្សាជាមួយកូនក្តីរបស់ខ្ញុំ ថាតើតុលាការឲ្យតម្លៃទៅលើអ្វីទៅលើមតិយោបល់របស់ជនជាប់ចោទ ដែលផ្អែកទៅលើការស្តាប់សវនាការលើឯកសារនេះ។ ហើយទាក់ទងទៅនឹងអ្វីដែលថាគាត់ប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ។ ហើយខ្ញុំក៏សូមសម្តែងមរណទុក្ខផងដែរ ចំពោះការចូលទិវង្គតរបស់ព្រះអតីតព្រះមហាក្សត្រនោះនរោត្តម សីហនុ។

ចំណុចចុងក្រោយមួយទៀត ខ្ញុំកត់សម្គាល់ឃើញនៅក្នុងៗកាសែត *អ៊ីនធឺណាស្សូណាល ហឺរ៉ល ត្រាយប៊្យូន* (International Herald Tribune) ចុះម្សិលមិញនោះ ខ្ញុំឃើញថា យើងឃើញថា ប៉ែរណា យិនុក គឺជា -- ដូចដែលយើងដឹងហើយគឺថា--

[០៩:០៨:៥១]

**ប្រធានអង្គជំនុំ៖**

លោកលើកឡើងហ្នឹង ទី១ លោកបានចងចាំទេថា យើងបានជម្រាបលោកហើយថា លោកត្រូវកំណត់នូវប្រធានបទជាមុន មុននឹងលោកនិយាយ ដើម្បីយើងអនុញ្ញាតឲ្យលោកនិយាយ ឬក៏មិនអនុញ្ញាត។ យើងអំមិញ យើងគិតថា លោកចងចាំនូវអ្វីដែលយើងបានកំណត់នូវរបៀបនៃដំណើរការនៅក្នុងដំណើរការសវនាការនេះហើយ ទើបយើងមិនរំឭកលោកសាជាថ្មីម្តងទៀត។ ទំនងជា ទៅថ្ងៃមុខប្រហែលជាយើងរំឭកលោកជានិច្ចកាលតែម្តងហើយតាមមើល។

ទី២ ឯកសារចុងក្រោយដែលលោក -- បញ្ហាចុងក្រោយ ដែលលោកចង់មានបំណងលើកឡើងហ្នឹង តើវាមានការពាក់ព័ន្ធជាមួយនឹងដំណើរការនៃសំណុំរឿង០០២/០១ ដែលអង្គជំនុំជម្រះកំពុងតែកំណត់យកមកធ្វើសវនាការនេះយ៉ាងដូចម្តេច?

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំសូមអភ័យទោស ដែលថាខ្ញុំមិនសូវបានច្បាស់ គឺថាវាពាក់ព័ន្ធទៅនឹងសវនាការនេះ។ ហើយទាក់ទងគឺជាអត្ថបទសារព័ត៌មាននៅក្នុងកាសែត ត្រាយប៊្យូន *(Tribune)* នោះគឺថាដែលទាក់ទងទៅនឹង -- ដ៏ជាក់លាក់នោះ--

**ប្រធានអង្គជំនុំ៖**

ទី១ ខាងចៅក្រមបានអានរួចហើយមិនមានការទាក់ទង និងមិនមានការពាក់ព័ន្ធទៅនឹងសំណុំរឿងដែលអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការទេ។ ទី២ ប្រសិនបើលោកយល់ឃើញថា វាពាក់ព័ន្ធចាត់ទុកថាជា ឯកសារភស្តុតាងថ្មី លោកអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះតម្រូវឲ្យលោកដាក់ឯក -- ស្នើសុំដាក់ឯកសារជាលាយលក្ខណ៍អក្សរឲ្យបានមុនពីរសប្តាហ៍ ប្រសិនបើឯកសារនោះត្រូវដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះ។ នេះជាសេចក្តីណែនាំរួចហើយ មិនគួរធ្វើអ្វីដែលវាខុសម្តងហើយម្តងទៀត ទៅនឹងការណែនាំរបស់អង្គជំនុំជម្រះនោះឡើយ។

សូមអញ្ជើញ!

[០៩:១១:៥០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់

ជម្រាបសួរសាធារណជន។ កាលពីសប្តាហ៍មុនយើងបានចាប់ផ្តើមសវនាការ ហើយខ្ញុំនៅសល់ឯកសារមួយចំនួនទៀត ដែលត្រូវបង្ហាញពាក់ព័ន្ធទៅនឹងក្រសួងមួយចំនួន។ មុនពេលនេះ ខ្ញុំសូមស្នើសុំអង្គជំនុំជម្រះឲ្យមេត្តាមានភាពបត់បែនបន្តិចដោយសារតែកាលពេលមុននោះ យើងបានចាប់ផ្តើមពីម៉ោង ៩៣៥ (ស៊ីក) ទៅហើយ បន្ទាប់ពីមានការថ្លែងរបស់លោក នួន ជា។ ដូច្នេះខ្ញុំមិនប្រាកដថាអាចបញ្ចប់នៅព្រឹកនេះនោះទេ។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះនៅបន្តដល់ រហូតដល់រសៀលនេះទៀត។ ដូច្នេះ តាមពិតទៅយើងមានរយៈពេល១ថ្ងៃដើម្បីបង្ហាញឯកសារ ដោយសារតែយើងចាប់ផ្តើមយឺតពេលបន្តិចនោះ ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាផ្តល់ពេលបន្ថែមបន្តិចទៀតនៅរយៈ -- នៅពេលរសៀលនេះ។ ប៉ុន្តែយើងនៅតែគោរពតាមពេលវេលាដែលបានផ្តល់ជូន។

កាលពីសប្តាហ៍មុននោះ យើងបានផ្អាកសវនាការនៅពេលដែលខ្ញុំបង្ហាញឯកសារមួយចំនួនពាក់ព័ន្ធទៅនឹងក្រសួងពាណិជ្ជកម្ម។ ក្នុងចំណោមឯកសារទាំងអស់នោះមានរបាយការណ៍ ២៨ នៃកិច្ចប្រជុំពាណិជ្ជកម្មដែលបានធ្វើឡើងរវាងគណៈកម្មាធិការពាណិជ្ជកម្ម ជាមួយនឹងគណៈប្រតិភូកូរ៉េខាងជើង ចិន និងយូហ្គោស្លាវី។

[០៩:១៣:២៨]

របាយការណ៍ ២៨នេះ គឺ ធ្វើដោយគណៈកម្មាធិការពាណិជ្ជកម្មធ្វើជូន បងហែម ដែលជាលោក ខៀវ សំផន។ ខ្ញុំសូមដកស្រង់ទៅនឹង ឧទាហរណ៍ពាក់ព័ន្ធទៅនឹងឯកសារទាំងនេះ។ ឧទាហរណ៍ដូចជាឯកសារ D366/7.1.351 ឯកសារនេះគឺជារបាយការណ៍ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៨ ធ្វើដោយគណៈកម្មាធិការពាណិជ្ជកម្មជូន បងហែម ជាទីគោរពនិងស្នេហា ដែលពាក់ព័ន្ធទៅនឹងកិច្ចប្រជុំជាមួយនឹងគណៈប្រតិភូពាណិជ្ជកម្មចិន។ ឯកសារនេះធ្វើជូន បងហែម ហើយចម្លងជូន បងវន, ក-៥១ និងឯកសារ។ ខាងភាគីកម្ពុជាមានសមមិត្ត វិត, សួ, សី និង ឆេង បានចូលរួមនៅក្នុងកិច្ចប្រជុំនោះ។

ខ្ញុំគ្រាន់តែចង់អានសម្រង់ពីរនៃឯកសារនេះ។ សម្រង់ទី១ គឺនៅទំព័រជាភាសាខ្មែរ ERN 00188509 គឺទំព័រទី១, ជាភាសាបារាំងក៏ទំព័រទី១ ដែរ គឺលេខ ERN 00548785, ERN ជាភាសាអង់គ្លេស 00574555។

[០៩:១៥:០៥]

នេះជាសម្តីរបស់ប្រធានគណៈប្រតិភូពាណិជ្ជកម្មចិន។ ខ្ញុំសូមដកស្រង់ លេខ២ "សូមជូនដំណឹងកប៉ាល់ ហុងឈី នឹងមកដល់កំពង់ផែកំពង់សោម ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៨ នេះ ដឹកសម្ភារៈយោធា

ស្នើមិត្តកម្ពុជាត្រៀមទទួលផង"។ សុន សេន ដែលជារដ្ឋមន្ត្រីក្រសួងការពារ ជាតិមិនមែនជាអ្នកទទួលរបាយការណ៍នេះតែម្នាក់ឯងនោះទេ គឺប្រាកដណាស់ថា មានអ្នកទទួលផ្សេងទៀតបានដឹងអំពីការមកដល់នៃសម្ភារៈយោធានេះ។ ឯកសារនេះបង្ហាញយ៉ាងច្បាស់ថា មានការទំនាក់ទំនងគ្នារវាងអ្នកទទួលរបាយការណ៍នេះ និងក្រសួងការពារជាតិ។

សម្រង់ទី២ ដែលមានខ្លឹមសារខ្លីទេ ដែលមាននៅទំព័រ២ ជាភាសាខ្មែរគឺ ERN 00188510, ទំព័រ២ ជាភាសាបារាំងផងដែរគឺ ERN 00548786, ជាភាសាអង់គ្លេស ERN 00574558។ ពាក់ព័ន្ធទៅនឹងចំណុចផ្សេងៗ ដែលពិភាក្សាដោយប្រធានគណៈប្រតិភូចិន ភាគីកម្ពុជាបានបញ្ជាក់ថា ខ្លួននឹងស្នើយោបល់ពីរដ្ឋាភិបាល ហើយនិងបញ្ជូនរបាយការណ៍ដោយឃ្លាមួយ ផ្ញើជូន បងហែម "សូមបងជ្រាបជាព័ត៌មាន និងមានមតិណែនាំ" សូមបញ្ចប់ការដកស្រង់។

ដូច្នេះ យើងឃើញថា គណៈប្រតិភូនៃគណៈកម្មាធិការពាណិជ្ជកម្ម ដែលដឹកនាំដោយ វ៉ាន់ រិត នោះ គឺស្នើសុំមតិណែនាំពី បងហែម ពាក់ព័ន្ធទៅនឹងបញ្ហាពាណិជ្ជកម្ម។

[០៩:១៧:១០]

ឥឡូវនោះខ្ញុំចូលទៅឯកសារផ្សេងទៀតរបស់ក្រសួងពាណិជ្ជកម្ម ដែលពាក់ព័ន្ធទៅនឹងស្បៀងអាហារ។ នៅក្នុងសំណុំរឿងមានឯកសារជាច្រើនរបស់ក្រសួងពាណិជ្ជកម្ម ពាក់ព័ន្ធទៅនឹងការប្រមូលស្បៀងអាហារ ហើយការបែងចែកស្បៀងនៅក្នុងប្រទេស ឬក៏ការដឹក -- ការនាំចេញ។ ហើយខ្ញុំសូមលើកឡើងនូវឯកសារពីរជាឧទាហរណ៍។

ឯកសារដំបូងនោះ គឺឯកសារលេខ D366/7.1.487។ ឯកសារនេះគឺជារបាយការណ៍អំពីស្រូវអង្ករប្រចាំសប្តាហ៍ចុះពីថ្ងៃទី០១ ខែ៣ ឆ្នាំ១៩៧៧ ហើយមានចំណារ ដែលមានចារថា "ផ្ញើជូនបងហែមមួយច្បាប់ក្នុងថ្ងៃនេះ ថ្ងៃទី១០ ខែមីនា"។ ខ្ញុំគិតថាយើងបង្ហាញឯកសារនេះ ឯកសារនេះបង្ហាញអំពីតារាងនៃបរិមាណស្រូវអង្ករ ដែលមកពីតំបន់ ភូមិភាគផ្សេងៗ ហើយនិងបង្ហាញថា តើស្រូវអង្ករទាំងនេះត្រូវបានបែងចែកឡើងវិញ ឬក៏រក្សាទុកដូចម្តេចខ្លះ?

ឯកសារនេះបង្ហាញអំពីមុខងារសម្របសម្រួលរបស់ក្រសួងពាណិជ្ជកម្ម ឬក៏ប្រធាននៃក្រសួងនេះពាក់ព័ន្ធទៅនឹងការផលិត ការដឹក ការស្តុក និងបែងចែកនៃស្បៀងអាហារទាំងអស់នេះ។

[០៩:១៨:៥២]

ឯកសារទី២របស់ក្រសួងពាណិជ្ជកម្មដែរ គឺឯកសារពាក់ព័ន្ធទៅនឹងស្បៀងអាហារ គឺIS18.68។

ឯកសារនេះចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ដែលមានចំណងជើងថា “ស្ថិតិនាំចេញនាំចូលឆ្នាំ១៩៧៨ ពីខែមករា ដល់ខែកញ្ញា”។ នៅទំព័រ២ ជាភាសាបារាំង គឺមានចំណារដែលសរសេរថា ខ្ញុំសូមដកស្រង់ “ផ្ញើជូន បងហែម ហើយ” សូមបញ្ចប់ការដកស្រង់។

ឯកសារនេះបង្ហាញ ជាពិសេសនៅក្នុងតារាងទី២ នូវបញ្ជីនៃសម្ភារៈដែលបាននាំចេញដោយកម្ពុជាប្រជាធិបតេយ្យ នៅឆ្នាំ១៩៧៨ ដែលនៅក្នុងនោះមាន ស្រូវ អង្ករ ល្ង កាហ្វេ ម្រេច សណ្ដែកសៀង សណ្ដែកបាយ សណ្ដែកដី ឈើ ហើយនិង គ ឬក៏កៅស៊ូ។ ហើយយើងឃើញនៅក្នុងតារាងចុងក្រោយនេះ យើងដឹងថាតើក្រសួង គណៈកម្មាធិការ ភូមិភាគ ឬសេនាធិការ មន្ទីររបស់អង្គការនោះថាបាននាំចូលស្បៀងសម្រាប់ពេលនោះ។ ហើយយើងគិតថា តារាងទាំងអស់នោះបង្ហាញអំពីតួនាទីនៃសម្របសម្រួលរបស់ក្រសួងពាណិជ្ជកម្មរបស់អង្គភាពមួយចំនួនរបស់កម្ពុជាប្រជាធិបតេយ្យ ហើយជាពិសេសគឺពាក់ព័ន្ធទៅនឹងការបញ្ជាទិញសម្ភារៈដែលត្រូវនាំចូល ហើយនិងសម្ភារៈសម្រាប់នាំចេញ។

[០៩:២០:៣៣]

ឯកសារផ្សេងទៀតរបស់ក្រសួងពាណិជ្ជកម្ម គឺឯកសារពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណ និងការកម្ទេចខ្មាំង និងឯកសារដ៏សំខាន់មួយរបស់ក្រសួងពាណិជ្ជកម្ម គឺឯកសារ E3/1159។ ឯកសារនេះគឺជាសេចក្ដីរាយការណ៍របស់សន្និបាតក្រសួងថ្ងៃ២៥ ដល់ថ្ងៃ២៦ ខែកក្កដា ឆ្នាំ១៩៧៦។

ជាដំបូងនេះយើងកត់សម្គាល់ឃើញថា នៅក្នុងក្រសួងពាណិជ្ជកម្មមានការរៀបចំសន្និបាត ឬសមាជ ដូចជាអ្វីដែលយើងបានឃើញដែរនៅក្រសួងការបរទេស ហើយក៏បាន -- យើងនឹងឃើញថា -- ខ្ញុំកាលពីសប្ដាហ៍មុននោះ ខ្ញុំបានបង្ហាញអំពីឯកសាររបស់ក្រសួងការបរទេសមួយហើយ គឺឯកសារ E3/522។ មានចំណុចរួមជាច្រើនរវាងឯកសារ E3/1159 របស់ក្រសួងពាណិជ្ជកម្ម និងឯកសាររបស់ក្រសួងការបរទេសដែលមានលេខ E3/552 និងឯកសារមួយទៀត គឺឯកសារលេខ E3/808 របស់ក្រសួងសង្គមកិច្ច។

[០៩:២២:០០]

ក្នុងចំណោមចំណុចរួមរវាងឯកសារទាំងអស់នោះ យើងឃើញថា ស្ថានភាពខ្មាំងនោះគឺមានតួនាទីសំខាន់ណាស់នៅក្នុងការជជែកពិភាក្សាគ្នានៅក្នុងក្រសួងទាំងអស់នោះ។ ហើយចំណុចទាំងអស់នោះគឺថាស្របជាមួយនឹងប្រធានបទដែលសរសេរនៅក្នុងទស្សនាវដ្ដីទង់បដិវត្ត សារាចរណែនាំ និងបញ្ជារបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលសហការីរបស់ខ្ញុំបានបង្ហាញកាលពីសប្ដាហ៍មុនរួចមក

ហើយ។ សម្រង់ដំបូងនៃឯកសារ E3/1159 គឺយើងឃើញជាភាសាខ្មែរ គឺទំព័រទី១ ទំព័រទី២ ដែលមានលេខ ERN 00188204 ទៅដល់ 05, ជាភាសាបារាំងទំព័រទី១ ERN 00665460 ទៅដល់ 61, ជាភាសាអង់គ្លេស 00701587។ ខ្ញុំសូមអាននូវសេចក្តីដកស្រង់ " I.សភាពការណ៍ខ្មាំង, ១)សកម្មភាពនៃពួកសមាសភាពមិនល្អមួយចំនួនបានស្ងប់ស្ងាត់ ក្រោយពីយើងមានវិធានការចាត់តាំងខ្លះ និងវិធានការអប់រំពួកផ្សេងៗទៀត។ ក្រៅពីនេះមានបាតុភាពមួយចំនួនដូចតទៅ" ហើយនៅក្នុងនេះមានលើកឡើងអំពីករណីខុសសីលធម៌ ការបើកខូចខាត ការបើកបរខូចខាតសម្ភារៈ ការប៉ះពាល់ដល់អាយុជីវិតប្រជាជន ហើយនិង ខ្ញុំសូមដកស្រង់ "ការទាក់ទងបើកច្រកខាងពាយ័ព្យ ខ្មាំងមានផែនការចង់ចូលជ្រៀតជ្រែកតាមច្រកនេះ។ ខ្មាំងជាពួកអា អ៊ុន តាំ។ ចំណុចទី ២) វិធានការរបស់យើង, គុណសម្បត្តិ៖ បានអប់រំបំពាក់បំប៉នផ្ទៃក្នុងអំពីឧបាយកលខ្មាំង។ មានវិធានការមួយចំនួនចំពោះពួកសេរី កែមិនឡើង។ ពង្រឹងវិធានការយាមកាម ការពារបក្ស ការពារបដិវត្ត ការពារមហាជន និងសម្បត្តិរួម។ ការខ្វះខាតការអប់រំថែបំប៉នមិនទាន់ដល់កម្រិត យកចិត្តទុកដាក់តាមដានប្រវត្តិរូប និងសម្រិតសម្រាំងនៅមានការខ្វះខាត"។ សូមបញ្ចប់ការដកស្រង់។

ហើយយើងកត់សម្គាល់ឃើញថា ពាក្យ "របាយកលខ្មាំង", "ពួកកែមិនឡើង", "ការតាមដានប្រវត្តិរូប"...។ល។ គឺជាសុទ្ធសឹងតែជាពាក្យ ដែលយើងមានរកឃើញនៅក្នុងឯកសាររបស់ក្រសួងការបរទេស ប-១ ដែលយើងបាននិយាយកាលពីសប្តាហ៍មុននេះ។ ខ្ញុំសូមចូលទៅដល់ឯកសារមួយទៀត។

[០៩:២៥:៥៤]

ឯកសារអម្បាញ់មិញដែលខ្ញុំបានលើកឡើង គឺ E3/1159 នេះត្រូវបានបំពេញបន្ថែមឯកសារនៃសន្និបាតរបស់ក្រសួងពាណិជ្ជកម្ម។ ឯកសារនេះ គឺមានលេខ E3/153។ ខ្ញុំមិនរៀបរាប់លម្អិតអំពីឯកសារមួយនេះទេ។ ក៏ប៉ុន្តែនៅក្នុងឯកសារនេះ មានការអន្តរាគមន៍ទិតៀនរបស់កម្មាភិបាលមួយចំនួននៅក្នុងសន្និបាតថ្ងៃទី២៥-២៦ ខែកក្កដា ឆ្នាំ៧៦ ហើយបទអន្តរាគមន៍នេះ គឺបង្ហាញអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងវិស័យមួយចំនួន ជាពិសេសពាក់ព័ន្ធទៅនឹងការតស៊ូវណ្ណៈ សមូហភាពនិយម បដិវត្តន៍សង្គមនិយម ឬភាពចាំបាច់ក្នុងការអនុវត្តតាមអ្វីដែលមានចែងនៅក្នុងទស្សនាវដ្តីទង់បដិវត្ត។

[០៩:២៧:០៤]

ឯកសារពីររបស់ក្រសួងពាណិជ្ជកម្ម ដែលឯកសារទាំងពីរនេះចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦

គឺពាក់ព័ន្ធទៅនឹងអំណាច ឬសិទ្ធិរបស់ក្រសួងពាណិជ្ជកម្មក្នុងការចាប់ខ្លួន ឬក៏បញ្ជូនខ្មាំងទៅឲ្យសន្តិសុខ ជាពិសេសឯកសារនេះ ឆ្លុះបញ្ចាំងអំពីនយោបាយមជ្ឈិមបក្សពាក់ព័ន្ធទៅនឹងខ្មាំង។

ឯកសារដំបូងនោះ គឺឯកសារ E3/962 សូមអានម្តងទៀត E3/962។ ឯកសារនេះ គឺជាសេចក្តីសម្រេចរបស់គណៈកម្មាធិការក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦។ ខ្ញុំសូមដកស្រង់នូវផ្នែកដំបូងនៃឯកសារនេះ ដែលត្រឹមតែមួយ ឬក៏ពីរទំព័រតែប៉ុណ្ណោះ។ នៅទំព័រដំបូងនៃឯកសារនេះគឺខ្ញុំសូមដកស្រង់ "គណៈក្រសួងពាណិជ្ជកម្មក្រោយពីបានសួរមតិដល់ផ្នែកក្នុងក្រសួងសម្រេចចាប់បញ្ជូនទៅសន្តិសុខ នូវឈ្មោះដូចតទៅ ដើម្បីសួរចម្លើយយកព័ត៌មាន" សូមបញ្ចប់ការដកស្រង់។

អ្នកទាំងប្រាំមួយដែលត្រូវបានចាប់ខ្លួនដែលមានឈ្មោះនៅក្នុងឯកសារនេះ គឺសុទ្ធតែជាត្រូវបានគេចោទថា ជាឧក្រិដ្ឋជនដោយសារតែការដើរហើរសេរីគ្មានការអនុញ្ញាត ការតវ៉ាប្រឆាំងនឹងអង្គការ ការស្គាល់ ឬក៏ការស្ថិតនៅក្នុងខ្សែរយៈពួកអាក្បត់។

[០៩:២៨:៥២]

ឯកសារទី២ គឺផ្តល់ព័ត៌មានមួយចំនួនពាក់ព័ន្ធទៅនឹងអំណាចរបស់ក្រសួងពាណិជ្ជកម្ម ហើយនិងអំណាចរបស់ក្រសួងផ្សេងទៀតពាក់ព័ន្ធទៅនឹងខ្មាំង។ ឧទាហរណ៍ឯកសារ E3/174 ឯកសារនេះក៏ជាសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម នៅថ្ងៃដដែល គឺថ្ងៃ១៧ តុលា ឆ្នាំ៧៦ តែប៉ុន្តែពាក់ព័ន្ធនឹងបុគ្គលផ្សេងទៀត។ ខ្ញុំសូមអាននូវខ្លឹមសារដំបូងនៃឯកសារនេះ "គណៈក្រសួងពាណិជ្ជកម្មក្រោយពីសាកសួរមតិយោបល់គ្រប់ផ្នែក សម្រេចបញ្ជូនទៅមន្ទីរអប់រំរបស់សន្តិសុខ ដូចមានឈ្មោះខាងក្រោមនេះ"។ សូមបញ្ចប់ការដកស្រង់។

បុគ្គលដែលបានកំណត់នៅក្នុងឯកសារនេះ គឺមាន ១១នាក់ ហើយមកពីផ្នែកបង្កបង្កើនផល មកពីផ្នែកផ្សារក្រុង ផ្នែកពាណិជ្ជកម្ម និងផ្នែកមន្ទីរពេទ្យ។ ពួកគេទាំងអស់នេះត្រូវបានចោទថា ជាប់ជិតស្និទ្ធនឹងពួកក្បត់ ឬក៏មិនធ្វើការអ្វីខ្លះ មិនមានវិន័យ ឬក៏ត្រូវបានចោទថាជាយោធានៃរបបចាស់ ឬក៏មិនទទួលការអប់រំ ឬក៏ប្រព្រឹត្តនូវអំពើខុសសីលធម៌ ជាដើម...។ល។

ខ្ញុំសូមបង្ហាញនូវឯកសារផ្សេងទៀត គឺឯកសារ E3/846 របស់ក្រសួងពាណិជ្ជកម្ម ដែលជារបាយការណ៍ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនដូចគ្នា គឺចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ៧៦ ដែលមានបង្ហាញនៅក្នុងឯកសារពីរ ដែលខ្ញុំបានបង្ហាញជូនអម្បាញ់មិញនេះ។

[០៩:៣០:៣៩]

ឯកសារ E3/846 នេះ គឺចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៦ ដែលមានចំណងជើងថា "របាយការណ៍ប្រចាំ១០ថ្ងៃ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦"។ ជាចុងក្រោយ ដូចក្រសួងការបរទេសដែរ គឺយើងសូមយោងទៅលើបញ្ជីអ្នកទោសនៃមន្ទីរ ស-២១ ប្រសិនបើយើងចង់ស្គាល់ផ្នែក ឬក៏នាយកដ្ឋានផ្សេងៗ ដែលស្ថិតនៅក្រោមឱវាទរបស់ក្រសួងពាណិជ្ជកម្ម។

ឯកសារ IS16.52 ដែលមានលេខមួយទៀត គឺ IS16.53 ឯកសារនេះ យើងមានបកប្រែជាភាសាអង់គ្លេស។ ឯកសារនេះ ជាបញ្ជីអ្នកទោស ស-២១ ដែលមានចំណងជើងថា "មនុស្សនៅពាណិជ្ជកម្ម ដែលចាប់ហើយ ពីដើម រហូតមកដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៧" គឺមានន័យថា ជាមនុស្សដែលខាងក្រសួងពាណិជ្ជកម្មដែលត្រូវបានចាប់ខ្លួន តាំងពីដើមទី រហូមកដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៧។

ឯកសារនេះ មាន២១០ឈ្មោះ ដែលបញ្ជីដំបូងនោះ មាន៤១ឈ្មោះ មកពីខាងកសិកម្ម ហើយនិងមានបញ្ជីមួយទៀត គឺ 169 មកខាងអង្គភាពក្រសួងពាណិជ្ជកម្ម។ ដូច្នេះ វាមានសារៈសំខាន់ណាស់ឯកសារនេះសម្រាប់កំណត់អំពីរចនាសម្ព័ន្ធរបស់ក្រសួងពាណិជ្ជកម្ម។ ក្នុងនេះយើងឃើញមានពាណិជ្ជកម្មរដ្ឋ ពាណិជ្ជកម្មក្រៅប្រទេស ផែកំពង់សោម ផ្សារថ្មី ផ្សារអូរឫស្សី ឫស្សីកែវ ឃ្លាំងរដ្ឋ គីឡូម៉ែត្រលេខ៦ ផ្សាររដ្ឋ និងអង្គភាពផ្សេងៗនៅក្នុងប្រទេស ដែលក្នុងនោះមាន មន្ទីរពាណិជ្ជកម្មប៉ោយប៉ែត។

[០៩:៣២:៤៩]

ដើម្បីបញ្ចប់ចំពោះក្រសួងពាណិជ្ជកម្មនោះ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងបញ្ជី IS16.52 និង IS16.53 នោះ ក៏មានឈ្មោះ តាន់ ទ្រី ហៅ ឈឿន ដែលយើងបានឃើញកាលពីសប្តាហ៍មុនហើយថា ឈឿន ស្ថិតនៅក្នុងចំណោមមនុស្សមួយចំនួន ដែលត្រូវបានបញ្ជាក់ថា ជាសមាជិកគណៈពាណិជ្ជកម្មជាមួយនឹង វ៉ាន់ រិទ្ធ។

នៅក្នុងសំណុំរឿងនោះ យើងមានចម្លើយសារភាពរបស់ តាន់ ទ្រី ដែលមានលេខ E3/1641។ កម្មាភិបាលផ្សេងទៀត របស់ក្រសួងពាណិជ្ជកម្មដែរ គឺឈ្មោះ ញ៉ែម ដែលឈ្មោះពិតរបស់គាត់ គឺ ទិត្យ ស៊ុន ហៅ ព្រុំ ញ៉ែម ដែលជាសមាជិកទី២ របស់គណៈពាណិជ្ជកម្មនៅក្នុងសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦ គឺឯកសារ E3/235 ហើយគាត់នេះ គឺជាកម្មាភិបាលដំបូង ដែលបានធ្វើបទអត្ថាធិប្បាយនៅក្នុងសមាជរបស់ក្រសួងពាណិជ្ជកម្ម ថ្ងៃទី២៥, ២៦ ខែកក្កដា ឆ្នាំ១៩៧៦ នៅក្នុងឯកសារ E3/153។ ឈ្មោះរបស់គាត់ គឺមាននៅក្នុងបញ្ជីអ្នកទោស ស-២១

ដែលមានលេខ IS16.50 ហើយនៅក្នុងលេខរៀងទី៧ នៃបញ្ជីអ្នកទោសនេះ។ ចម្លើយសារភាពរបស់គាត់ នៅមន្ទីរស-២១ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ៧៦ ដែលមានលេខ D82/II-Annex 42។ សូមម្តងទៀត គឺលេខ D82/II-Annex 42។

យើងបានឃើញថា យើងបានរៀបរាប់ពីឯកសារមួយចំនួនរបស់ក្រសួងពាណិជ្ជកម្ម ហើយខ្ញុំនឹងបង្ហាញមួយទៀត គឺឯកសាររបស់ក្រសួងសង្គមកិច្ច គឺឯកសារពីរ។

ឯកសារដំបូងនោះ គឺឯកសារលេខ E3/226 ដែលជាកំណត់ហេតុនៃសង្គមកិច្ច និងសុខាភិបាល ថ្ងៃទី១០ មិថុនា ឆ្នាំ៧៦ ដែលជាកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ជាមួយសមាជិក ជាមួយសមមិត្តលេខា អនុលេខា, ហែម, មាន ភា ដែលជា អៀង ធីរិទ្ធ, ស៊ូ, សី ដែលជាអនុរបស់ អៀង ធីរិទ្ធ ហើយដែលបានបញ្ជូនទៅស-២១ ទាំងពីរនាក់ ហើយនិងកម្មាភិបាលផ្សេងទៀតរបស់សង្គមកិច្ច និងសុខាភិបាល។

[០៩:៣៥:៤៥]

បើតាមកំណត់ហេតុនេះ ភា ដែលជាអៀង ធីរិទ្ធ នោះ បានរាយការណ៍ជូនគណៈអចិន្ត្រៃយ៍អំពីការវិវត្តន៍ ហើយនិងកង្វះខាតនៅក្នុងវិស័យសុខាភិបាល។ គាត់បានលើកឡើងអំពីរោងចក្រផលិតថ្នាំបួន ហើយនិងមានមន្ទីរពេទ្យពីរដែលដំណើរការនៅសម័យនោះ ហើយបន្ទាប់មកកម្មាភិបាលផ្សេងទៀតឡើងធ្វើបទអន្តរាគមន៍ បន្ទាប់មកអង្គការធ្វើមតិយោបល់ ហើយបន្ទាប់មកទៀតគឺ ប៉ុល ពត ជាអ្នកធ្វើបទឧទ្ទេសនាម។

ខ្ញុំសូមដកស្រង់នូវចំណុចដែលមានលេខ ERN ជាភាសាខ្មែរ 00017154, ជាភាសាបារាំង ទំព័រ៦ ERN 00296163, ជាភាសាអង់គ្លេស 00183368។ នេះជាសម្តីរបស់លេខាបក្សនៅខែមិថុនា ឆ្នាំ១៩៧៦។

"ចំណុចទី១ អំពីកិច្ចការរបស់ក្រសួង" ចុះមកខាងក្រោមបន្តិចមក "ពិតមែនតែយើងមិនទាន់ម្ចាស់ការខាងបច្ចេកទេសទាំងស្រុងក៏ដោយ តែយើងមានគោលជំហរជាសំខាន់ ដូចខាងពេទ្យ យុទ្ធជន និងយុទ្ធនារីយើងជំនួសបច្ចេកទេសពេទ្យបានមួយកម្រិត។ សូមរំលងពីរបីបន្ទាត់ចុះមកក្រោមទៀត "កត្តាជាមូលដ្ឋានដែលនាំឲ្យឈានទៅមុខបាន នៅតែកត្តានយោបាយ និងកត្តាសតិអារម្មណ៍"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះយើងឃើញច្បាស់ហើយថា កត្តានយោបាយនោះគឺជាកត្តាដ៏សំខាន់ជាងកត្តាបច្ចេកទេសទៅទៀតសម្រាប់របបខ្មែរក្រហម។

[០៩:៣៨:៤១]

ពាក់ព័ន្ធទៅនឹងអ្នកជម្លៀសចេញពីទីក្រុង លេខាបក្សបានបែងចែកច្បាស់លាស់ណាស់គឺ អ្នកបដិវត្តន៍កសិករ ហើយនិងកម្មករ។ យើងឃើញមាននៅក្នុងទំព័រERN ជាភាសាខ្មែរគឺ 00017155, ជាភាសាបារាំងទំព័រដូចគ្នា ដែលខ្ញុំបង្ហាញពីមុនមកដែរ ហើយភាសាអង់គ្លេសគឺបន្តទំព័រ 00183369។ ខ្ញុំសូមដកស្រង់ "ដូច្នេះក្រសួងសង្គមកិច្ចសុខាភិបាល មានភារកិច្ចសំខាន់មួយដែរ ដើម្បីដោះស្រាយជីវភាពប្រជាជន ក៏ដូចជាដើម្បីដោះស្រាយជំងឺសត្វ។ ឧទាហរណ៍ ប្រជាជនចេញពីភ្នំពេញទៅជនបទមាននាំជំងឺអាសន្នរោគទៅតាមផង នាំឲ្យគ្រោះថ្នាក់ដល់ប្រជាជនយើង"។ សូមបញ្ចប់ការដកស្រង់។

ហើយខ្ញុំសូមបញ្ជាក់ថា ប៉ុល ពត បានបែងចែករវាងប្រជាជនយើង ដែលជាប្រជាជននៅជនបទ ហើយនិងប្រជាជននៅទីក្រុង ដែលត្រូវបានចោទថា នាំយកជំងឺទៅជាមួយ ចម្លងទៅដល់ប្រជាជនយើងនៅមូលដ្ឋាន។

[០៩:៣៩:០៥]

ឯកសារទី២ របស់ក្រសួងសង្គមកិច្ច គឺ E3/808 ឯកសារនេះគឺជាកម្រងកំណត់ហេតុ ដែលយើងឃើញដូចនៅក្រសួងការបរទេសដែរ គឺឯកសារនេះគឺជារបាយការណ៍របស់ក្រសួងពាណិជ្ជកម្ម។ ឯកសារនេះមានជំពូកផ្សេងៗ ដែលមានរបាយការណ៍របស់ -- របាយការណ៍នៃកិច្ចប្រជុំទូទៅរបស់មន្ទីរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ៧៨។ ឯកសារនេះលាតសន្ធឹងពីរយៈពេលពីថ្ងៃទី២៣ មេសា ឆ្នាំ៧៨ ទៅដល់ថ្ងៃទី០៦ តុលា ៧៨។ ឯកសារនេះបង្ហាញអំពីរចនាសម្ព័ន្ធរបស់ក្រសួង និងជាពិសេសទៅលើផ្នែកផ្សេងៗនៃមន្ទីរពេទ្យ១៧ មេសា ឬក៏យើងអាចហៅថា "មន្ទីរពេទ្យខ្មែរ-សូវៀត" ឬក៏ "ព-១៧"។ ឯកសារនេះបង្ហាញអំពីស្ថិតិនៃចំនួនពេទ្យ ចំនួនអ្នកជំងឺ ចំនួនអ្នកស្លាប់ ក៏ដូចជាគោលនយោបាយដែលអនុវត្តនៅក្នុងអង្គភាព ឬក៏ស្ថាប័នដែលនៅក្រោមឱវាទក្រសួងសង្គមកិច្ច។ ដូចគ្នានេះដែរ ដូចជានៅក្រសួង -- នៅក្នុងកិច្ចប្រជុំផ្ទៃក្នុងនៅក្នុងក្រសួងការបរទេស និងក្រសួងពាណិជ្ជកម្ម បុគ្គលិកធ្វើការទិតៀន និងស្វ័យទិតៀន ហើយនិងមានការបង្ហាញអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងរបស់ក្រសួងចំពោះខ្មាំង ជាពិសេសគឺចំពោះខ្មាំងវៀតណាម។ ម្យ៉ាងវិញទៀតមានការស្លាប់មនុស្សមួយចំនួន ដោយសារតែកំហុសផ្នែកវេជ្ជសាស្ត្រ ដែលធ្វើឡើងដោយបុគ្គលិកពេទ្យដែលមិនមានសមត្ថភាព ដែលមិនមាន -- ដែលមិនចេះអក្សរ។

[០៩:៤១:00]

ខ្ញុំសូមអានឃ្លាពីរបី គឺដំបូងគឺនៅក្នុងភាសាខ្មែរគឺ 00000534, ជាភាសាបារាំងទំព័រ៨ ហើយ

និងទំព័រខាងមុខទៀត ដែលមានលេខ ERN 00811290, ជាភាសាអង់គ្លេស 00197559។ ខ្ញុំសូមដកស្រង់ "នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ៧៨ កិច្ចប្រជុំក្រុមអំពីផ្នែកនយោបាយ មនោគមវិជ្ជា និងចាត់តាំង។ នៅក្នុងរបៀបវារៈមាន ចំណុច ១) ស្មារតីបំពេញភារកិច្ចប្រចាំថ្ងៃ, ចំណុចទី២) ស្មារតីសាមគ្គីភាព, ចំណុចទី៣) សីលធម៌រស់នៅ"។ ជាចំណុចនេះ ខ្ញុំសូមយោងទៅលើការបកប្រែជាភាសាអង់គ្លេសដែលមានលក្ខណៈច្បាស់លាស់ជាង ដែលយើងអាចបកប្រែមកជាភាសាខ្មែរថា ការគោរពតាមសីលធម៌រស់នៅ។ "ចំណុចទី៤) ស្មារតីសមូហភាពនៃវណ្ណៈអធន, ចំណុចទី៥) ការគោរពវិន័យអង្គការ។ ចំណុចទី៦) សេដ្ឋកិច្ច អនាម័យ និងការប្រុងប្រយ័ត្នបដិវត្តន៍។ ចំណុចទី៧) បញ្ហាអប់រំបច្ចេកទេសនយោបាយ បច្ចេកទេសវប្បធម៌ វិទ្យាសាស្ត្រ ហើយនិងទី៨) គឺការយកចិត្តទុកដាក់ទៅលើសភាពការណ៍ខ្មាំង"។ ខ្ញុំសូមលើកឡើងនៅពេលនេះ គឺសង្កត់ធ្ងន់ទៅលើពាក្យ សីលធម៌រស់នៅ, ការប្រុងប្រយ័ត្នបដិវត្តន៍, ការគោរពវិន័យ, ហើយនិងការយកចិត្តទុកដាក់ទៅលើសភាពការណ៍ខ្មាំង។

[០៩:៤៣:០៧]

ខ្ញុំសូមអាននូវសម្រង់ទី២ នៅទំព័រជាភាសាខ្មែរគឺ 00000549, ជាភាសាបារាំងគឺទំព័រ២៥ លេខ ERN 00813997, ជាភាសាអង់គ្លេស 00197635។ ខ្ញុំសូមអានឃ្លានេះជាភាសាអង់គ្លេសពីព្រោះថាភាសាបារាំងបកប្រែដូចជាមិនសូវច្បាស់។ ដូច្នេះចំពោះអ្នកបកប្រែខ្ញុំនឹងអាចជាភាសាអង់គ្លេស។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស "នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩០០ (ស៊ីក) ការប្រជុំ ទី១ តំណាងបក្សមកពីក្រសួងសង្គមកិច្ច ហើយនិងយុវជន"។ ខ្ញុំទៅខាងបន្តិចទៀត "តាមសំណើរបស់បក្ស យើងនឹងធ្វើការវាយខ្មាំង ដើម្បីកុំឲ្យខ្មាំងងើបក្បាលបាន។ ជាចាំបាច់យើងត្រូវប្រុងប្រយ័ត្នអំពី មន្ទីរពេទ្យ១៧ មេសា ហើយការផ្តោតអារម្មណ៍ និងការយកចិត្តទុកដាក់ -- ការវាយតម្លៃបន្ទាប់មក នៅក្នុងមាតុភូមិយើងនោះ ហើយខុសពីអតីតកាល ហើយអំពីការផ្សាយនៅក្នុងការឃោសនារបស់វិទ្យុ។ ផ្អែកលើអ្វីដែលបានឃើញដោយភ្នែករបស់យើងនោះ គឺថាសកម្មភាពខ្មាំងនៅក្នុងចុងខែឧសភា និងពាក់កណ្តាលខែមិថុនា បន្ទាប់ពីយើងវាយយួន -- ខ្មាំងយួនហើយ ខ្មាំងយួនបានចូលមកជាម្តងទៀត វាយប្រហារកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យគេរួមជាមួយខាងភូមិភាគបូព៌ា។ ខ្មាំងយួនចូលកាន់កាប់ភូមិភាគបូព៌ា ហើយកាន់កាប់មេគង្គ ហើយចូលមកភ្នំពេញ។ ក្រុមទាំងអស់នេះត្រូវបានកម្ទេចទាំងស្រុងហើយ។ ខ្មាំងយួនត្រូវវាយចាប់ពីគ្រប់ទិសដៅទាំងអស់។ គឺមានបញ្ហាស្មុគស្មាញមួយចំនួន យើងត្រូវការអ្នកជំនួយបច្ចេកទេសដើម្បីវាយពួកក្បត់នោះ។ ហើយគេបាន -- គេមកយាយី ហើយបំពានទៅលើមិត្តប្រដាប់អាវុធរបស់យើង"

សូមបញ្ចប់សេចក្ដីដកស្រង់។

[០៩:៤៦:២០]

ជាចុងក្រោយ គឺខ្ញុំមានឯកសារពីររបស់ក្រសួងឃោសនាការ ដែលខ្ញុំចង់បង្ហាញជូនក្នុងចំណោមកិច្ចប្រជុំបីរបស់គណៈអចិន្ត្រៃយ៍ គឺមានឯកសារពីរ ដែលខ្ញុំចង់បង្ហាញជូន។ គឺឯកសារ E3/231 ដែលជាកំណត់ហេតុកិច្ចប្រជុំកិច្ចការងារឃោសនាការ ថ្ងៃទី១៨ ខែមីនា ឆ្នាំ៧៦ ដែលមាន ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន, សមមិត្ត ឌឿន ដែលជា សឿ វ៉ាស៊ី, ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការ។ កិច្ចប្រជុំនេះមានគោលដៅ គឺការផ្សាយអំពីការបោះឆ្នោតថ្ងៃទី២០ ខែមីនា ឆ្នាំ៧៦។ នៅពេលដែលយើងអានឯកសារនោះ យើងឃើញថា ការផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោតនោះ គណៈអចិន្ត្រៃយ៍ជាអ្នកសម្រេចទៅលើការផ្សាយ ហើយនិងខ្លឹមសារនៃការបោះឆ្នោតទាំងអស់នេះ។

ឯកសារមួយទៀត គឺឯកសារលេខ E3/225 ដែលជាកិច្ចប្រជុំការងារឃោសនាការ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ៧៦។ កិច្ចប្រជុំនេះមានសមមិត្តលេខា សមមិត្តអនុលេខា ដែលជាតំណាងឲ្យគណៈអចិន្ត្រៃយ៍ ហើយនិងមានកម្មាភិបាលផ្សេងៗទៀតរបស់ក្រសួងឃោសនាការ ក្នុងនោះមានសមមិត្ត ភាស់។ ខ្ញុំសូមបញ្ជាក់ថា ជាភាសាបារាំងនោះមានកំហុសខាងផ្នែកបកប្រែ ពីព្រោះថាជាភាសាបារាំង បកថា សមមិត្ត កាស (កា-អា-អេស) ហើយជាភាសាអង់គ្លេសគឺបកត្រូវថា ភាស់។ ដូច្នេះអង់គ្លេស និងខ្មែរបកត្រូវ ហ៊ូ នឹម ជាសមមិត្ត ភាស់ ហើយនិងមាន សមមិត្តគួយ និង សុង ហើយនិងក្រុមវិទ្យុ ហើយនិងក្រុមភាពយន្ត។

[០៩:៤៨:២០]

ដោយមិនចូលទៅក្នុងលម្អិតនោះ យើងឃើញថា គណៈអចិន្ត្រៃយ៍ តាមរយៈលេខា និងអនុលេខាបក្ស គឺជាអ្នកគ្រប់គ្រងទៅលើគោលនយោបាយឃោនាការ និងសកម្មភាពរបស់ក្រសួងឃោសនាការ ហើយគ្រប់គ្រងរហូតទៅដល់ចំណុចលម្អិតៗថែមទៀត។ ឧទាហរណ៍ គឺគណៈអចិន្ត្រៃយ៍នោះជាអ្នកកំណត់ថា ក្រុមណាត្រូវមានមនុស្សប៉ុន្មាន ហើយមានកំណត់ពីវិធានក្នុងការ ថតភាពយន្ត ថតកុន... ។ល។ ដើម្បីផ្សាយតាមវិទ្យុ។

អស់លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់ការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងរដ្ឋាភិបាល រាជរដ្ឋាភិបាលរួបរួមជាតិ និងរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យ និងក្រសួងផ្សេងៗរបស់កម្ពុជាប្រជាធិបតេយ្យ ហើយនិងនយោបាយដែលអនុវត្តនៅក្នុងកម្ពុជាប្រជាធិបតេយ្យ នៅក្នុងរយៈពេលនៃរបបខ្មែរ

ក្រហម។ ហើយឥឡូវនេះខ្ញុំសូមផ្តល់ជូនវេទិកានេះជូនសហការីរបស់ខ្ញុំបន្តទៅទៀត។ សូមអរគុណ។

[០៩:៤៩:៤០]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស ជាបឋមសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងភាគីទាំងអស់ និងអ្នកទាំងអស់ដែលមានវត្តមាននៅទីនេះ។

ជាបន្តទៅទៀតនេះខ្ញុំនឹងធ្វើបទបង្ហាញពីឯកសារមួយចំនួន ដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងដែលបានធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលការប្រាស្រ័យទាក់ទងទាំងនេះ គឺចាប់តាំងពីគណៈមជ្ឈិម ដែលបានដាក់ចេញជាការណែនាំ ដាក់ចេញជាសេចក្តីសម្រេចនានាទៅកាន់ភូមិភាគ ហើយភូមិភាគក៏បានធ្វើការប្រាស្រ័យទាក់ទងជាមួយថ្នាក់មជ្ឈិម ឬអង្គការវិញតាមរយៈទូរលេខ ឬរបាយការណ៍ដើម្បីជូនដំណឹង ក៏ដូចជារាយការណ៍ដល់ថ្នាក់លើរបស់ខ្លួនអំពីបញ្ហាផ្សេងៗ ដែលបានកើតមានឡើងនៅក្នុងភូមិភាគនីមួយៗ។ លើសពីនេះទៅទៀត ខ្ញុំនឹងធ្វើបទបង្ហាញផងដែរ ពីតួលេខ របាយការណ៍ពីថ្នាក់តំបន់ ថ្នាក់ស្រុក ថ្នាក់ឃុំ ពីទំនាក់ទំនងរដ្ឋបាល និងពីទំនាក់ទំនងដែលមាន -- ដែលបានកើតមានឡើងនៅពេលនោះ។ តែមុននឹងចាប់ផ្តើមធ្វើបទបង្ហាញ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីដាក់បង្ហាញនូវឯកសារមួយចំនួន នៅលើអេក្រង់កុំព្យូទ័រផងដែរ និងសូមអនុញ្ញាតពីលោកប្រធានផងដែរ ដើម្បីចែកជូននូវផែនទីមួយនេះ ជូនដល់ភាគីទាំងអស់នៅក្នុងសវនាការនេះ ដើម្បីជាជំនួយដល់ការធ្វើបទបង្ហាញរបស់ខ្ញុំ ហេតុដូច្នេះ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាជាតិយកជូនភាគី!

*(មន្ត្រីតុលាការយកឯកសារជូនភាគី)*

[០៩:៥១:៣៣]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ ពេលនេះខ្ញុំនឹងធ្វើបទបង្ហាញអំពីកំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ គឺនៅក្នុងឯកសារលេខ E3/182 ចុះថ្ងៃទី០៩ ខែ១០ ឆ្នាំ៧៥ ដែលមាន ERN ជាភាសាខ្មែរគឺ 00019108 ដល់ 119, ជាភាសាអង់គ្លេសគឺ 00183393 ដល់ 402, ជាភាសាបារាំងគឺ

00292868 ដល់ 879។ កំណត់ហេតុប្រជុំនេះ បានបង្ហាញអំពីសមាសភាពរបស់គណៈអចិន្ត្រៃយ៍ដែលចូលរួមនៅក្នុងការប្រជុំមានដូចជា សមមិត្តលេខាទទួលរួមយោធា និងសេដ្ឋកិច្ច, សមមិត្តអនុលេខាទទួលការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ, សមមិត្តវ៉ាន់ ការងារបរទេសទាំងបក្សទាំងរដ្ឋ។ សមមិត្ត ហែម ទទួលរណសិរ្ស និងរដ្ឋាភិបាល ពាណិជ្ជកម្ម ខាងបញ្ជី និងតម្លៃ។ សមមិត្តដទៃទៀត សរុបទាំងអស់ចំនួន ១៣រូប”។ ឯកសារនេះដដែល ត្រង់ ERN ជាភាសាខ្មែរគឺ 00019111, ជាភាសាអង់គ្លេសគឺ ERN គឺ 00183395, ERN ជាភាសាបារាំងគឺ 00292871 ដល់72 បានបង្ហាញអំពីការណែនាំដល់មន្ទីរក្នុងការបែងចែកទូរលេខបន្ទាប់ពីទទួល។

[០៩:៥៣:២៣]

ខ្ញុំសូមដកស្រង់ “តាំងពីទូរលេខឡើងទៅគេទទួលបានភ្លាម មន្ទីរត្រូវប្រគល់ឲ្យផ្នែកទទួលខុសត្រូវភ្លាម។ ឲ្យពិនិត្យ ពិចារណា ហើយស្នើអចិន្ត្រៃយ៍បញ្ហាខ្លះត្រូវប្រញាប់, បញ្ហាយោធា ឲ្យខាងយោធា បញ្ហាពាណិជ្ជកម្ម ឲ្យខាងពាណិជ្ជកម្ម, បញ្ហាបក្ស ឲ្យផ្នែកបក្ស”។ ឯកសារដដែលនេះ ចុះមកខាងក្រោមបន្តិចក៏បានណែនាំផងដែរពីរបបនៃការរាយការណ៍។ ខ្ញុំសូមដកស្រង់ “ពេលអចិន្ត្រៃយ៍ប្រជុំម្នាក់ៗ រាយការណ៍ កន្លងមកការងារប្រមូលមកសមមិត្ត ខៀន ទាំងអស់ ថ្ងៃក្រោយត្រូវឲ្យផ្នែកនីមួយៗគេគិត ឧទាហរណ៍ការងារបរទេស ថ្ងៃក្រោយត្រូវគិតទាំងអស់ យើងមិនចង់ឲ្យការងារប្រមូលមកអចិន្ត្រៃយ៍។ មន្ទីរ អចិន្ត្រៃយ៍ទាក់ទងពីផ្នែកមួយទៅផ្នែកមួយ អចិន្ត្រៃយ៍តាមដានផ្នែកនីមួយៗក្នុងការអនុវត្តមាគ៌ា” ខ្ញុំសូមរំលងបន្តិច ចុះមកខាងក្រោម “យើងត្រូវចាប់ដំណើរការតាំងពីស្អែកនេះទៅ” បញ្ចប់ការដកស្រង់។

នៅក្នុងឯកសារដែលជាកំណត់ហេតុដដែល ប៉ុន្តែនៅត្រង់ ERN ជាភាសាខ្មែរគឺ 0009118, ជាភាសាអង់គ្លេសគឺ 00183401, ជាភាសាបារាំងគឺ 00292878 ដល់ 79។ ត្រង់ទំព័រ១១ ជាភាសាខ្មែរ បានបញ្ជាក់ពីភារកិច្ចរបស់វិទ្យុទាក់ទង។ “ជាឧទាហរណ៍ គឺវិទ្យុទាក់ទងប្រើសម្រាប់ការងារចំពោះមុខ បម្រើការងារក្នុងសង្គ្រាម”។ សូមរំលងបន្តិច “ហើយមានទិសដៅនៅឯសមុទ្រ និងរតនគិរី”។

[០៩:៥៥:២៥]

ឯកសារមួយទៀត ខ្ញុំនឹងលើកឡើងអំពីកំណត់ហេតុនៃអង្គប្រជុំមួយផ្សេងទៀត។ ឯកសារលេខ E3/232 ដែលជាកំណត់ហេតុនៃអង្គប្រជុំការងារមូលដ្ឋានដែលបានធ្វើនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦។ នៅក្នុងឯកសារនេះ បានបង្ហាញពីសមាសភាពដែលបានចូលរួមក្នុងកិច្ចប្រជុំរួមមាន៖ សមមិត្តលេខា,

សមមិត្តទូច, សមមិត្តហែម, សមមិត្តឌឿន, សមមិត្តស្រេង, សមមិត្តហង់, សមមិត្តសុត។ នៅក្នុងកិច្ចប្រជុំនេះ លោក ខៀវ សំផន បានធ្វើការរាយការណ៍ជូនមូលដ្ឋានពាក់ព័ន្ធនឹងគោលការណ៍នៃការបោះឆ្នោត ហើយក៏មានមតិបញ្ជាក់បន្ថែមពីអង្គការ អំពីន័យនយោបាយនៃការបោះឆ្នោតផងដែរ។

បន្ទាប់ពី សមមិត្តហែម បានរាយការណ៍រួចហើយពាក់ព័ន្ធទៅនឹងសភាពការណ៍នៅ ៣០៣ "សមមិត្តស្រេង បានរាយការណ៍ជូនអង្គការពីសកម្មភាពរបស់ពួកអាលឿន និងគ្នាវា ៣៤នាក់ ដែលកងទ័ពចាប់បាន កងទ័ពចាប់ខ្លួនបានអស់ហើយ"។ ចំណែកឯនៅឯកសារដដែល ប៉ុន្តែពាក់ព័ន្ធទៅនឹងសភាពការណ៍នៅ១០៦ វិញ គឺសមមិត្តសុត ជាអ្នករាយការណ៍ជូនអង្គការផងដែរ។ រីឯនៅ ១០៣ សមមិត្តហង់ ជាអ្នករាយការណ៍ជូនអង្គការពីបញ្ហាខ្លះ ដែលបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាដែលបានរាយ-ការណ៍ជូនអង្គការនោះ គឺ ខ្ញុំសូមដកស្រង់ "ចំណែកនៅក្នុងតំបន់ទាំងមូល គ្មានសកម្មភាពខ្លាំងទេ។ មានតែពួករត់ពីកន្លែងផ្សេងៗមក ដូចជា រត់ពី៣០៣ ឬពីកំពង់ឆ្នាំង ចាប់បាន -- ចាប់ពីខែ០១ មកចាប់បានជិត ១០០នាក់ហើយ"។

[០៩:៥៧:៣២]

ឯកសារ E3/232 ដដែលបានលើកឡើងអំពីការណែនាំរបស់អង្គការទៅកាន់មូលដ្ឋាន ដែលការណែនាំនេះ ខ្ញុំសូមដកស្រង់ "ចំពោះបញ្ហានៅ៣០៣ ជាវិធានការ ត្រូវហៅអ្នកដែលមានឈ្មោះមកសាកសួរ ហើយឆ្លើយយ៉ាងម៉េច យើងមិនទាន់ដកពីតំណែងទេ។ បន្ទាប់មកហៅមកសាកសួរទៀត នៅចំពោះមុខអ្នកចោទ ហើយចំមើល តើមានប្រតិកម្មយ៉ាងណា? ដូច្នេះមានពីរដំណាក់កាល គឺសួរហើយទុកមួយកន្លែង ហើយរាយការណ៍មកខាងលើ ដោយមានភ្ជាប់សំណុំរឿងផង"។ ឯកសារដដែលនេះ ក៏បានបង្ហាញពីរបបនៃការរាយការណ៍ ខ្ញុំសូមដកស្រង់ "១) ស្នើរាយការណ៍ជូនអចិន្ត្រៃយ៍ រាល់អាទិត្យអំពីសភាពការណ៍" រំលងបន្តិច "អចិន្ត្រៃយ៍ដឹងអាចឆ្លើយតបទាន់ពេលវេលា"។ ទំនាក់ទំនងដែលបានកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលមាននៅក្នុងឯកសារបន្ទាប់មកទៀតនេះ គឺឯកសារលេខ E3/216 ដែលជាកំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យដែលបានធ្វើនៅថ្ងៃទី២០ ដល់ ២៤ សីហា ឆ្នាំ១៩៧៥។

[០៩:៥៩:០៧]

ផ្នែកទីI នៃឯកសារនេះ និយាយអំពីសេចក្ដីរាយការណ៍អំពីសមភាពការណ៍រួមនៅមូលដ្ឋាន។ ក្នុងផ្នែកទីI ចំណុច ១) ជាសេចក្ដីរាយការណ៍ពីសភាពការណ៍ប្រជាជនដែលមានការខ្វះខាតក្នុងការរស់

នៅ។ ខ្ញុំសូមដកស្រង់ "ប្រជាជនថ្មីមានការខ្វះខាត ខ្វះស្បៀង ខ្វះថ្នាំសង្កូវផង មានលិចល្វា និងតាមស្ទឹង មង្គលបូរី គ្រុនក្ដៅច្រើន"។ ក្នុងផ្នែកទីI នេះដដែល តែត្រង់ចំណុច ២) ក្នុងចំណុច(ខ) បានបង្ហាញពី សកម្មភាពខាងក្នុង។ ខ្ញុំសូមដកស្រង់ "វាមានខ្សែបង្កប់វា រៀបចំទាក់ទងពីកន្លែងមួយទៅកន្លែងមួយ។ វាមានបង្កប់ក្នុងចំណោមកម្មកររទេះភ្លើង (កម្មករថ្មី) វាធ្វើសង្គ្រាមចិត្តសាស្ត្រ ធ្វើវិទ្ធេទកម្ម ខាងក្នុងជួរ យើងដែលសម្រិតសម្រាំងមិនអស់ ក៏នៅមាន។ វាប្រើប្រាស់ពួកនេះ ឲ្យនាំប្រជាជនរត់។ យើងចាប់វា បានជាបន្តបន្ទាប់ ហើយកំពុងបន្តរាវរកទៀត"។ ឯកសារដដែល ត្រង់ចំណុចII បានបង្ហាញមតិណែនាំ របស់អង្គការ ដែលមានត្រង់ចំណុចមួយនៃឯកសារ បានបង្ហាញពីកិច្ចដំណើរការការពារប្រទេស។

[១០:០០:៥០]

ចំណុច(ក) និយាយអំពីបញ្ហាគន្លឹះមួយចំនួន ខ្ញុំសូមដកស្រង់ "បញ្ហាគន្លឹះ គឺដោះស្រាយសភាព ការណ៍នយោបាយរបស់ប្រជាជន" រំលងបន្តិច "ជាក់ស្ដែងគឺត្រូវពង្រឹងពង្រីកសហករណ៍ យកកម្លាំង សហករណ៍ធ្វើជាស្នូល។ ធ្វើឲ្យស្នូលនេះ រឹងថែសសម្រាប់ស្រូបប្រជាជនថ្មី។ ប្រជាជនថ្មី ត្រូវរណប សហករណ៍ទាំងនយោបាយ ទាំងសេដ្ឋកិច្ច។ នេះជាទិសដៅរបស់យើង"។ នៅបន្ត -- នៅទំព័របន្ទាប់ជា ខ្មែរ ក្នុងចំណុចII ដដែល បានបញ្ជាក់ពីតួនាទីរបស់សហករណ៍មានពីរ ហើយនៅក្នុងចំណុចទី២ នៃតួនាទីនោះ ខ្ញុំសូមដកស្រង់ "តួនាទីក្រោយពេលរំដោះទាំងស្រុង៖ សហករណ៍ស្រូបប្រជាជនថ្មីចេញពី ទីក្រុងទាំងអស់ ពិសេសក្រុងភ្នំពេញ ហើយនៅពាយ័ព្យ គឺបាត់ដំបង។ ប្រជាជនថ្មីរាប់សែននាក់នៅ បាត់ដំបង មានសមាសភាពអាក្រក់គ្រប់យ៉ាង"។ យោងតាមកំណត់ហេតុដដែលនេះ ក៏បានដាក់ចេញនូវ វិធានការជាក់ស្ដែងមួយចំនួន ដើម្បីឲ្យថ្នាក់ក្រោមអាចអនុវត្តបាន។ ហើយត្រង់វិធានការចំណុចទី៤នៃ ឯកសារ បានណែនាំថា ខ្ញុំសូមដកស្រង់ "យកចិត្តទុកដាក់ពិនិត្យសហករណ៍ថែម សមាសភាពចាស់ថ្មី ឲ្យស្រុកឃុំដឹង ហើយអប់រំសហករណ៍ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង" បញ្ចប់ការ ដកស្រង់។

[១០:០២:៤០]

ជាបន្ទាប់មកទៀតនេះ ខ្ញុំសូមចូលដល់ឯកសារមួយថ្មីទៀត គឺឯកសារ E3/200 ដែលឯកសារ នេះ ជាសុន្ទរកថារបស់លោក ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួបថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧។ ត្រង់ ERN ជាភាសាខ្មែរ 00292805, ជាភាសាអង់គ្លេស 00004165, ជាភាសាបារាំង 006121 66។ ខ្ញុំសូមដកស្រង់ "តាមរយៈការទប់ស្កាត់ជាដាច់ខាតនូវសត្រូវទាំងអស់ រារាំងពួកវា ពីការឈ្លាន

ពាន ពីការជ្រៀតជ្រែក ឬការធ្វើវិទ្ធង្សនាប្រឆាំងនឹងយើង។ យើងត្រូវបោសសម្អាតសត្រូវ នៅក្នុងសមាសភាពយើងជាម្ចាស់ការលើស្ថានភាព ដើរតាមមាគ៌ានយោបាយក្នុងស្រុក គោលនយោបាយបរទេស និងគោលនយោបាយយោធារបស់អង្គការបដិវត្តន៍របស់យើង។ ត្រូវធ្វើអ្វីៗឲ្យល្អប្រណីត និងគ្រប់ជ្រុងជ្រោយ។ យើងមិនត្រូវមានចិត្តរាយមាយធ្វេសប្រហែស ឬភ្លេចភ្លាំងដោយសារជោគជ័យអតីតកាលទេ។ ផ្ទុយទៅវិញ យើងត្រូវតែប្ដេជ្ញាដោយខ្លួនឯងបន្ថែមទៀត ត្រូវប្រុងប្រយ័ត្នជាប់ជានិច្ចរក្សាស្មារតីបដិវត្តន៍ឥតងាករេ បន្តវាយប្រយុទ្ធ និងទប់ស្កាត់សត្រូវគ្រប់ប្រភេទ គ្រប់ពេលវេលា”។ បញ្ចប់ការដកស្រង់។

[១០:០៤:៣០]

ឯកសារមួយទៀត ជាឯកសារថ្មីដែរ គឺឯកសារ E3/166 វាជាទង់បដិវត្តលេខ២-៣ ខែកុម្ភៈមីនា ឆ្នាំ១៩៧៦។ នៅក្នុងទង់បដិវត្តនោះ វាជាការណែនាំដែលមានសរសេរចុះផ្សាយនៅក្នុងទង់បដិវត្តនៅត្រង់ ERN ជាភាសាខ្មែរ គឺ 00063210, ERN ជាភាសាអង់គ្លេសគឺ 00517830 និងERN ជាភាសាបារាំងគឺ 00492773។ ខ្ញុំសូមដកស្រង់ខ្លឹមសារចេញអំពីទង់បដិវត្តន៍នោះ, ដកស្រង់ “ឃើញបច្ច័យល្អ អាក្រក់ នៃការឃោសនាអប់រំរបស់ប្រជាជន មហាជន ដូចមានពោលខាងលើនេះហើយបក្ខជនគ្រប់រូប កម្មាភិបាលរបស់បក្សគ្រប់ថ្នាក់ចាំបាច់ត្រូវចាប់អារម្មណ៍ឲ្យខ្ពស់ចំពោះបញ្ហាឃោសនាអប់រំប្រជាជន មហាជននេះ។ ទោះបីជារវល់ការងារមមាញឹកយ៉ាងណា ក៏ត្រូវចេះឆ្លៀតពេលធ្វើការឃោសនាអប់រំប្រជាជនមហាជនក្នុងមូលដ្ឋានយើង ក្នុងក្របខ័ណ្ឌយើងឲ្យបានទៀងទាត់ជាប់ជានិច្ច”។ បញ្ចប់ការដកស្រង់។

[១០:០៦:០៨]

ជាបន្តទៅទៀតនេះ ខ្ញុំសូមបង្ហាញឯកសារ E3/12 ដែលឯកសារនេះជាសេចក្ដីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន ដែលបានធ្វើនៅថ្ងៃទី៣០ ខែ៣ ឆ្នាំ៧៦។ ត្រង់ទំព័រទី១ ហើយទំព័រទី១ ហ្នឹងគឺគ្រប់ភាសា ត្រង់ចំណុចទី២ យោងតាមសេចក្ដីសម្រេចរបស់គណៈមជ្ឈិមទាក់ទងទៅនឹងរបបនៃការរាយការណ៍មួយអាទិត្យម្ដងៗមក៨៧០។ នៅឯកសារដដែលគឺឯកសារ E3/12 នេះ ប៉ុន្តែត្រង់ERN ជាភាសាខ្មែរ គឺ 0003 (សូមទោសសូមម្ដងទៀត) ERN ជាភាសាខ្មែរគឺ 00003139, ERN ជាភាសាអង់គ្លេសគឺ 00182812 និងERN ជាភាសាបារាំងគឺ 00224365។ ត្រង់ចំណុចទី៩ នៃសេចក្ដីសម្រេចរបស់គណៈមជ្ឈិមអំពីកម្មវិធីបុណ្យឯករាជ្យ។ ខ្ញុំសូមដកស្រង់ “៩) កម្មវិធីបុណ្យ

ឯករាជ្យ៣ថ្ងៃ ១៥, ១៦, ១៧ ខែ០៤ បុណ្យឯករាជ្យ និងបុណ្យចូលឆ្នាំផង”។ ខាងក្រោមបន្តិច “មូលដ្ឋានក៏ត្រូវធ្វើយ៉ាងនេះដែរ ឲ្យប្រជាជនសម្រាក៣ថ្ងៃ ដើម្បីអប់រំនយោបាយ”។ ឯកសារជាបន្តទៅទៀតនេះ គឺឯកសារលេខ E3/160 វាជាការណែនាំពីមន្ទីរ៨៧០ ពាក់ព័ន្ធទៅនឹងថ្ងៃបុណ្យឯករាជ្យ និងបុណ្យចូលឆ្នាំដែរ។ ខ្ញុំសូមដកស្រង់ “ថ្ងៃ១៦, ១៧, ១៨ ខែមេសា ខាងមុខ ជាថ្ងៃបុណ្យឯករាជ្យផង ជាថ្ងៃបុណ្យចូលឆ្នាំប្រពៃណីផង ពេល៣ថ្ងៃនេះ ស្នើបងណែនាំឲ្យគ្រប់សហករណ៍ គ្រប់ការដ្ឋាន គ្រប់រោងចក្រ ក្រសួងមន្ទីរសម្រាកការងារទាំងអស់ ទុកពេលឲ្យបងប្អូនកសិករ និងកម្មករយើងសម្រាក និងកម្សាន្តថ្ងៃបុណ្យ ព្រមជាមួយនេះ ក៏ស្នើឲ្យរៀបចំរបបពិសេសទាំងបាយទឹក ម្ហូបអាហារ ចំណីក្នុង៣ថ្ងៃនេះផង។ ក្រៅពីនេះ មិនបាច់ធ្វើមីទ្ទិងតាមកន្លែងមួយៗទេ។ ថ្ងៃដំបូងមានតែពិធីគោរពទង់ជាតិ និងគោរពវិញ្ញាណក្ខន្ធ និងចាត់តាំងរួមគ្នាស្តាប់សេចក្តីថ្លែងការណ៍របស់គណៈរដ្ឋតាមវិទ្យុជាតិយើងបានហើយ”។

[១០:០៩:០៧]

នៅត្រង់ចំណុចទី៣ ឯកសារដដែល ក៏មានការដាក់ការណែនាំចេញអំពីមន្ទីរ ៨៧០ ដល់កងទ័ពផងដែរ។ ខ្ញុំសូមដកស្រង់ “ចំពោះកងទ័ពកម្មវិធីដូចគ្នាខាងលើដែរ តែចាំបាច់ត្រូវផ្លាស់វេនប្រចាំការប្រយុទ្ធឲ្យម្ចាស់ការលើខ្មាំងជានិច្ច”។ ផ្នែកខាងក្រោមបំផុតនៃឯកសារ E3/160 នេះ ដែលពាក់ព័ន្ធនឹងការណែនាំដូចដែលបានរៀបរាប់ខាងលើនេះ ធ្វើឡើងគឺនៅថ្ងៃទី០១ ខែ៤ ឆ្នាំ៧៨ មន្ទីរ៨៧០ ដោយភាពគោរពបដិវត្តន៍ យ៉ាងកក់ក្តៅបំផុត។

ជាបន្តទៅទៀតនេះ ខ្ញុំនឹងលើកឡើងពីការប្រកាសរបស់គណៈមជ្ឈិមដែលធ្វើឡើងនៅថ្ងៃទី០១ ខែ០១ ៧៩ ដែលមានលេខឯកសារ E3/722 ដែលការប្រកាសនេះនិយាយអំពីការប្រយុទ្ធប្រឆាំង និងជាដាច់ខាតប្រឆាំងនឹងខ្មាំងយួន ឈ្លានពាន វាតទីលេបទឹកដី។ ដើម្បីប្រយុទ្ធប្រឆាំងនឹងខ្មាំងយួន សមាសភាពដែលគណៈ៨៧០ បានធ្វើការណែនាំមានដូចជា “បក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្ពុជាទាំងមូល កងទ័ពបដិវត្តន៍កម្ពុជាទាំងមូល យុវជនយុវនារី កម្មាភិបាលគ្រប់ក្រសួងមន្ទីរទាំងអស់។ ១) ត្រូវពង្រឹងពង្រីកប្រយុទ្ធជាប្រចាំ និងដាច់ខាតជាមួយខ្មាំងយួន ឈ្លានពាន វាទទីលេបទឹកដី បំបាត់ពូជសាសន៍កម្ពុជា។ គ្រប់អំពើប្រព្រឹត្តទាំងអស់ត្រូវឈរលើជំហររួមវាយខ្មាំងយួនដាច់ខាត។ ២) ត្រូវលើកកម្ពស់ស្មារតី ប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជាប់ជានិច្ច តាមដាន រាវរកភ្នាក់ងារខ្មាំងយួន កុំឲ្យវាលាក់បំពួនបាននៅទីកន្លែងណាឲ្យសោះ ហើយកម្ចាត់វា ឲ្យម្ចាស់ការនិងទាន់ពេលវេលា”។ បញ្ចប់ការដកស្រង់។

ឧទាហរណ៍មួយទៀត ដែលបង្ហាញអំពីការទំនាក់ទំនងរវាងគណៈមជ្ឈិមទៅកាន់ថ្នាក់ក្រោមដែរ នោះគឺ មាននៅក្នុងឯកសារ E3/1150។ ខ្ញុំសូមដាក់បង្ហាញឯកសារនេះ ហើយសូមដកស្រង់នៅលើក្បាលឯកសារ គឺបានបង្ហាញអំពី ចាប់ផ្តើម "ជម្រាបជូនសមមិត្ត យ៉ា ជាទីស្នេហា និងរពួក"។

[១០:១១:៥៩]

ត្រង់ចំណុចទី I ត្រង់ទំព័រទី១ គ្រប់ភាសា បានបញ្ជាក់ថា ដកស្រង់ "យើងបានទទួលទូរលេខថ្ងៃទី៩ ខែ១០ ៧៥ របស់សមមិត្តហើយ តាមរយៈលិខិតដដែលនេះគណៈមជ្ឈិមបានធ្វើការណែនាំមួយចំនួនផងដែរ"។ ខ្ញុំសូមដកស្រង់ពីឯកសារដដែលនេះ ត្រង់ចំណុចទី៣ "ទន្ទឹមនឹងការប្រមូលកម្លាំងនៅតំបន់ជិតៗ ស្នើឲ្យយកកម្លាំងខ្លះពីខាងស្ទឹងត្រែង ឬខាងពន្លងដែរ ដើម្បីទៅត្រៀមវាយវាដែរ។ កម្លាំងនេះអាចឲ្យទៅបណ្តើរៗ"។ សេចក្តីសន្និដ្ឋានរួមរបស់គណៈមជ្ឈិមនៅក្នុងចំណុចទី៦ នៃលិខិតនេះបានបង្ហាញ ខ្ញុំសូមដកស្រង់ "ទស្សនៈយើងគឺ ១) ត្រៀមកម្លាំងយោធា ដោយយកកម្លាំងយោធាដែលនៅក្នុងមូលដ្ឋានជាសំខាន់បំផុត ទាំងកម្លាំងភាគ តំបន់ និងស្រុក ឯកម្លាំងពីក្រោមទាល់តែយូរបន្តិច។ ២) ក្តាប់សភាពការណ៍ខ្មាំងឲ្យច្បាស់ថែម។ ៣) ពិនិត្យលទ្ធភាពទាក់ទងពួកអាមេបា ដើម្បីតវ៉ាផ្លូវនយោបាយយ៉ាងម៉េចបាន"។ នៅខាងក្រោមបំផុតនៃលិខិតនេះបានបញ្ជាក់ ខ្ញុំសូមដកស្រង់ "បន្ថែមជូនអំពីប្រជាជនថ្មី យើងខ្ញុំបានទទួលអំពីទូរលេខ គឺព្រឹកនេះ ប៉ុន្តែចាំមានមតិពេលក្រោយ"។

[១០:១៣:៤៩]

ឯកសារបន្ទាប់មកទៀត ជាឯកសារដែលមានលេខ E3/241 វាជាទូរលេខលេខ៥២ ដែលផ្ញើចេញពីភូមិភាគឧត្តរថ្មី គឺភូមិភាគ៨០១ ដែលមានលេខាភូមិភាគឈ្មោះ សែ ផ្ញើជូនមន្ទីរ៨៧០។ ទម្រង់ទូទៅនៃទូរលេខនេះមានដូចជា ចំណុចទី១ បង្ហាញអំពីសភាពការណ៍ខ្មាំង ពោលគឺត្រង់ ERN ជាភាសាខ្មែរ 00020908, ERN ជាភាសាអង់គ្លេសគឺ 00183627, ERN ជាភាសាបារាំងគឺ 00335192។ ខ្ញុំសូមដកស្រង់ "ខ្មាំងខាងក្នុង ក្នុងរយៈប៉ុន្មានថ្ងៃនេះ យើងបានរកឃើញខ្មាំងបង្កប់ក្នុងជួរ និងក្នុងប្រជាជនជាបន្តបន្ទាប់ ហើយចាប់បានអាខ្មាំងទាំងនោះជាបន្តបន្ទាប់។ យើងម្ចាស់លើខ្មាំង ហើយមានវិធានការទាន់ពេលវេលា គ្មានបណ្តែតបណ្តោយឲ្យប្រែប្រួលអ្វីទេ នៅជាធម្មតា។ ១) វិធានការ យើងបន្តបោសសម្អាត និងប្រុងប្រយ័ត្នខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងទាំងនោះជាបន្តបន្ទាប់"។ ទូរលេខដដែលនេះ ត្រង់ចំណុច២ និយាយអំពីសភាពការណ៍ប្រជាជន និងចំណុច៣ និយាយអំពីសភាពការណ៍បង្កបង្កើនផលដើម្បីរាយការណ៍ជូនគណៈមជ្ឈិមជាព័ត៌មាន។

[១០:១៥:៣៧]

ទូរលេខមួយទៀត គឺទូរលេខលេខ៥៣ ដែលមានលេខឯកសារ E3/1091 ជាទូរលេខរបស់លេខាភូមិភាគ៨០១ ឈ្មោះ សែ ដដែល។ ខ្ញុំសូមដកស្រង់ "គោរពជូនគណៈ៨៧០ ជាទីគោរពស្នេហា និងរឭក តាមការសម្រេចរបស់បក្ស បានឲ្យខ្ញុំទៅធ្វើការនៅតំបន់១០៣ មួយរយៈនោះ ខ្ញុំរាយការណ៍ -- សូមរាយការណ៍ជូនដូចខាងក្រោម៖ ខ្ញុំបានទៅធ្វើការក្នុងរយៈពេល១០ថ្ងៃ ចុះទៅធ្វើការបានប្រាំស្រុក គឺស្រុកត្បែង ស្រុកគូលេន ស្រុកមង្គលថ្មី ស្រុករវៀង ស្រុកជាំខ្សាន្ត ហើយបានបើកធ្វើសន្និបាតតាមស្រុកនីមួយៗ ក្នុងសន្និបាតនោះ មានគណៈស្រុក មានទាំងគណៈសហគមន៍ មានមន្ទីរនានាក្នុងស្រុកចូលរួមផង។ សន្និបាតនោះ បានឧទ្ទេសនាមផ្សព្វផ្សាយមាគ៌ារបស់បក្សដូចតទៅនេះ ១) មាគ៌ានយោបាយបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ ២) មាគ៌ាបង្កបង្កើតផលរបស់បក្ស និងដោះស្រាយជីវភាពរបស់ប្រជាជន។ ៣) របៀបរបបធ្វើការងាររបស់បក្សប្រជាធិបតេយ្យប្រមូលផ្តុំ សមូហភាពដឹកនាំ"។ ទូរលេខនេះគឺបានធ្វើឡើងនៅថ្ងៃទី២៣ ខែ៨ ឆ្នាំ៧៧ ចេញពីភូមិភាគ៨០១ ឈ្មោះ សែ ហើយបានទទួលថ្ងៃទី២៥ ខែ៨ ឆ្នាំ៧៧ ម៉ោង២១:៥០ នាទី។

[១០:១៧:៣២]

ទូរលេខមួយទៀតរបស់ភូមិភាគ៨០១ ដដែល ដើម្បីរាយការណ៍ទៅគណៈ៨៧០ ជាទូរលេខលេខ៦០ ដែលមានឯកសារគឺ E3/1144។ ទម្រង់ទូទៅនៃទូលេខនេះគឺចាប់ផ្តើមឡើងដោយ លេខ I អំពីស្ថានភាពខ្មាំងខាងក្រៅ។ ចំណុចទី៥ ក្នុងលេខ I នេះគឺរាយការណ៍ពីស្ថានភាពខ្មាំងខាងក្នុង។

ពាក់ព័ន្ធទៅនឹងការរាយការណ៍នេះដែរ ខ្ញុំសូមដកស្រង់ "នៅតាមមូលដ្ឋាន នៅតាមមន្ទីរក្រសួង និងយោធា យើងបានរកឃើញខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជាបន្តបន្ទាប់ ទាំងការតាមដានសកម្មភាពក្បត់ប្រឆាំងបដិវត្តន៍ ទាំងតាមចម្លើយ។ ឯពួកខ្មាំងជាវរជ្ជការ និងប៉ូលិស ទាហានចាស់ យើងបានរកឃើញជាបន្តបន្ទាប់។ ចំពោះខ្មាំងស៊ីរូងផ្ទៃក្នុង បើប្រៀបធៀបពីមុន ឥឡូវយើងកាន់ថមថយចុះបណ្តើរៗ ហើយ។ ចំពោះខ្មាំងបង្កប់ស៊ីរូងមាននៅសល់ដែរ តែវាតិចតួច។ តទៅទៀតជាវិធានការ យើងបានបន្តសម្អាតខ្មាំងទាំងនោះជាបន្តបន្ទាប់។ ដំណើរការក្នុងការចលនាប្រយុទ្ធគ្រប់ផ្នែក ពិសេសនយោបាយបង្កបង្កើនផល ជាគន្លឹះដើម្បីរកខ្មាំង គឺរកក្នុងសមរភូមិប្រយុទ្ធ សម្រិតសម្រាំង និងបោសសម្អាត"។

[១០:១៩:២១]

ជាទម្រង់ដែលគួរឲ្យកត់សម្គាល់មួយដែរ គឺផ្នែកទី II នៃទូរលេខនេះគឺរាយការណ៍អំពីសភាព

ការណ៍ប្រជាជន។ ហើយផ្នែកទី III នៃទូរលេខពាក់ព័ន្ធទៅនឹងសកម្មភាពឃោធា។ ផ្នែកទីIV បានរាយការណ៍លម្អិតអំពីសកម្មភាពបង្កបង្កើនផលគ្រប់ស្រុកទាំងអស់ ទូទាំងភូមិ និងផ្នែកទីV អំពីជីវភាពប្រជាជន។

ចំណែកឯខាងក្រោមបង្អស់នៃទូរលេខបានបញ្ជាក់ថា "ឈ្មោះ សែ លេខាភូមិភាគ៨០១ ថ្ងៃទទួលគឺ ០៦ ខែ៩ ៧៧ ម៉ោងដែលទទួលគឺ ម៉ោង ប្រាំពីរព្រឹក និងមានបញ្ជាក់ផងដែរថា បានចម្លងជូនអ៊ំ អ៊ំនួន, បងវ៉ាន់, បង់វន, បងខៀវ, មន្ទីរ ឯកសារ"។ ឯកសារមួយទៀត ក៏ជាទូរលេខរបស់លេខាភូមិភាគ៨០១ ផងដែរ គឺលេខា សមមិត្តសែ។ ទូរលេខនេះ គឺមានលេខ៣២៤ ដែលលេខឯកសារ E3/1073 ទូរលេខនេះចាប់ផ្ដើមគឺ "គោរពជូនគណៈ៨៧០ ជាទីស្នេហា" ត្រង់ ERN ជាភាសាខ្មែរគឺ 00284274 និងERN ជាភាសាអង់គ្លេសគឺ 00293359, ERN ជាភាសាបារាំងគឺ 00630816 ដល់ 17។ ត្រង់ចំណុចទី៣ ខ្ញុំសូមដកស្រង់ "សភាពការណ៍ខ្មាំងខាងក្នុង គ្មានអ្វីប្រែប្រួលធំដុំអីទេ ជាសភាពធម្មតា។ យើងកំពុងបន្តបោសសម្អាត ពួកអានៅសេសល់ជាបន្តបន្ទាប់ ដែលវាផ្ទៀតប្រឆាំងបដិវត្តយើងទាំងចំហក្ដី ទាំងដោយសម្ងាត់ក្ដី"។ ចុះមកក្រោមបន្តិច "យើងដំណើរការបានល្អ ខ្មាំងវាងើបក្បាលឡើងវិញមិនរួច ក៏មកពីកម្លាំងប្រជាជនខ្លាំង ហើយកម្លាំងនេះសង្កត់វាជាប់ និងបោសសម្អាត សម្រិតសម្រាំងវាដាច់ (សូមទោស) វាជាប់"។ ចុះក្រោមបន្តិចដែរ ដកស្រង់ "សូមបញ្ជាក់និងជូនពត៏មានពីនារី ស៊ុន ប្រពន្ធសមមិត្ត ម៉ាន។ នារីនេះ ខ្មាំងឆ្លើយដាក់ច្រើន ខ្ញុំសម្រេចដកនារីនេះឲ្យមកសម្រាកនៅមន្ទីរភូមិភាគ៨០១ ដើម្បីទប់ទល់កុំឲ្យនារី នេះបន្តសកម្មភាពក្បត់តទៅទៀត"។

[១០:២២:៥៤]

ឯកសារដែលនាងខ្ញុំនឹងបង្ហាញចុងក្រោយ គឺជាឯកសារចម្លើយដែលនេះ ធ្វើឡើងដោយលេខាភូមិភាគ៨០១ ដដែល គឺលេខាឈ្មោះ សែ –សមមិត្តសែ– បានបង្ហាញទៅដល់គណៈ៨៧០។ ខ្ញុំសូមដកស្រង់ "សូមគោរពគណៈ៨៧០ ជាទីស្នេហា ខ្ញុំសូមជូនឯកសារចម្លើយរបស់ឈ្មោះ ១.សាន់ អ៊ាប ហៅ ឃុន ពាណិជ្ជកម្ម១០៣" ចុះមកក្រោមបន្តិច "ដើម្បីគណៈពិនិត្យ ហើយនិងជាឯកសារស្រាវជ្រាវខ្សែក្បត់បង្កប់ស៊ីរូងផ្ទៃក្នុង។ ៨០១ សែ"។ លេខាភូមិភាគ៨០១ សមមិត្តសែ បានផ្ញើឯកសារចម្លើយនេះទៅឲ្យគណៈ៨៧០ ហើយនៅឯកសារបន្ទាប់គឺ E3/801 ដែលមាន ERN ជាភាសាខ្មែរគឺ 00017183, (ដែលសូមអភ័យទោសផងដែរ ដែលខ្ញុំពុំមាន ERN ជាភាសាអង់គ្លេស និងបារាំង) នេះបានភ្ជាប់ជាឯកសារពីគណៈ ពីលេខាភូមិភាគឈ្មោះសែ ផ្ញើជាចម្លើយឲ្យសារភាពរបស់ សាន់ អ៊ាប ហៅ ឃុន

ទៅដល់គណៈអចិន្ត្រៃយ៍។

ខ្ញុំសូមបញ្ចប់ការងារធ្វើបទបង្ហាញពីភស្តុតាងជាឯកសារ ហើយសូមផ្តល់ វេទិកាបន្តនេះទៅដល់សភាតារបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។

[១០:២៥:១៤]

**លោក ឃីត វេយ៉ន័រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ យើងខ្ញុំនឹងពិនិត្យមើលនៅការប្រាស្រ័យទាក់ទងទាក់ទងទៅនឹងភូមិភាគព្ាយ៍សាន។ ទំនាក់ទំនងមកពីភូមិភាគព្ាយ៍សានមកមជ្ឈិមបក្ស ប្រហែលជាមានប្រយោជន៍ដល់តុលាការ ហើយយើងសូមពិនិត្យមើលផែនទី ហើយនិងសូមជូនទៅភាគីនៅដំណាក់កាល នៅភូមិភាគព្ាយ៍សាននេះ យើងពិនិត្យឃើញថា នៅក្នុងខាងស្តាំដៃផ្នែកខាងលើនៃផែនទីភូមិភាគនេះគឺបង្ហាញពីសញ្ញាពណ៌លឿង ហើយតំបន់១០១, ១០២, ១០៤ ហើយនិងតំបន់ ១០៧។ ដូច្នេះ ភូមិភាគព្ាយ៍សាន ជាឯកសារទី១ គឺ E3/1122 នេះជាឯកសារទូរលេខមកពី វី ជាលេខាភូមិភាគព្ាយ៍សានជូនទៅមជ្ឈិមបក្ស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៨ ហើយជូនថា "បងជាទីគោរព"។ នេះជាទូរលេខរបស់តំបន់ ភូមិភាគទៅមជ្ឈិម។

[១០:២៦:៥០]

យើងឃើញពាក្យថា ទាក់ទងទៅនឹងស្ថានការណ៍នៅក្នុងស្រុក១០១ ហើយនៅក្នុងទី២ និយាយអំពីការរកឃើញខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ហើយមានយោងទៅរកនៅក្នុងស្ថានភាពទាក់ទងទៅនឹងអង្គរនៅតំបន់១០៤ ស្រូវនៅ១០១ ហើយនិង១០៧ ផងដែរ។ ហើយនៅក្នុងខាងក្រោមទំព័រនេះ គឺអ្នកទទួលសារទូរលេខនេះ ទាក់ទងទៅនឹងមជ្ឈិមបក្សនោះ។ ឯកសារបន្ទាប់ទាក់ទងទៅនឹងភូមិភាគនេះដែរ គឺ E3/319។ ដូច្នេះគ្នានេះដែរ នេះជាសារទូរលេខមកពីឈ្មោះ វី មកពីលេខាភូមិភាគព្ាយ៍សាន "ជូនបងជាទីគោរព" ទូរលេខនេះនិយាយអំពីខ្មាំង ស្ថានភាពខ្មាំងនៅក្នុង -- នៅតាមព្រំដែន។ លេខាភូមិភាគរាយការណ៍ទៅមជ្ឈិមបក្សរហូតទៅដល់ខាងក្រោមនៃឯកសារនេះ គឺបានភូមិភាគបញ្ជាក់ថា "នៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៨។ ខ្ញុំ គឺ វី គឺជាលេខាភូមិភាគព្ាយ៍សានបានចូលរួមការប្រជុំមួយដើម្បីស្តាប់ការប្រកាសរបស់បក្សដែលនិយាយអំពីថា ភូមិភាគទាំងអស់ត្រូវធ្វើការនៅក្នុងសហករណ៍ តំបន់ ហើយនិងមូលដ្ឋាន មជ្ឈិម ហើយនិយាយអំពីការទាក់ទងជាមួយយួន ហើយស្របទៅនឹងការណែនាំរបស់អង្គការយើងពង្រឹងគោលជំហររបស់យើងដើម្បីបោសសម្អាតផ្ទៃក្នុង ហើយតស៊ូប្រឆាំងនឹងយួនទាំងថ្ងៃទាំងយប់"។

នៅខាងក្រោយមនៃឯកសារនេះ ថ្ងៃនៃសារទូរលេខនេះ ហើយនិងអ្នកទទួលទូរលេខនៅមជ្ឈិមបក្ស។ នៅបន្ទាប់ទៀត ក៏ចេញមកពីភូមិភាគពៀសានដែរ ឯកសារ E3/943 ជាទូរលេខមកពី វីជាលេខាភូមិភាគពៀសានដូចគ្នា ជូនទៅមជ្ឈិមបក្ស។ ហើយដែលជូនបងជាទីគោរព ហើយយើងអាចឃើញថា គេនិយាយអំពីសភាពការណ៍នៃខ្មាំង។ ហើយអ្នកទទួលឯកសារនេះ គឺនៅខាងក្រោមទំព័រនេះ ឯកសារនេះដែរ។

[១០:២៩:៥៩]

ឥឡូវនេះ ខ្ញុំចូលទៅៗតំបន់ឯករាជ្យ១០៥ នៅក្នុងផែនទីនេះ គឺថាតំបន់ឯករាជ្យ១០៥ នេះនៅក្នុងពណ៌ខៀវ យើងមានខេត្តមណ្ឌលគិរី នៅក្នុងផ្នែក នៅក្នុងតំបន់នោះ ខាងក្រោមនោះ។

ឯកសារទី១ ចំពោះតំបន់នេះគឺ E3/1191។ នេះគឺជាសារទូរលេខដែលយើងមើលលេខ បាទតេឡេក្រាមនេះគឺលេខ 00 ហើយ "ជូន បងខឿន សមមិត្តជាទីស្រឡាញ់ ជាទីនឹករឭក" ហើយនិយាយថា គាត់អ្នកបញ្ជូនបានមកដល់តំបន់១០៥ នៅថ្ងៃទី១១ ខែតុលា គឺ១ថ្ងៃ មុនផ្ញើទូរលេខនេះ ហើយត្រូវបានប្តូរឈ្មោះ ហើយយើងឃើញថា នេះជាទូរលេខទី១ ចេញមក ដែលបញ្ជូននៅថ្ងៃទី១២ ខែតុលា ហើយបន្ថែមនោះគឺបានផ្ញើជូន បងខឿន ហើយចម្លងជូនបងនួន ហើយនិងមន្ទីរ ហើយនិងឯកសារ។

[១០:៣១:១២]

ហើយខ្ញុំចូលទៅដល់ឯកសារមួយទៀត គឺ E3/1192 "នៅថ្ងៃដដែល នៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦ អ្នកបញ្ជូនគឺចេញមកពីតំបន់១០៥"។ នៅខាងលើនៃទូរលេខនេះគឺ "ជូនបងនួន ជាទីស្នេហា និងរឭក យើងបានទទួលទូរលេខរបស់បងហើយ។ ទាំងខ្លឹមសារ ទាំងការណែនាំ យើងបានចាប់អារម្មណ៍ខ្លះៗដែរ។ ហើយយើងខ្ញុំបានចាត់តាំងក្រុមពាណិជ្ជកម្មមួយក្រុមប្រចាំក្រុងភ្នំពេញ សមមិត្តជួន ទទួល។ អំពីវិទ្យុទាក់ទងថា ខូចនេះ ជួសជុលបានវិញហើយ មិនបានជូនទេ ទុកប្រើ"។ ដូច្នេះនៅក្នុង នេះជារបាយការណ៍មកពីភូមិភាគ ជូនបងនួន អំពីការខូចទូរស័ព្ទ -- វិទ្យុទាក់ទងនោះ ជាពិសេសប្រាប់ថា វិទ្យុដែលខូចនោះ បានជួសជុលហើយ គឺត្រូវបានទុកប្រើ។ ហើយវិទ្យុថ្មីនោះ ត្រូវបានរក្សាទុក មិនបានប្រើប្រាស់ទេ។

[១០:៣២:៣៩]

ឥឡូវនេះខ្ញុំចូលទៅអំពីការទាក់ទង អំពីតំបន់ឯករាជ្យ៥០៥ ទៅមជ្ឈិមបក្ស។ ដូច្នេះ ខ្ញុំក៏នឹងសូមអនុញ្ញាតដើម្បីបង្ហាញលើផែនទីតំបន់ឯករាជ្យ៥០៥ នេះ ក៏នៅលើផែនទីពណ៌ខៀវ យើងមានខេត្តក្រចេះ

ដែលបង្ហាញនៅលើតំបន់ -- ភូមិភាគ៥០៥ នេះ។ ឯកសារមួយ ដែលគឺថា E3/257។ នេះក៏ជាសារទូរលេខចេញមកពី១ភូមិភាគ៥០៥ ជូនមជ្ឈិមបក្ស គឺចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧៧ ផ្ញើជូនមន្ទីរ ៨៧០ ជាទីស្នេហា។ យើងឃើញនៅខាងក្រោម ខាងក្រោមនៃតេលេក្រាមនេះ គឺអ្នកទទួលនៅ -- ដែលជាមជ្ឈិមបក្សជាអ្នកទទួលសារទូរលេខនេះ។ កម្មវត្ថុនៃសារទូរលេខនេះគឺតំបន់៥០៥ គឺនិយាយអំពីអ្នកដែលចូលមកក្នុងតំបន់ពិសេស។ ពេលនោះគឺគេបានស្នើទៅមជ្ឈិមបក្ស ដែលមានចែងនៅខាងក្រោមនៃសារទូរលេខនេះ ដែលនិយាយថា សំណូមពរ ពីភូមិភាគ៥០៥ នេះស្នើទៅមជ្ឈិមបក្ស "យើងខ្ញុំស្នើថា បើមានភ្ញៀវមកយើងខ្ញុំ សូមស្នើអង្គការផ្តល់ជូនដំណឹងមកខាងយើងខ្ញុំផង។ បើអាចទៅបាន ក៏ស្នើផ្តល់ព័ត៌មានជូនពីរបបភ្ញៀវដែលមកនោះផង"។

[១០:៣៤:៤៤]

ឥឡូវនេះ ខ្ញុំសូមចូលទៅខាងមុខទៀត ដើម្បីពិនិត្យមើលការទំនាក់ទំនងមកពីភូមិភាគបូព៌ា ទៅគណៈមជ្ឈិមបក្ស។ យើងមើលនៅលើផែនទី យើងឃើញភូមិភាគបូព៌ាមានពណ៌ខៀវ ហើយយើងឃើញតំបន់នៅក្នុងភូមិភាគបូព៌ាហ្នឹងគឺមានតំបន់២០, ២១, ២២ និង ២៣ និង ២៤ មួយទៀត។ ឯកសារទី១ គឺ E3/879 គឺជាសារទូរលេខចុះថ្ងៃទី១១ ខែ១១ ឆ្នាំ១៩៧៥ នេះជាសារទូរលេខចេញមកពី ឆុន, សោ ភឹម ជាលេខាភូមិភាគបូព៌ា ហើយជូនបងប៉ុល។ ដែលមានចំណងជើងថា "ជូនបងប៉ុល ជាទីគោរពស្នេហា សូមផ្តល់ជាយោបល់។ ស្នើសុំជូនរាយការណ៍បង អំពីរបាយការណ៍ព្រំដែនតាមសេចក្តីរាយការណ៍របស់តំបន់២៣ មានដូច--" អ៊ីចឹងគឺតំបន់២៣ បញ្ជូនទៅភូមិភាគដែលមាន សោ ភឹម ហើយនិង ឆុន ហើយនិងថាគឺអាចនឹងផ្ញើជូនតាមគំនិតនេះ គឺតាមទៅសមមិត្ត ទៅបងប៉ុល។ នៅក្នុងរបាយការណ៍មកពីភូមិភាគនេះគឺមាននិយាយ -- ចម្លងតាមរបាយការណ៍របស់តំបន់ គឺនិយាយពីសភាពការណ៍នៅក្នុងស្រុក នៅក្នុងភូមិភាគបូព៌ាជាពិសេសនៅក្នុងស្រុកចន្ទ្រា ហើយនិងស្រុករមាសហែក។ បន្ទាប់មកនៅក្នុងភូមិនេះគឺឯកសារ E3/871 នេះក៏ជាសារទូរលេខចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៦ នេះផ្ញើមកពីលេខាភូមិភាគបូព៌ាមាន ឆុន, មាន សោ ភឹម ជូនមជ្ឈិមបក្ស។

[១០:៣៧:២៣]

ហើយ "ផ្ញើជូនបងប៉ុល ជាទីគោរពស្នេហា និងនឹករឮក" សារទូរលេខនេះក៏បាននិយាយផងដែរអំពីរបាយការណ៍ជូនមជ្ឈិមបក្ស អនុលោមទៅតាមរបាយការណ៍របស់ ឈូក នៅតំបន់២៤ ដែលថា ឈូក បានផ្ញើរបាយការណ៍ទៅលេខាភូមិភាគបូព៌ា ហើយលេខាភូមិភាគបូព៌ាពឹងផ្អែកលើព័ត៌មាននេះមក

ពីតំបន់របស់ខ្លួន ហើយក៏ភូមិភាគក៏រាយការណ៍មកមជ្ឈិមបក្ស។ ហើយឯកសារនេះគឺអំពីការ "គប់គ្រាប់បែក ពីហេតុការណ៍គប់គ្រាប់បែកទាក់ទងនឹងការ -- អ្នកគប់គ្រាប់បែកហ្នឹង យើងបានវាយជននោះនៅក្នុងការសួរចម្លើយអំពីស្វែងរកបណ្តាញរបស់គេ ហើយនិងចាប់បាន២៤នាក់នៅក្នុងមូលដ្ឋាន"។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី! លោកមេធាវីការពារក្តីលោក ខៀវ សំផន។

[១០:៣៨:៤៤]

**លោក អាកទូរ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំសូមធ្វើការកត់សម្គាល់មួយគឺពីព្រោះថា ខ្ញុំយល់ឃើញថា អម្បាញ់មិញនេះ សហភាតារបស់ខ្ញុំនិយាយអំពីមជ្ឈិមបក្ស វាជាពាក្យដែលគាត់បង្កើតដោយខ្លួនឯងទេ ព្រោះថាមិនមាននៅក្នុងឯកសារនោះទេ។ ដូច្នេះ ត្រង់ចំណុចនេះត្រូវតែបំភ្លឺ តេឡេក្រាមដែលនិយាយ -- ដែលសហព្រះរាជអាជ្ញាបានលើកឡើងនេះមិនៗសំដៅទៅមជ្ឈិមបក្សនោះទេ។ ឧទាហរណ៍ដូចជាតេឡេក្រាមដែលគាត់កំពុងនិយាយនេះ គឺថាផ្ញើជូនទៅ ប៉ុល ពត វិញនោះទេ។ ដូច្នេះយើងត្រូវតែបញ្ជាក់ថា តើវាជាតេឡេក្រាមនិយាយពីមជ្ឈិមបក្ស ឬក៏អត់ទេ។ អ៊ីចឹងត្រូវតែបំភ្លឺចំណុចនេះ ពីព្រោះថាមើលឃើញថាគាត់កំពុងតែបង្ហាញឯកសារទៅសាធារណជន ដែលមានលក្ខណៈមិនត្រឹមត្រូវ។ ហេតុដូច្នេះ សូមអង្គជំនុំជម្រះជួយបំភ្លឺចំណុចនេះលោកប្រធាន។

[១០:៣៩:៤៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន លោកស្រីចៅក្រម ខ្ញុំៗនឹងយោងទៅលើអ្នកទទួលឯកសារ ដោយលើកឡើងចំៗតែម្តង ដោយសារតែពេលវេលា ខ្ញុំមានឯកសារពីរទៀតដែលត្រូវបង្ហាញនិយាយអំពីប្រព័ន្ធទាក់ទងពីភូមិភាគបូព៌ានេះ។ ថាតើពេលនេះវាសមស្របល្មមនឹងឈប់សម្រាកហើយឬនៅ លោកប្រធាន ឬក៏ខ្ញុំអាចបន្តទៅមុខទៀត?

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះមានការតវ៉ាជំទាស់ទៅលើការបង្ហាញឯកសាររបស់លោក ដោយមេធាវីអន្តរ-

ជាតិការពារក្ដីលោក ខៀវ សំផន។ តើលោកមានមតិយោបល់អ្វីទេ លើការកត់សម្គាល់អម្បាញ់មិញនេះរបស់លោកមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន?

[១០:៤១:២០]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធានខ្ញុំសូមឆ្លើយបំភ្លឺ ខ្ញុំសូមជំទាស់ចំពោះអ្វីដែលមេធាវីការពារក្ដីលើកឡើង។ ខ្ញុំនឹងមិនប្រើពាក្យថា "មជ្ឈិមបក្ស" ទៀតទេ។ ប៉ុន្តែខ្ញុំយល់ស្របជាមួយការជំទាស់របស់ខាងមេធាវីការពារក្ដី ខ្ញុំឈប់ប្រើថា "មជ្ឈិមបក្ស" តទៀតហើយ ប្រើឲ្យចំៗតែម្ដង។ ថាតើការឆ្លើយបំភ្លឺរបស់ខ្ញុំនេះច្បាស់លាស់ហើយឬនៅ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាស២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤២ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។

សូមអញ្ជើញ!

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ ឯកសារចុងក្រោយដែលខ្ញុំត្រូវបង្ហាញ សូមបង្ហាញជូនគឺ E3/871 ឯកសារនេះគឺគ្របដណ្ដប់ទៅលើសារទូរលេខ ហើយខ្ញុំសូមចូលទៅសារទូរលេខមកពីភូមិភាគបូព៌ាមួយ

ទៀត គឺសារទូរលេខ E3/892។ នេះជាសារទូរលេខផ្ញើជូនៗ បងហែម ដាក់ក្នុងវង់ក្រចកថា (ម៨៧០) ហើយនៅខាងក្រោមនៃឯកសារនេះ គឺជាឯកសារផ្ញើជូនមកពីឈ្មោះ ផុន ឬ សោ ភឹម ជាលេខាភូមិភាគបូព៌ា ដែលបានរាយការណ៍មកមន្ទីរ៨៧០។

នៅផ្នែកខាងលើនៃសារទូរលេខនេះគឺមេភូមិភាគបានថា "យើងខ្ញុំសូមផ្ញើជូនអំពីស្ថានភាពនៅតំបន់២៣"។ បើសិនណាជាយើងមើលឃើញទៅ មើលទៅលើផែនទីគឺ តំបន់២៣ នេះ គឺមាននៅលើផែនទី។ សារទូរលេខនេះ និយាយអំពីការចាប់បានពួកវៀតណាម ហើយនៅខាងក្រោមនៃទំព័រសារទូរលេខនេះគឺមេភូមិភាគផ្ញើជូនមកមន្ទីរ៨៧០ ដោយលើកឡើងថា "យើងខ្ញុំសូមស្នើមតិចង់ដឹងថា តើមន្ទីរ -- យើងខ្ញុំសូមស្នើមតិរបស់មន្ទីរ៨៧០ អំពីបញ្ហា យួន ដែលយើងចាប់បាននៅភូមិតាដេវ នៅលើផ្ទះប្រជាជន។ បើមន្ទីរ៨៧០ ត្រូវការ យើងខ្ញុំនឹងផ្ញើជូន ផ្ញើមកជូន។ បច្ចុប្បន្ន យើងរក្សាទុកកំពុងសួរយកចម្លើយ។ យើងខ្ញុំសូមជម្រាបដំណឹងប៉ុណ្ណោះសិន"។

[១១:០៤:៥៣]

ខ្ញុំសូមចូលទៅភូមិភាគនិរតីម្តង។ បើ -- សូមបង្ហាញនូវផែនទី ដើម្បីបង្ហាញឲ្យច្បាស់ថាភូមិភាគនិរតីនេះ គឺក៏មាននៅលើផែនទីនេះដែរ។ ក្នុងនោះមានតំបន់១១៣, តំបន់៣៣, តំបន់៣៥ ការប្រាស្រ័យទាក់ទងប្រព័ន្ធប្រាស្រ័យទាក់ទងពីភូមិភាគនិរតី គឺឯកសារ E3/769។ នេះជារបាយការណ៍ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៧ ជារបាយ ការណ៍មកពីភូមិភាគនិរតី ផ្ញើជូនអង្គការជាទីនឹករឭក និងជាទីស្រឡាញ់។ ទំព័រដំបូងនេះ គឺERN ជាភាសាខ្មែរ 0005285 (ស៊ីក) ទៅដល់8256។ របាយការណ៍នេះ គឺលើកឡើងអំពីបញ្ហាមួយចំនួនដែលអង្គជំនុំជម្រះបានជ្រាប គឺរាយការណ៍អំពីសភាពការណ៍ការការពារប្រទេស សភាពការណ៍សេដ្ឋកិច្ច។ ហើយនៅផ្នែកនៃសភាពការណ៍ការការពារប្រទេសនេះ គឺសកម្មភាពខ្មាំងពីខាងក្រៅ។ និយាយអំពីសកម្មភាពខ្មាំងពីខាងក្រៅ។ ហើយនៅទំព័រទី១ នេះដែរ និយាយអំពីសកម្មភាពនៅខាងក្នុងប្រទេស ហើយភូមិភាគបានរាយការណ៍ថា នៅតំបន់៣៣ ខ្មាំងបានធ្វើសកម្មភាពដោយដុតនូវៗ ដុតចោលស្រូវ។

[១១:០៧:០១]

ហើយកថាខណ្ឌបន្ទាប់នោះ និយាយថា ចម្លើយសារភាពរបស់ពួកខ្មាំងដែលបានចាប់បាននៅតាកែវ និងនៅខេត្តកំពត ហើយខ្មាំងបានបង្កើតបណ្តាញរបស់ពួកគេនៅក្នុងជួរពួកនីរសារ។ ហើយនៅខាងក្រោមនៃទំព័រនេះ ក៏និយាយអំពីកម្មវត្ថុតែមួយដែរ។ សូមដកស្រង់ "មួយរយៈកន្លងមកយើងចាប់

បានខ្មាំងជោគជ័យ ខ្មាំងដែលបានធ្វើសកម្មភាពដូចរៀបរាប់ខាងលើ"។

ខ្ញុំសូមចូលទៅដល់ភូមិភាគពាយ័ព្យវិញម្តង គឺភូមិភាគពាយ័ព្យនេះ មានពណ៌ខៀវ នៅលើផែនទីនេះ ហើយតំបន់នេះ មានតំបន់ទាំងឡាយនៅក្នុងភូមិភាគនេះ មានតំបន់ ១, ២, ៣, ៤, ៥, ៦ និងតំបន់៧។--

[១១:០៨:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក អាកទូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធានបាទ។ ខ្ញុំមិនធ្វើការជំទាស់អីទេ គ្រាន់តែចង់ប្រាប់ថា តេឡេក្រាមទី១ ដែលសហភាតាខ្ញុំលើកឡើងនេះ គឺថាប្រហែលជាមានកំហុសជាភាសាបារាំង និងជាភាសាខ្មែរ មានការបកប្រែថា "ទូរលេខនេះផ្ញើជូនទៅបងហែម" ប្រហែលជាៗបញ្ហាបកប្រែហើយប្រហែលជាបញ្ហាបងហែម មន្ទីរ៨៧០ ហើយតាមពិតទៅក្នុងទូរលេខនេះ មិនមែននិយាយយ៉ាងដូច្នេះទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១១:០៩:០២]

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ ដូចខ្ញុំបានជម្រាប គឺខ្ញុំសូមចូលទៅៗភូមិភាគបស្ចិមវិញម្តង ហើយឯកសារទី១ ដែលសូមបង្ហាញ E3/1094។ នេះជារបាយការណ៍មួយវែង ជារបាយការណ៍ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ ជារបាយការណ៍មកពីភូមិភាគបស្ចិម ផ្ញើជូនអង្គការជាទីគោរពស្នេហា និងរឭក។ ហើយយើងឃើញនៅខាងក្រោមមានពាក្យថា "យើងខ្ញុំសូមធ្វើសេចក្តីរាយការណ៍ប្រចាំខែជូនអង្គការ ជារបាយការណ៍ប្រចាំខែមកពីភូមិភាគបស្ចិម ផ្ញើជូនមកអង្គការ"។ ហើយក្នុងនោះគឺមានចំណងជើងតូចៗនិយាយអំពីសភាពការណ៍ការពារប្រទេស ខ្មាំងខាងក្រៅ ហើយនៅទំព័រទី១ ដដែល គឺនិយាយអំពីសកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង។ សូមដកស្រង់ "ពិនិត្យជារួមសកម្មភាពខ្មាំងស៊ីរូងផ្ទៃក្នុងរយៈពេល១ខែនេះ វាធ្វើសកម្មភាពបំផុសខែជំទាស់ វាយប្រហារប្រឆាំង។ ហើយខាងក្រោមមកនិយាយថា "ហើយ

ខ្មាំងទាំងអស់នេះ គឺយើងត្រូវបានចាត់វិធានការដកហូត សម្រិតសម្រាំង និងបោសសម្អាតជាបន្តបន្ទាប់ពីគ្រប់អង្គភាពទាំងអស់។ ក្នុងនោះរួមមានតាំងពីអតីតមន្ត្រីរដ្ឋការ ជាអ្នករដ្ឋការចាស់ និងអនិកជនចិន និងយួន មួយចំនួន"។ ហើយឃ្លាមួយចំនួនខាងក្រោមនេះ សូមដកស្រង់ "ប៉ុន្តែនៅសកម្មភាពខ្មាំងខាងលើនេះ វាធ្វើអ្វីយើងពុំបានជាធំដុំទេ។ ហើយយើងបានបោសសម្អាត ដកហូត សម្រិតសម្រាំង បោសសម្អាតជាបន្តបន្ទាប់"។

[១១:១១:៥៤]

ហើយចំណាងជើងនៅក្នុងទំព័រដដែលនេះ និយាយអំពីមន្ទីរជុំវិញភូមិភាគ។ "ខាងរោងចក្រខ្មាំងវាបំផុសប្រជាជនថា បំផុសយុវជន យុវនារី ថាបើស្រឡាញ់ឪពុកម្ដាយ កុំយកគ្រួសារជាកម្មាភិបាល"។ ម្យ៉ាងទៀតថា "សុខចិត្តងាប់ មិនយកគ្រួសារជាកម្មាភិបាលទេ។ នៅក្នុងអង្គភាពជាសំណង់ធ្វើផ្ទះ មានមនុស្សចូលលួចកង់ក្នុងពេលយប់ ហើយមិនទាន់រកមុខឃើញនៅឡើយទេ"។ ហើយនៅខាងក្រោមនេះ ERN ជាភាសាខ្មែរ 00143605 និងនៅទំព័របន្ទាប់ផងដែរ។ ក្នុងនេះគឺក៏ភូមិភាគបានរាយការណ៍មកជូនអង្គការ គឺរាយការណ៍អំពីតំបន់កំពង់ឆ្នាំង "សកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដោយសារវាជាប់ពាក់ព័ន្ធទៅនឹងតំបន់នេះតែម្ដង"។

ដោយសារតែពេលវេលាពាក់ព័ន្ធទៅនឹងការបង្ហាញនូវឯកសារនេះ យើងខ្ញុំសូមអនុញ្ញាតបន្តទៅទំព័រខ្មែរERN ជាភាសាខ្មែរ 00143607, ជាភាសាបារាំង 00593526 ដល់ 27, ERN ជាភាសាអង់គ្លេស 00315371។ នៅទំព័រនេះ យើងមានប្រធានបទទី២ និយាយអំពីខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងនៅស្រុកឧដុង្គ និងនិយាយអំពីការចាប់ខ្លួនខ្មាំងនៅក្នុងស្រុកនេះ។ ហើយបន្ទាប់មករបាយការណ៍នេះបាននិយាយអំពីសហករណ៍ ដែលមានបុរសម្នាក់គាត់ចង់ធ្វើអត្តឃាត។ ហើយទំព័របន្ទាប់នៃរបាយការណ៍នេះ គឺERN ភាសាខ្មែរ 00143607 ដល់ 08 គឺនិយាយទៅលើស្ត្រីម្នាក់ឈ្មោះៗ តាំង លី គឺនិយាយៗអំពីការរៀបការរបស់ -- ដោយបុរសម្នាក់រៀបការជាមួយស្ត្រីប្រាំនាក់។ ហើយដោយសារតែស្ត្រីទាំងប្រាំនាក់នេះ គឺថាត្រូវដូរតែថ្នាំតែមួយសំចុក។

[១១:១៥:២៣]

ហើយ ERN ជាភាសាខ្មែរនៅក្នុងឯកសារនេះដដែលគឺ ERN 00143609, ERN ជាភាសាបារាំង 00593528 ដល់ 29, ERN ជាភាសាអង់គ្លេស 00315373។ ទំព័រនេះនិយាយ -- មានចំណាងជើងនិយាយអំពី សកម្មភាពខាងសីលធម៌។ សូមដកស្រង់ "នៅតាមមូលដ្ឋានស្រុកនីមួយៗក៏នៅមាន

លេចសកម្មភាពនេះជាបន្តបន្ទាប់ដែរ រវាងយុវជនយុវនារី និងបុរសស្ត្រីមួយចំនួន ឬក៏បុរសមានគ្រួសារជាមួយយុវនារី។ ប៉ុន្តែនៅស្រុក២៧ នៅសហករណ៍តាសាល នៅថ្ងៃទី២១ ខែ៧ ៧៨ ឈ្មោះ សឿង ឈ្លបសហករណ៍តាសាល បានប្រព្រឹត្តក្បត់សីលធម៌ ដោយរំលោភទៅលើនារីមកពីតំបន់កោះកុង។ វិធានការបានយកឈ្មោះ សឿង នេះដាក់ការដ្ឋានអប់រំរបស់ស្រុកហើយ"។

ហើយទំព័របន្ទាប់ ERN ជាភាសាខ្មែរ 0014369 (ស៊ីក) ដល់ 10, ហើយ ERN ជាភាសាបារាំង 00593529 ដល់ 30, ហើយ ERN ជាភាសាអង់គ្លេស 00315374។ ចំណងជើងត្រង់ទំព័រនេះនិយាយអំពីសកម្មភាពបោសសម្អាត សមាសភាពមិនល្អនៅក្នុងអង្គភាពផ្សេងៗ ដោយយោងទៅលើតំបន់ខាងផ្នែកនេសាទត្រី។ ហើយនៅក្នុងនោះក៏មាននិយាយអំពីសកម្មភាពកសិកម្មតំបន់។ បានបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងចំនួនបួនក្បាល ដោយមានលើកទាំងឈ្មោះខ្មាំងទាំងនេះផង។ ហើយក្នុងនេះគឺៗ នៅក្នុងទំព័រជាភាសាខ្មែរក៏មានចំណងជើងអំពីតំបន់មួយដែរ និយាយអំពីសកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង។

[១១:១៨:២៣]

ហើយនៅទំព័រខ្មែរដដែលនេះ សូមដកស្រង់ "អំពីការសម្រិតសម្រាំងសមាសភាពយួន ភ្នាក់ងារ សេ.អ៊ី.អា និងសមាសភាពមិនល្អ។ ១) កម្ទេចជនជាតិយួនបាន១០០នាក់មានទាំងតូចទាំងធំ ទាំងចាស់ទាំងក្មេង។ ចំណុចទី២) កម្ទេចពួកបណ្ដាស័ក្តិនិងពួក សេ.អ៊ី.អា ៦០នាក់ ដែលជាពួកបណ្ដាស័ក្តិ និងជាពួក សេ.អ៊ី.អា របស់ចក្រពត្តិអាមេរិក ដែលនៅបង្កប់ក្នុងអង្គភាព និងសហករណ៍។ ៣) នៅក្នុងកងទ័ពតំបន់ សម្រិតសម្រាំងយុទ្ធជនចិន ដែលនៅក្នុងជួរកងទ័ពចំនួន ៤០នាក់ ដកទុកឲ្យបង្កើតផល។ ៤) យួនបីនាក់ជាយុទ្ធជនត្រូវបានចាត់វិធានការ។ ៥) មនុស្ស ១០នាក់ក៏ត្រូវបានសម្រិតសម្រាំងកងតូចកងធំ នៅក្នុងសហករណ៍។ សមាសភាពទាំងអស់នេះរួមមានអ្នកខ្ជិលធ្វើការ ខ្លះប្រឆាំងអង្គការ ខ្លះជេរស្តីដល់ប្រជាជន ខ្លះទៀត ជាប់ចម្លើយខ្មាំងច្រើន ហើយមិនព្រមធ្វើការ"។

[១១:២០:០០]

ហើយចំណងជើងទាក់ទងទៅនឹងផ្នែកនេះដែរ វិធានការយើងលើសកម្មភាពខ្មាំងខាងលើនេះ សូមដកស្រង់ "បន្តតាមដានស្រាវជ្រាវរកខ្សែខ្មាំងគ្រប់ប្រភេទ ដែលបង្កប់ស៊ីរូងផ្ទៃក្នុង ហើយបានបោសសម្អាតវាតទៅទៀត ឲ្យស្អាតដាច់ខាតពីក្នុងមូលដ្ឋាន អង្គភាព មន្ទីរ និងក្រសួងផ្សេងៗ"។ ហើយនៅក្នុងរបាយការណ៍នេះដដែល និយាយអំពីការអប់រំ ខ្ញុំសូមបង្ហាញជូន ERN ជាភាសាខ្មែរ 00143611

ដល់ 12, ERN ជាភាសាបារាំង 00593532 ហើយ ERN ជាភាសាអង់គ្លេស 00315376។ នេះជារបាយការណ៍របស់ភូមិភាគដែលមានចំណងជើងថា “ការកសាងកម្លាំងដឹកនាំរបស់បក្ស”។ ហើយចំណងជើងតូចបន្ទាប់គឺ “១) កសាងខាងនយោបាយសតិអារម្មណ៍”។

[១១:២១:៣១]

បាទ សូមដកស្រង់ “នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ យើងបានបើកវគ្គអប់រំរៀនសូត្រជារួម ឲ្យកម្មាភិបាល បក្ខជន គ្រប់តំបន់ទាំងអស់នៅក្នុងភូមិភាគ ចាប់តាំងពីសមាជិកតំបន់ គណៈស្រុក គណៈសហករណ៍ និងបក្ខជន។ ព្រមជាមួយនេះយើងបានបើកវគ្គរៀនសូត្រឲ្យអង្គការស្នូលជាទូទៅ ទាំងសមាជិកយុវកក ទាំងជនបង្គោល”។ សូមបិទការដកស្រង់។

ហើយយោងទៅលើឯកសារនេះផងដែរ ឯកសារអប់រំ បានយកឯកសារទាំងប្រាំពីររបស់បក្ស ដែលបក្សបានអប់រំដល់ពួកយើងខ្ញុំនៅក្នុងខែមិថុនា ក្នុងឆមាសទី១ ឆ្នាំ១៩៧៨ មករៀនសូត្រ ដោយដកយកចំណុចខ្លះដែលត្រូវរៀនសូត្រជាទូទៅ។ លទ្ធផលនៃការរៀនសូត្រឃើញថា កម្មាភិបាល បក្ខជន ព្រមទាំងអង្គការស្នូល បានយល់និងជ្រួតជ្រាបលើគ្រប់ឯកសារទាំងអស់ ជាពិសេសលើមាគ៌ាការពារប្រទេស ការបន្តធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមគ្រប់ផ្នែក។ ហើយបានយល់ច្បាស់នូវកត្តាសំខាន់ៗ គឺកសាងកម្លាំងដឹកនាំ និងជាពិសេសកម្ចាត់ខ្មាំងស៊ីរូងផ្ទៃក្នុង។

[១១:២៤:០៣]

ហើយចំណងជើងតូចលេខ២ នៅខាងក្រោមគឺ “ការកសាងខាងចាត់តាំង”។ សូមដកស្រង់ “ក្នុងពេលជាមួយគ្នានេះគឺ កម្មាភិបាល ក៏ដូចជាសមាជិកសហករណ៍ គឺថាត្រូវបានដកចេញ ហើយផ្ញើទៅកាន់មន្ទីរសន្តិសុខ។ ដោយសារតែពួកទាំងនេះគឺជាសមាសភាពមិនល្អ ដែលបានធ្វើសកម្មភាពរារាំង។ ពួកអ្នកទាំងនេះត្រូវបានយើងតាមដានជាយូរមកហើយ។ វាជាខ្សែសង្វាក់របស់ពួកអាក្បត់”។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំគ្រាន់តែចង្អុលបង្ហាញ តែខ្ញុំមិនលើកឡើងទេ ដែលថារបាយការណ៍នេះ គឺជារបាយការណ៍មកពីភូមិភាគ ដែលមានរហូតទៅដល់ប្រាំមួយ ឬប្រាំពីរទំព័រឯទៀតឯណោះ ដោយមានជាអង្គការលេខ និយាយអំពីតំបន់ផ្សេងៗ និងនិយាយអំពីការប្រកប -- បង្កបង្កើនផល។

[១១:២៥:៣៨]

ឯកសារបន្ទាប់មកពីភូមិភាគដដែលនេះ គឺឯកសារ E3/1092។ នេះគឺជារបាយការណ៍មកភូមិភាគ៧បស្ចិម ផ្ញើជូនទៅអង្គការ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨។ ភូមិភាគបានរាយការណ៍នៅផ្នែកខាងលើនៃទំព័រ "យើងខ្ញុំសូមស្នើរាយការណ៍ប្រចាំ១០ថ្ងៃ ជាលើកទី១ នៅថ្ងៃទី០១ ខែកក្កដា ៧៨ ជូនអង្គការមានដូចខាងក្រោមនេះ"។ ខ្ញុំសូមបង្ហាញ ERN ជាភាសាខ្មែរ 00143577 ទៅដល់ 78, ERN ជាភាសាបារាំង 00611447 ដល់ 48, ហើយ ERN ជាភាសាអង់គ្លេស 00289922។ នៅត្រង់ទំព័រនេះគឺមានចំណងជើង ដែលនិយាយអំពីប្រវត្តិរូបរបស់មនុស្សពីរនាក់ ៗត្រូវបានកំណត់មុខសញ្ញា ហើយចំណងជើងបន្ទាប់មកទៀត ចម្លើយរបស់ខ្មាំងទាំងពីរនាក់។ សូមដកស្រង់ "គឺមានខ្សែសង្វាក់ និងមានអ្នកដឹកនាំ ហើយក្នុងនោះក៏មានផ្នែកដៃជើងរបស់វាផ្សេងៗទៀត ដែលរៀបរាប់ឈ្មោះមនុស្សបី ១) ឈ្មោះ សឿន, ឈ្មោះមួយទៀត សុក, ខ្មាំងទាំងពីរនេះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខរួចហើយ"។ ហើយនៅត្រង់ទំព័រដដែលនេះ គឺមានចំណងជើងនិយាយអំពី ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងនៅក្នុងតំបន់៣១ មនុស្សពីរនាក់ត្រូវបានផ្ញើជូនទៅមន្ទីរអប់រំកែប្រែដែលយោងទៅលើតំបន់៣២។

[១១:២៨:១៤]

ខ្ញុំសូមចូលទៅទំព័រចុងក្រោយបំផុតនៃរបាយការណ៍មកពីភូមិភាគនេះ នៅឯកសារ E3/1092 ដដែល ខ្ញុំសូមធ្វើការយោងដូចតទៅ៖ "ទី១ និយាយអំពីការកសាងគ្រួសារ" នៅក្រោមចំណងជើងនេះគឺសូមដកស្រង់៖ "បាន១០គ្រួសារនៅក្នុងស្រុក២៦ តំបន់២២ (ស៊ីក) ឯតំបន់៣១ និង៣៧ ពុំបានឃើញរាយការណ៍លើបញ្ហានេះទេ"។ ហើយរបាយការណ៍នេះនិយាយអំពីការកសាងកម្មាភិបាលដឹកនាំ។ ហើយភូមិភាគបានលើកឡើងដូចតទៅនេះ សូមដកស្រង់ "យើងបានអប់រំកម្មាភិបាល បក្ខជន អង្គការស្នូល និងមហាជនចម្រើន បានហើយ បានខិតខំអប់រំពង្រឹងខាងគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងរបស់បក្សគ្រប់ផ្នែកឲ្យកាន់តែរឹងមាំ រឹងប៉ឹង ខ្លាំងក្លា មាំមួនថែមទៀត ព្រមជាមួយនេះ កម្មាភិបាលគ្រប់ថ្នាក់បានចុះជាប់ចលនាមហាជន នៅគ្រប់មុខសញ្ញានីមួយៗឲ្យកាន់តែជ្រាលជ្រៅថែមទៀត ដើម្បីក្ដាប់ចលនា និងពិនិត្យតាមដានប្រវត្តិរូប និងសកម្មភាពអ្នកដែលត្រៀមចូលបក្ស អង្គការស្នូល និងមហាជនចម្រើន។ យើងធ្វើយ៉ាងណាពង្រឹងជួរកម្មាភិបាលដឹកនាំរបស់បក្សឲ្យបានត្រឹមត្រូវតាមមាគ៌ារបស់បក្ស"។

[១១:៣០:៣៦]

ឥឡូវនេះ ខ្ញុំសូមចូលទៅដល់ភូមិភាគពាយ័ព្យទាក់ទងទៅនឹងផែនទីនេះដែរ។ ឯកសារទី១ គឺ

E3/1179។ នេះជារបាយការណ៍មកពីភូមិភាគពាយ័ព្យ មិនបាននិយាយច្បាស់ទេ គឺខាងលើគ្រាន់តែនិយាយថា "សេចក្តីរាយការណ៍"។ ហើយនិយាយថា របាយការណ៍ថ្ងៃទី២១ អ៎! ២៤ ខែឧសភា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៧៧។ ទី១ និយាយពីសភាពការណ៍ខ្មាំង ក) ខ្មាំងខាង -- បាទមានខ្មាំងខាងក្នុង ខ្មែរទំព័រ 00214271 ជាលេខ ERN។ មានការថែងទៅរកឧទាហរណ៍ហេតុការណ៍មួយនៅក្នុងនេះ គេបានចាប់កុមារម្នាក់មកសួរចម្លើយ ហើយយកទៅសម្លាប់ បន្ទាប់ពីវាយដល់ស្លាប់ហើយមុននឹងកប់កុមារនេះ។ អ្នកយកការណ៍បានវះពោះកុមារនោះ ដើម្បីយកថ្លើមយកមកហូប។

[១១:៣២:២២]

ដូចដែលរឿងក្តីនេះ ដូចដែលករណីនេះទាក់ទងជាមួយមនុស្សប្រាំមួយនាក់ដែរ យើងសម្រេចចិត្តចាប់មនុស្សអ្នកយកការណ៍ អ្នកបីនាក់ ហើយបានដាក់ឈ្លបស្ត្រីបីនាក់ ដើម្បីឃុំខ្លួនបណ្តោះអាសន្ន"។ បន្ទាប់មកមានខ្លឹមសារមួយនៅខាងក្រោមនោះទៀត ជាសេចក្តីសន្និដ្ឋាន "ខ្មាំងស៊ីរូងផ្ទៃក្នុង -- ខ្មាំងផ្ទៃក្នុង ខ្មាំងខាងក្រៅ បានបង្ហាញថា ខ្មាំងបានធ្វើសកម្មភាពទាំងគ្រប់រូបភាព ប៉ុន្តែមិនគួរឲ្យកត់សម្គាល់ទេ។ សកម្មភាពរបស់គេកើតមានគ្រប់ពេលវេលា ហើយខ្មាំងដែលយើងបានកំណត់មុខសញ្ញាហើយត្រូវបានចាប់ខ្លួន ហើយកម្ទេចចោលជាបន្តបន្ទាប់"។

ចំណុចមួយទៀត នៅក្នុងទូរលេខរបស់តំបន់នេះ គឺ E3/951។ ដូច្នេះនេះជាសារទូរលេខមកពីរស់ ញឹម ជាលេខាភូមិភាគជូនទៅអង្គការ៨៧០។ អ៊ីចឹងលេខាភូមិភាគនេះ បាននិយាយនៅក្នុងឃ្លាទី១ថា "សូមរាយការណ៍សភាពការណ៍ទូទៅ និងការងារនៅក្នុងភូមិភាគដូចតទៅនេះ" ហើយបានយោងទៅរកការប្រជុំជាមួយអង្គការនោះផងដែរ។ "ក្រោយពីខ្ញុំបានជួបជាមួយអង្គការត្រឡប់មកវិញបានចុះទៅធ្វើការខាងតំបន់៥, តំបន់៣, តំបន់១ និងតំបន់៤ រួចនៅថ្ងៃទី១០ ខែឧសភា នេះខ្ញុំជួបធ្វើការជាមួយសមមិត្ត ក្នុងគណៈកម្មការអចិន្ត្រៃយ៍ចាត់តាំងប្រចាំការ។ ក្នុងការជួបធ្វើការជាមួយគណៈអចិន្ត្រៃយ៍ខ្ញុំបានរាយការណ៍អំពីការណែនាំរបស់៨៧០ រួចហើយយើងបានពិនិត្យសភាពការណ៍ក្នុងភូមិភាគរបស់យើងដូចតទៅ" ហើយមានការយោងនៅក្នុងខាងក្រោមនេះ គឺការពិនិត្យខ្មាំងក្រៅ និងខ្មាំងក្នុង។

[១១:៣៥:០៥]

នៅក្នុងអត្ថបទភាសាខ្មែរ 00021043, បារាំង 00296221, អង់គ្លេស 11185216 ហើយនៅក្នុងនេះគឺនិយាយអំពីវិធានការ។ អ៊ីចឹងភូមិភាគនេះបាននិយាយពីវិធានការ។ សូមដកស្រង់ "ការពារឲ្យបានប្រុងប្រយ័ត្ន។ ប្រយុងប្រយ័ត្នឲ្យបានខ្ពស់ថែមទៀត ខ្មាំងយួន វាវាយកម្ទេចខ្មាំងឈ្លានពាន បោស

សម្អាតពួកសមាសភាពអន្តរាយជាបន្តបន្ទាប់តទៅទៀត ទល់ការរត់លូន។ ហើយនៅក្នុងឯកសារ E3/951 ដដែលនេះ ដែលមានចំណងជើងមួយនោះ "ការគ្រប់គ្រងការងារ ហើយនិងការកសាងកម្មាភិបាលសំខាន់ៗ"។

លេខាភូមិភាគ ញឹម បាននិយាយដូចខាងក្រោមនេះ៖ "ការពង្រឹង -- ខិតខំពង្រឹងតាមអង្គការណែនាំ ធ្វើការកម្ទេច ធ្វើម្តេចឲ្យកម្មាភិបាលភូមិភាគរឹងខ្លាំង កម្មាភិបាលតំបន់ខ្លាំង កម្មាភិបាលស្រុកខ្លាំង សហករណ៍ខ្លាំង កម្មាភិបាលណាមិនទទួលខុសត្រូវមិនស្មោះត្រង់ មិនចុះជាប់តាមដានក្នុងបដិវត្តន៍ទេ ត្រូវដោះស្រាយតាមមាគ៌ារបស់បក្ស"។ បន្ទាប់នេះទៅខាងក្រោម នៅក្នុងតេឡេក្រាមនេះ ញឹម បាននិយាយថា "សេចក្តីអស់តែប៉ុណ្ណេះ ស្នើអង្គការមានមតិសូមណែនាំថែម ដោយគោរពយ៉ាងខ្ពស់"។

ឥឡូវនេះ ខ្ញុំសូមចូលទៅដល់ផ្នែកមួយទៀត លោក លោកស្រីចៅក្រម លោកប្រធាន អំពីការប្រាស្រ័យទាក់ទងរវាងភូមិភាគឧត្តរចាស់ មកគណៈមជ្ឈិម ដែលលេខាភូមិភាគនោះឈ្មោះ កែ ពក គឺថាឯកសារ E3/1906 នេះជាសារទូរលេខចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ៧៨ ជាសារទូរលេខមកពី ពក –កែ ពក– មកពី ជាលេខាភូមិភាគ ជូនមកគណៈ៨៧០ ជាទីនឹករឭក។

[១១:៣៨:០០]

សារទូរលេខនេះ គឺផ្អែកលើខ្លឹមសារនៅក្នុងលិខិតមួយ ដែលបញ្ជាក់នៅខាងក្រោម៖ ផ្អែកតាមខ្លឹមសារសំបុត្រនេះ គាត់ជាលេខាភូមិភាគបានទទួល ៗពីសមមិត្ត អាន ពីលេខាតំបន់៤១ ដែល កែ ពក នោះបានិយាយថា "ខ្លឹមសារនៃលិខិតនេះ ដែលខ្ញុំ កែ ពក បញ្ជូនទៅមន្ទីរ៨៧០ នោះ ខ្លឹមសារនៃសំបុត្រនេះ ខ្ញុំចម្លងមកពីសំបុត្ររបស់សមមិត្តអាន តំបន់៤១ ជូនអង្គការ"។ ដូច្នេះ តើតំបន់៤១ រាយការណ៍អ្វីខ្លះ? បាទ យើងនឹងពិនិត្យមើលបន្ទាត់ទី១ នៃទូរលេខ គឺថានៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ គឺកងទ័ពនៅក្នុងតំបន់ -- ទាហាននៅក្នុងតំបន់៤១ ជាភូមិភាគរបស់ កែ ពក នោះបានឃាត់ខ្លួនយុវជនពីរនាក់មកពីខាងទ័ពអាកាស ហើយគេបានប្រាប់ថា ទៅភូមិភាគរបស់ កែ ពក ថា ពួកគេ គេមកជួសជុលយន្តហោះ នៅព្រលានយន្តហោះរ៉ឺនសៃ នៅខេត្តក្រចេះ នៅក្នុងភូមិភាគមួយខុសមួយផ្សេងទៀតនោះ។

[១១:៣៩:៣៦]

ដូច្នេះ លេខាភូមិភាគពេលនោះ ដែលឈ្មោះ កែ ពក នោះបានធ្វើការទាក់ទងមន្ទីរ៨៧០ ហើយមកក្រោមនៃសារទូរលេខនេះ "ចំពោះបញ្ហាដែលបានលើកឡើងខាងលើនេះ ស្នើអង្គការសាកសួរសមមិត្តម៉េត ផង ជា -- សួរមិត្តម៉េត ផងតើមានឈ្មោះដូចរាយការណ៍ទេ? បើមានសូមឲ្យដំណឹងមក

ទាក់ទង សមមិត្តអាន តំបន់៤១ ដើម្បីទទួលយុទ្ធជននេះផង។ ប្រសិនបើគ្មានទេ សូមអង្គការតបដំណឹងមកវិញ"។ នេះហើយជាការទាក់ទងពីភូមិភាគមួយ ទៅភូមិភាគមួយ ហើយជាបណ្តាញទំនាក់ទំនងផងដែរពីភូមិភាគទៅគណៈមជ្ឈិមនោះ។

[១១:៤០:៣៦]

ឯកសារមួយទៀត E3/511 ស្ថិតនៅក្នុងភូមិភាគរបស់ កែ ពក ដដែល។ នេះជាសារទូរលេខដែលចេញពី កែ ពក ជូនបងប៉ុល ជាទីគោរព ហើយចម្លងជូន បងនួន, បងខៀវ, មន្ទីរ ហើយនិងឯកសារ។ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦។ កែ ពក បាននិយាយក្នុងទូរលេខនេះថា "ខ្ញុំបានស្នើក្នុងរបាយការណ៍ជូនបង អំពីស្ថានភាពខ្មាំង គឺថា ស្ថានភាពរបស់មហាជន ហើយស្ថានភាពបង្កបង្កើនផលនៅភូមិភាគឧត្តរ"។ ហើយមានចំណងជើងដូចគ្នា ដែលអង្គជំនុំជម្រះអាចនឹងប្រើដើម្បីពិភាក្សាពិចារណា ដោយសារពេលខ្លី ខ្ញុំមិនអាចជម្រាបជូនឲ្យលម្អិតទាំងអស់បាននោះទេ។ ហើយខ្ញុំក៏បានពិនិត្យឃើញថា នេះជាសារទូរលេខមួយទៀតមកពីភូមិភាគ មួយនេះគឺឯកសារ E3/239។ ដើម្បីសន្សំពេលវេលានោះ ខ្ញុំមិននិយាយដោយលម្អិតនៅក្នុងសារទូរលេខនេះទេ។

[១១:៤២:០១]

ខ្ញុំសូមអនុញ្ញាតចូលទៅចំណុចមួយទៀត ដែលខ្ញុំបាននិយាយបន្តិចផងដែរ គឺជា -- អំពីការប្រាស្រ័យទាក់ទងពីភូមិភាគទៅភូមិភាគ តាមរយៈគណៈកម្មការរបស់ខ្លួននោះ។ ឯកសារទី១ នៅក្នុងផ្នែកនេះគឺ ឯកសារ E3/1679។ នេះជាសារទូរលេខ ដែលផ្ញើចេញពី ឆុន ឬ សោ ភឹម គឺមកពីភូមិភាគបូព៌ា គឺផ្ញើជូនសមមិត្តបងប៉ុល។ ដូច្នេះ គឺភូមិភាគបូព៌ារាយការណ៍ជូនសមមិត្តប៉ុល –សមមិត្តបងប៉ុល– បាទ។ តើលេខាភូមិភាគនេះរាយការណ៍អំពីអ្វី? គឺយើងឃើញនៅក្នុងបន្ទាត់ទី១ នៃសារទូរលេខនេះឯងដែលបាននិយាយថា យើងសូមអង្គការពីបញ្ជាដកប្រជាជន ពីភូមិភាគបូព៌ាទៅឧត្តរ។ ហើយយើងប្តូរទៅភូមិភាគឧត្តរនោះ ដែលកាលនោះភូមិភាគឧត្តរ មានលេខា កែ ពក។ នៅក្នុងនោះគឺថា មានការខ្វែងគំនិតគ្នាខ្លះរវាងភូមិភាគបូព៌ា ហើយនិងភូមិភាគឧត្តរ ហើយការមិនបានគោរពទៅតាមការណែនាំរបស់អង្គការ នូវចំណុចចាំទទួលនោះទេ ដែលនាំឲ្យមានបាតុភាពកើតឡើងដូចតទៅនេះ៖

[១១:៤៣:៥៣]

ហើយខ្ញុំអានឃ្លាដំបូងនេះ គឺយើងឃើញថា "នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ សមាជិកនៃជនចាមមូស្លីម ត្រូវបានដកហូតចេញអំពីតំបន់២១ គឺដកចេញពីភូមិភាគបូព៌ា ហើយដឹកតាមកាណូត ទៅ

តាមទន្លេ ចេញពីភូមិភាគបូព៌ា ទៅភូមិភាគរបស់ កែ ពក។ បន្ទាប់មកយើងឃើញមានទិសដៅពីរ ដែលគេដឹកទៅ ទៅក្នុងតំបន់របស់ កែ ពក នោះ ក្នុងភូមិភាគរបស់ កែ ពក នោះ ហើយគេបានបដិសេធមិនព្រមទទួលជនជាតិមូស្លីមនោះទេ គេទទួលយកតែខ្មែរសុទ្ធទេ។ ដូច្នេះ ប្រជាជនដែលត្រូវបានដកនោះគឺនាំឲ្យមានបញ្ហាជ្រួលច្របល់យ៉ាងខ្លាំង។ ដូច្នេះ សោ ភឹម គឺជាលេខាភូមិភាគបូព៌ា។ "ខ្ញុំបានផ្ញើមតិណែនាំទៅតំបន់ និងស្រុកភ្លាមៗឲ្យផ្អាកជាបណ្ដោះអាសន្នសិន រង់ចាំតំបន់ និងស្រុក និងយោបល់ណែនាំពីសមមិត្ត បងប៉ុល។ ដូច្នេះហើយរង់ចាំការសម្រេចពី បងប៉ុល នោះ ហើយនិងភូមិភាគឧត្តរផងដែរ"។ ហើយ សោ ភឹម បាននិយាយទៀតថា "បញ្ហានេះប្រហែលជាសមមិត្ត ពក មិនដឹងដែរទេមើលទៅ។ ដូច្នេះ លេខាភូមិភាគបូព៌ានោះមិនអាចទាក់ទង កែ ពក ទេ ដែលថានៅភូមិភាគផ្សេង ប៉ុន្តែនៅក្នុងករណីនេះគឺ គេត្រូវទាក់ទងតាមរយៈសមមិត្ត ប៉ុល។

[១១:៤៦:០៩]

ចំណុចមួយទៀត នៅក្នុង E3/956 នេះជាសារទូរលេខ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៧ មកពីភូមិភាគបស្ចិម បញ្ជូន -- "ជូនអង្គការជាទីគោរពស្នេហា"។ តាមរយៈការអាន យើងយល់ថា ភូមិភាគបស្ចិមហ្នឹងគឺរាយការណ៍ អំពីហេតុការណ៍នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៧៧ នៅពេលដែលគេឃុំខ្លួនមនុស្សនៅក្នុងភូមិភាគបស្ចិម ដែលថាអ្នកខ្លះនោះគឺថា អ្នកខ្លះលួចរត់ចេញពីភូមិភាគបស្ចិម។ ភូមិភាគបស្ចិមនោះនិយាយថា នៅក្នុងចំណុចទី៤ "រយៈពេលវារត់ចំនួន ១២០ថ្ងៃហើយ។ ដូច្នេះ សូមស្នើអង្គការទាក់ទងទៅខាងឧត្តរ បើមានមនុស្សរត់មែនឬទេ ថាតើវិធានការអ្វីដែលអង្គការត្រូវចាត់អនុវត្តនោះ"។ ដូច្នេះគឺថា ភូមិភាគបស្ចិមមិនអាចទាក់ទងឧត្តរដោយផ្ទាល់ទេចំពោះការឃុំខ្លួន ប៉ុន្តែក្នុងករណីនេះត្រូវទាក់ទងជាមួយអង្គការជាទីគោរពស្នេហា ដើម្បីឲ្យអង្គការនោះធ្វើការទាក់ទងជាមួយភូមិភាគឧត្តរ"។

[១១:៤៨:០៧]

ចំណុចមួយចុងក្រោយ នៅក្នុងផ្នែកនេះគឺថា E3/501 នេះជាសារទូរលេខដែលចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៧។ ទូរលេខនោះគឺផ្ញើមកពី យី ជាលេខាតំបន់ឯករាជ្យ៥០៥ បាទ ជាតំបន់៥០៥ ជាតំបន់ឯករាជ្យនោះ។ យី ជាលេខាតំបន់នេះ បានបញ្ជូនទូរលេខទៅមន្ទីរ៨៧០ ជាទីស្នេហា។ នៅក្នុងសារទូរលេខនេះ យោងតាមរបាយការណ៍ លេខាភូមិភាគទទួលរបាយការណ៍ពី ព្រំ ថា គាត់បានគ្រប់គ្រងកងទ័ពនៅតំបន់២១ ដែលនៅលើផែនទីនេះ យើងឃើញហើយដែលនៅក្នុងស្រុកមួយ "នៅក្នុងតំបន់ ២១ នេះ ដែលមានព្រំដែនជាប់នឹងស្ទួលនោះ ចេះតែចូលមកកាប់ស្លឹក កាប់ឈើនៅក្នុងតំបន់ខាង៥០៥

ដោយឥតបានឲ្យដំណឹងមកខាងតំបន់ -- មកខាង៥០៥ នាំឲ្យខាងយើងពិបាកពិនិត្យព្រៃ។ ដូច្នេះតាមដានរកខ្មាំងនោះផងដែរ។ អ៊ីចឹងលេខាភូមិភាគឯករាជ្យ ឈ្មោះ យី នេះគឺបញ្ជូនទូរលេខដោយមានសំណូមពរផង។ "យើងខ្ញុំស្នើឲ្យខាង២១ បូព៌ា ជូនដំណឹង -- យើងស្នើឲ្យមន្ទីរ៨៧០ សូមឲ្យតំបន់២១ ឲ្យជូនដំណឹងយើងខ្ញុំផង បើមានការចូលមកកាប់ស្មឹក កាប់ឈើនៅក្នុងតំបន់ដី៥០៥ ជិតជាប់ព្រំដែនគ្នាក្តី"។ ដូច្នេះបង្ហាញថា លេខាភូមិភាគឯករាជ្យពិសេស ឯករាជ្យ យី នេះគឺថាមិនអាចទាក់ទងទៅភូមិភាគមួយទៀត ដោយផ្ទាល់ទេ គឺត្រូវធ្វើទំនាក់ទំនងដោយឆ្លងមន្ទីរ៨៧០ ជាមុនបាទ។

[១១:៥១:០៨]

ខ្ញុំសូមអនុញ្ញាតចូលទៅចំណុចមួយទៀត គឺទំនាក់ទំនងរវាងតំបន់ តំបន់ទៅភូមិភាគ គោលបំណងនោះគឺឯកសារ E3/178។ នេះជារបាយការណ៍ប្រចាំសប្តាហ៍បញ្ជូនចេញពីតំបន់៥ នៅក្នុងផែនទីនេះគឺថា តំបន់៥ នេះនៅក្នុងភូមិភាគពាយ័ព្យ នេះជារបាយការណ៍តំបន់ប្រចាំសប្តាហ៍។ របាយការណ៍នោះគឺចម្លងជូន លេខាភូមិភាគគឺ ទៅលេខាភូមិភាគពាក់ព័ន្ធ ហើយនិងដាក់ចូលជាឯកសារនោះផងដែរ។ របាយការណ៍តំបន់នេះគឺថា មានចំណាងជើងមួយនៅកន្លែងចំណុចនោះ។ ទំព័រខ្មែរគឺ 00275588 រហូតទៅដល់ 89, បារាំង ERN 00623326, អង់គ្លេស 00342710។ នៅក្នុងខ្លឹមសារនេះគឺ ដែលនិយាយនៅក្នុងភាសាខ្មែរ នៅទំព័រខាងលើ សូមអង្គជំនុំជម្រះមេត្តាពិចារណាលើចំណុចនេះជាពិសេស។ បាទ និយាយនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៧ "មានខ្មាំងថៃ ចំនួន១០នាក់ បានចូលមកក្នុងដីយើងជម្រៅ ១០ម៉ែត្រនៅឡាក់៤២ ពួកវាត្រូវបានទទួលរងគ្រោះថ្នាក់ ដោយត្រូវនឹងមីនរបស់យើងមួយគ្រាប់"។ សូមជម្រាបថា នេះគឺជារបាយការណ៍ប្រចាំសប្តាហ៍ភូមិភាគមួយទៅតំបន់៥ ទៅភូមិភាគពាយ័ព្យឲ្យបានដឹងជាព័ត៌មាន។ សូមឲ្យអង្គជំនុំជម្រះមេត្តាពិចារណា ចំណុចនេះជាពិសេសក្នុងការប្រើខ្លឹមសារលម្អិតនោះ។

[១១:៥៣:៣០]

ប្រអប់ពណ៌ក្រហម នៅក្នុងទំព័រខ្មែរនោះគឺមានខ្លឹមសារថា សូមដកស្រង់ "ផ្អែកទៅលើការណែនាំរបស់បក្សជាបន្តបន្ទាប់ ដោយឈរលើសេចក្តីសម្រេចចិត្តរបស់អង្គសន្និបាតភូមិភាគ ដោយឈរលើសភាពការណ៍ជាក់ស្តែងជាបន្តបន្ទាប់ ដូចខាងលើនេះ។ យើងខ្ញុំបានបន្តវាយសម្រុក អប់រំបំពាក់បំប៉ន ខាងទស្សនៈ និងគោលជំហរ និងចំពោះកម្មាភិបាលបក្ស សមាជិកបក្ស អង្គការស្នូល។ នៅក្នុងពេលនេះគឺបានផ្សព្វផ្សាយ ៗទាំងប្រជាជនចាស់ ទាំងថ្មី ក្នុងសហករណ៍សម្ងហភាព ក្នុងសហជីត

កម្មករ ឲ្យជ្រួតជ្រាប ដើម្បីពង្រឹងនិងទស្សនៈ -- និងទាំងទស្សនៈ ទាំងគោលជំហរ បន្តបំផុសបំផុលចលនាការពារសហករណ៍ ការពារសហជីព ដោយបន្តបោសសម្អាតសមាសភាពក្បត់ឲ្យអស់រលីងដែលបង្កប់ជាខ្សែ សេ.អ៊ី.អា ជាខ្សែ កា.ហ្សេ.បេ ជាខ្សែវៀតណាម"។ នៅក្នុងរបាយការណ៍ដដែលនេះគឺខ្មែរទំព័រ 00275587, បារាំង ERN 00623305 ដល់ 06, អង់គ្លេស 00342709។

[១១:៥៥:១០]

នេះជារបាយការណ៍នៅក្នុងតំបន់ ហើយខ្ញុំសូមដកស្រង់ "យើងបានរកឃើញដោយជោគជ័យអំពីអ្នកដែលបង្កប់ខ្លួន និងជនក្បត់ជាពួកសមាសភាព ១៧ មេសា មកពីភ្នំពេញ។ ការពិនិត្យសកម្មភាពរបស់គេ ផ្អែកទៅលើចម្លើយរបស់បណ្តាញរបស់ពួកគេ ដែលអង្គការបានណែនាំឲ្យយើងស្វែងរកនោះ"។

ដើម្បីសន្សំពេលវេលានោះ ខ្ញុំនឹងផ្តោះទំព័រខ្លះនៅក្នុងឯកសារនេះ។ ខ្ញុំសូមអនុញ្ញាតចូលទៅដល់ទំព័រចុងក្រោយនៃឯកសារនេះ នៅក្នុងឯកសារ E3/178។ "តំបន់៥ បាននិយាយថា ការងារកសាងពង្រឹងពង្រីកបក្ស និងអង្គការស្ហូល"។ សូមដកស្រង់ នេះនៅក្នុងរបាយការណ៍របស់តំបន់៥ "នៅក្នុងរយៈកាល១អាទិត្យនេះបានយកសេចក្តីសម្រេចចិត្ត របស់អង្គសន្និបាតភូមិភាគមកផ្សព្វផ្សាយរៀនសូត្រនៅក្នុងសាខាបក្សគ្រប់មូលដ្ឋាន និងនៅតាមសមរភូមិ និងនៅក្នុងកងទ័ព ដោយបានពាក់ព័ន្ធយ៉ាងជ្រាលជ្រៅ និងក្តាប់បានមួយកម្រិត"។

[១១:៥៦:៤៧]

កថាខណ្ឌបន្ទាប់ទៀត "នៅក្នុងអាទិត្យនេះ បានពិនិត្យប្រវត្តិរូបជាបេក្ខជនចាស់ និងប្រវត្តិរូបមហាជនចម្រើន ដើម្បីពង្រីកមហាជនចម្រើនតទៅទៀត។ មួយទៀត បានបើកវគ្គអប់រំផ្ទែកផ្ទៃក្នុងបក្សជនបង្គោលផងដែរ"។ កថាខណ្ឌនោះគឺថា "មានបានបើកវគ្គអប់រំចំពោះបក្សផ្ទៃក្នុង ជនបង្គោល ហើយនិងមហាជនចម្រើននៅក្នុងអង្គភាពយោធា តំបន់ ស្រុក សេនាជននារី អំពីសកម្មភាព សភាពការណ៍ការពារប្រទេស"។ ហើយចុងខាងក្រោមមកទៀត "នៅក្នុងគណៈសហករណ៍ នឹងមានផែនការបន្តការអប់រំតទៅទៀត"។

ឯកសារបន្ទាប់ទៅទៀតនេះ គឺឯកសារ E3/180 ឯកសារខាងដើមដែលជារបាយការណ៍ប្រចាំសប្តាហ៍របស់តំបន់នោះ ចុះថ្ងៃ២១ ខែឧសភា ឆ្នាំ១៩៧៧។ ឥឡូវនេះយើងចូលទៅដល់ឯកសារ E3/180 ជារបាយការណ៍ចេញមកពីភូមិភាគពាយ័ព្យ ហើយរបាយការណ៍នេះនៅខាងលើហ្នឹងនិយាយ

ការ -- ចាប់ផ្តើមពីថ្ងៃទី០៤ ខែ៥ ឆ្នាំ១៩៧៧ ដល់ថ្ងៃទី២៩ ខែ០៥ ឆ្នាំ១៩៧៧ ជារបាយការណ៍របស់ភូមិភាគពាយ័ព្យ។ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ គឺប្រហែលជា១អាទិត្យ ក្រោយពីមានរបាយការណ៍ពីតំបន់មកភូមិភាគ។ សូមឲ្យលោក លោកស្រីចៅក្រមចងចាំ និងពិចារណាអំពីខ្លឹមសារ ដែលនិយាយថា តំបន់រាយការណ៍ថា "ប្រជាជនថៃ១០នាក់ ដែលបានចាប់ខ្លួននោះ"។ ហើយយើងឃើញមានសរសេរនៅក្នុងរបាយការណ៍នៅក្នុងខែ -- ថ្ងៃទី២៩ ខែ៥ ឆ្នាំ៧៧ ដែលនិយាយអំពីខ្មាំងថៃ១០រូប ដែលបានចូលមកទឹកដីខ្មែរ ហើយបានជាន់មីនរបស់យើង ជម្រៅ១០ម៉ែត្រ ក្នុងឡាក់៤២ នោះគឺថា អ៊ីចឹងគឺរបាយការណ៍ដែលគេរាយការណ៍ហេតុការណ៍ពីតំបន់មកភូមិភាគ ភូមិភាគបានយកខ្លឹមសាររបាយការណ៍ហ្នឹងដាក់ក្នុងរបាយការណ៍ភូមិភាគផ្ញើមកគណៈមជ្ឈិមតទៅទៀត។ ដោយសារខ្ញុំមានពេលមិនច្រើននោះ ខ្ញុំមិនដកស្រង់សេចក្តីលម្អិតទាំងអស់នោះទេបាទ។

[១២:០០:០៥]

លោកប្រធាន ឥឡូវនេះ ជិតដល់ម៉ោង១២ហើយ ខ្ញុំសូមជម្រាបថា ខ្ញុំនឹងលើកបញ្ហានេះ អាចនឹងជួយបាន។ ការិយាល័យសហព្រះរាជអាជ្ញាបានជ្រើសរើសយកឯកសារ៥០ ដើម្បីនឹងដាក់ជូនលោក លោកស្រីចៅក្រម។ ឥឡូវនេះ យើងបានបង្ហាញតែ៣៨ តែប៉ុណ្ណោះទេ។ នៅសល់ឯកសារ១២ ទៀត ខ្ញុំមិនស្នើដើម្បីបង្ហាញដេញដោល ដាក់ជូនទាំង១២ នោះទេ ប៉ុន្តែយើងបានលើកសំណើដូចថ្ងៃនេះ។ ខ្ញុំសូមស្នើពេលកន្លះម៉ោងទៀតល្ងាចនេះ ដោយហេតុថា យើងមានពេលការពន្យារពេល១៥នាទី ដែលមេធាវីការពារបានលើកឡើងនោះ។ ដូច្នេះ យើងខ្ញុំស្នើពេលកន្លះម៉ោងទៀត បន្ទាប់ពីអាហារថ្ងៃត្រង់ ដើម្បីឲ្យខ្ញុំបានបញ្ចប់ការបង្ហាញឯកសារនេះជូនតុលាការ។ បាទ សូមអរគុណ។

[១២:០១:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតតាមសំណើសុំរបស់លោកតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។

ចំណុចទី១ ដែលខ្ញុំចង់លើកឡើងនោះ យើងមិនមានការជំទាស់អ្វីទេ ចំពោះសំណើរបស់សហព្រះរាជអាជ្ញា ដែលអង្គជំនុំជម្រះបានអនុញ្ញាតនោះ។ មិនមែនដោយហេតុថា លោក វេយ័ន័រ បានលើក

ឡើង គាត់ថា គាំទ្រនូវជំហររបស់យើង។ ចំណុចទី២ ដែលខ្ញុំចង់លើកឡើងនោះ គឺសំណើសុំឱ្យមានការបំភ្លឺដែលលោកប្រធានបានបញ្ជាក់ព្រឹកមិញនេះ។ ខ្ញុំចង់ឱ្យច្បាស់ថា ខ្ញុំដឹងចាប់បានច្បាស់ដែរ តើលោកប្រធានបានបញ្ជាក់ថា ចៅក្រមទាំងអស់បានអានអត្ថបទសារព័ត៌មាន ដែលខ្ញុំបានលើកឡើង តើចៅក្រមទាំងអស់ ឬក៏គ្រាន់តែចៅក្រមរូបណា? សូមលោកចៅក្រមជម្រាប តើមានតែចៅក្រមខាតវ៉ាយថ៍ ដែរទេ? ដើម្បីឱ្យខ្ញុំបានយល់ច្បាស់--

[១២:០២:០៥]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមបញ្ជាក់ជូនលោកថា វាជាប្រភេទឯកសារថ្មី ប្រសិនបើលោកយល់ឃើញថា វាមានភាពពាក់ព័ន្ធ លោកប្រព្រឹត្តទៅតាមនីតិវិធីដែលអង្គជំនុំជម្រះបានកំណត់ ឱ្យលោកដាក់សំណើសុំជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះ ដោយបង្ហាញអំពីភាពពាក់ព័ន្ធ ដូចមានចែងនៅក្នុងវិធាន៨៧(៤) និងវិធាន៨៧(៣) និងដូចអ្វីដែលអង្គជំនុំជម្រះបានជម្រាប និងកំណត់ជូនលោករួចហើយ និងភាគីពាក់ព័ន្ធរួចហើយ អំពីនីតិវិធីនៃការស្នើសុំដាក់ឯកសារថ្មី។

ចំណែកផ្សេងទៀត យើងមិនឆ្លើយតបទេ ពីព្រោះលោកដាក់ឯកសារជាភាសាបរទេស ភាសាអង់គ្លេស ហើយលោកមិនបានដាក់មកយើងទេ។ តែលោកចាំឱ្យច្បាស់ ឯកសារថ្មីត្រូវដាក់តាមនីតិវិធីដែលអង្គជំនុំជម្រះបានកំណត់ ហើយមិនអនុញ្ញាតឱ្យលោកនិយាយលើកឡើង នូវសំណើប្រភេទនេះដដែលៗផ្ទាល់មាត់ទេ។ ហើយយើងមិនមែនអ្នកឆ្លើយទេណា៎ យើងមិនមានអ្នកចាំឆ្លើយនឹងសំណួររបស់លោកទេ។

[១២:០៣:៤៩]

**លោក អេនគ្រូ អ៊ីនូហ្វ្រី៖**

សូមអរគុណដែលលោកប្រធានបានបំភ្លឺ។ បន្ទាប់ទៅទៀតនេះ គឺលោក នួន ជា ក៏បានមានជំងឺឈឺក្បាល ឈឺខ្នង ហើយគាត់មិនអាចផ្តង់អារម្មណ៍បាន ហើយសូមអនុញ្ញាតទៅតាមដានសវនាការពីបន្ទប់ខាងក្រោម ហើយខ្ញុំនឹងបំពេញបែបបទទៅតាមនីតិវិធីរបស់តុលាការ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោត

ទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅពីក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញ១រសៀលថ្ងៃនេះ។ ដោយលោក នួន ជា បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ ក្នុងកិច្ចដំណើរសវនាការនៅក្នុងបន្ទប់សវនាការនេះ។

[១២:០៤:៥១]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការដោយផ្ទាល់ ដោយចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក នួន ជា។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការ នៅរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម។ ដោយនៅរសៀលនេះឲ្យទុកលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៥:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបញ្ចប់នូវការបង្ហាញភស្តុតាងពាក់ព័ន្ធជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ។ បញ្ចប់នូវកិច្ចការនេះរបស់ខ្លួន តាមសំណើរបស់លោកតំណាងសហព្រះរាជអាជ្ញាកាលពីព្រឹកមិញ គឺសូម ៣០នាទី។

សូមអញ្ជើញ!

**លោក ឃើត វេយ៍ន័រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ឯកសារដែលត្រូវបង្ហាញចំនួនពីរបីទៀតហ្នឹង ទាក់ទងទៅនឹងប្រព័ន្ធទំនាក់ទំនងរវាងតំបន់ទៅភូមិភាគ។ ខ្ញុំសូមបង្ហាញជូនឯកសារដែលខ្ញុំបានស្នើសុំតុលាការពីមុនសម្រាកពិសាបាយថ្ងៃត្រង់ ឯកសារនេះគឺថាត្រូវបានខាងផ្នែកតំបន់បញ្ជូនទៅភូមិភាគហើយបន្ទាប់មកភូមិភាគបញ្ជូនទៅថ្នាក់លើទៀត។

[១៣:៣៧:១៧]

ឥឡូវនេះខ្ញុំសូមបង្ហាញជូនចំៗតែម្តង គឺពីតំបន់ ប្រព័ន្ធទំនាក់ទំនងពីតំបន់ទៅកាន់ភូមិភាគ។ ឯកសារទី១ គឺ E3/1019។ នេះគឺជារបាយការណ៍ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦ សេចក្តីរាយការណ៍នេះ គឺរាយការណ៍មកពីតំបន់២៣ ផ្ញើជូនទៅគណៈអង្គការអចិន្ត្រៃយ៍តំបន់២៣។ យើងឃើញ បើមើលលើភូមិភាគ ឃើញតំបន់បូព៌ានៅលើផែនទីនេះ ហើយឃើញតំបន់២៣ នៅស្វាយរៀងជាប់ព្រំដែនជាមួយនឹងប្រទេសវៀតណាម។ ហើយរបាយការណ៍ដែលផ្ញើពីតំបន់នេះ បាននិយាយនៅក្នុងកថាខណ្ឌទី២ នៃរបាយការណ៍ជាក់ស្តែងនេះតែម្តងថា សូមដកស្រង់ "យើងខ្ញុំ តំបន់២៣ បានទទួលរបាយការណ៍ពីគណៈកម្មាធិការស្រុកចន្ទ្រា អំពីឧបទ្ទវហេតុកើតឡើងនៅថ្ងៃទី១៦ ខែកុម្ភៈ ១៩៧៦"។ នៅផ្នែកខាងក្រោមរបាយការណ៍បានរាយការណ៍ថា "តើ -- សូមឲ្យគណៈអចិន្ត្រៃយ៍ភូមិភាគជូនយោបល់មកខាងយើងខ្ញុំ"។ ដូច្នេះយើងឃើញថា ខាងតំបន់ទទួលរបាយការណ៍ពីស្រុក ដែលស្ថិតនៅខាងក្រោមរបស់ខ្លួនហើយបញ្ជូនរបាយការណ៍នេះបន្តមកភូមិភាគ។ ក្នុងករណីនេះ គឺរបាយការណ៍ដែលបញ្ជូនទៅភូមិភាគបូព៌ា។

[១៣:៣៩:៣៦]

ហើយនៅខាងក្រោមឯកសារនេះដែរ គឺយើងនៅមានឯកសារ E3/1120។ របាយការណ៍នេះគឺពាក់ព័ន្ធជាមួយនឹងភូមិភាគពាយ័ព្យ។ យើងឃើញនៅលើផែនទីដែរ ហើយតំបន់៥ គឺស្ថិតនៅផ្នែកខាង

ជើងនៃខេត្តបាត់ដំបង។ នេះគឺជាសារទូរលេខពីតំបន់៥ ផ្ញើជូន បងញ៉ឹម។ ដូច្នេះ បងញ៉ឹម គឺជាប្រធាន គឺជាគណៈភូមិភាគពាយ័ព្យ។ សារទូរលេខនិយាយអំពីស្ថានភាពខ្លាំងនៅក្នុងតំបន់៥ ហើយពាក់កណ្ដាល ទំព័រនេះ សូមដកស្រង់ "បញ្ហានេះតាមតំបន់នីមួយៗមានវិធានការហើយគឺ ១) ខិតខំរកក្បាលម៉ាស៊ីន ខ្លាំង ក្បាលម៉ាស៊ីនខ្លាំងតទៅទៀត។ ២) ខិតខំឃោសនាអប់រំប្រជាជនឲ្យគេយល់អំពីបដិវត្តន៍សង្គម និយមឲ្យបានច្បាស់ថែមទៀត។ ៣) មូលដ្ឋាន និងយោធាត្រូវសហការណ៍គ្នាឲ្យជិតស្និទ្ធ ដើម្បីកម្ទេច ខ្មាំងគ្រប់បែបយ៉ាង"។ បន្ទាប់មកទៀត ខ្ញុំសូមបង្ហាញជូននូវឯកសារ៧ដដែលនេះ ក៏ប៉ុន្តែមកផ្នែកខាង ក្រោមនិយាយអំពីការចាត់តាំង ផ្នែកខាងរដ្ឋបាល ជាពិសេសរវាងឃុំ និងស្រុក ហើយពេលខ្លះក៏មាន ពាក់ព័ន្ធទៅដល់តំបន់ដែរ គឺនិយាយអំពីប្រព័ន្ធទំនាក់ទំនងរវាងឃុំ និងស្រុក។

[១៣:៤២:០៧]

ហើយឯកសារទី១នេះគឺ IS18.52។ ERN ជាភាសាខ្មែរ 00079106, បារាំង 00712134, ហើយអង់គ្លេស 00276574។ នេះគឺជាការទាក់ទងគ្នាពីសហករណ៍មកកាន់ថ្នាក់ស្រុក។ ដូច្នេះ សហករណ៍ពាក់ព័ន្ធគឺមានត្រពាំងធំខាងជើង គឺឃុំត្រពាំងធំខាងជើង ហើយសហករណ៍បានផ្ញើជូនទៅ អង្គការស្រុកត្រាំកក់។ ដូច្នេះប្រព័ន្ធទំនាក់ទំនងពីសហករណ៍គឺទាក់ទងមកថ្នាក់ស្រុក។ ហើយការ ទាក់ទងគ្នានេះ និយាយអំពីក្រុមយុវជនដែលបានជួបប្រជុំគ្នាជាសម្ងាត់នៅពាក់កណ្ដាល់អធ្រាត្រ ហើយ របាយការណ៍និយាយ "កងឈ្លបឃុំចាប់បាន រួចយកមកសួរចម្លើយ។ ពួកគេមិនព្រមឆ្លើយទេទាល់តែ សោះ ពួកគេគឺនៅស្ងៀមទាំងអស់គ្នា ឥឡូវនេះបានបញ្ជូនមកហើយ។ ហេតុនេះសូមអង្គការសូមជ្រាប ជាព័ត៌មាន"។

ឯកសារបន្ទាប់ IS18.44 នេះគឺជារបាយការណ៍មកពីឃុំផ្ញើទៅថ្នាក់ស្រុក។ ERN ជាភាសា បារាំងសម្រាប់ឯកសារនេះមិនមានទេ ប៉ុន្តែ ERN ជាភាសាអង់គ្លេស 00276590, ខ្មែរ 0082729 ដល់ 30។ វាជាការទំនាក់ទំនងដែលផ្ញើជូនមកស្រុកត្រាំកក់ មូលដ្ឋានស្រុកត្រាំកក់។ បាទ គឺរបាយ-ការណ៍នេះ គឺរបាយការណ៍មកពីឃុំខ្ពបត្របែក និយាយអំពីទាហានដែលជាអ្នកថ្មីចំនួន ១០នាក់ ដែល មកពីភ្នំពេញ ឯកសារចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៧។ ហើយទាក់ទងទៅនឹងមនុស្ស ចំនួន១០នាក់នេះ ថ្នាក់ឃុំគឺបានសរសេរនៅផ្នែកខាងក្រោមនៃរបាយការណ៍នេះថា "ដូច្នេះ សូមស្នើសុំអាទាំង១០នេះ បញ្ជូនមកឲ្យ -- សម្រាប់ឲ្យអង្គការជាអ្នកសម្រេច"។ ហើយនៅលើកឯកសារដដែល គឺ D157.47 នេះជារបាយការណ៍ផ្ញើពីថ្នាក់ឃុំមកថ្នាក់ស្រុក ហើយថ្នាក់ឃុំក៏បានទទួលសេចក្ដីណែនាំ មកពីថ្នាក់

ស្រុកនោះវិញ។ របាយការណ៍នេះបាននិយាយ គឺផ្ញើជូនអង្គការថ្នាក់ស្រុកជាទីគោរព ហើយនៅក្នុងរបាយការណ៍នេះ គឺខ្ញុំសូមមិនលើកឡើងលម្អិតទេ។ អ្នកដែលគេត្រូវចាប់នេះ គឺជាអ្នកថ្មី ខាងថ្នាក់ឃុំនិយាយនៅផ្នែកខាងក្រោមថា "ខ្ញុំស្នើសុំអង្គការ គឺអង្គការស្រុក សូមជម្រាបជូន សូមមេត្តាមានមតិចំពោះបញ្ហាដែលលើកឡើងខាងលើនេះ"។

[១៣:៤៦:៥៣]

ហើយនៅផ្នែកខាងក្រោមនៃរបាយការណ៍នេះ យើងមានការឆ្លើយតបយល់ព្រមពីថ្នាក់ស្រុកត្រាំកក់ គឺថ្នាក់ គឺស្រុកត្រាំកក់។ គឺឈ្មោះ គិត លេខាស្រុកត្រាំកក់នេះគឺឈ្មោះ គិត គាត់យល់ស្របជាមួយនឹងរបាយការណ៍ពីថ្នាក់ឃុំ។ សូមដកស្រង់ "យើងយល់ស្របថា ឈ្មោះ មូ ផុន នេះ ស្នើចាប់ចុះ"។ កាលបរិច្ឆេទគឺមាននៅខាងក្រោម។ ដូច្នេះបង្ហាញថា មានទំនាក់ទំនងពីថ្នាក់ឃុំមកស្រុក ហើយស្រុកក៏បានផ្តល់ជាមតិជូនទៅថ្នាក់ឃុំវិញ។

ឯកសារបន្ទាប់មកទៀត គឺ D157.95 នេះគឺជារបាយការណ៍មកពីថ្នាក់ស្រុក ផ្ញើជូនទៅខាងមន្ទីរសន្តិសុខស្រុក តាមរយៈពីសេចក្តីសម្រេចរបស់អង្គការស្រុករួចមក គឺឯកសារចុះកាលបរិច្ឆេទថ្ងៃទី ១៤ ធ្នូ ១៩៧៧។ របាយការណ៍បានដាក់ថា ខ្ញុំសូមធ្វើសេចក្តីរាយការណ៍ជូនបងតំណាងមន្ទីរអប់រំស្រុកត្រាំកក់ជ្រាបជាព័ត៌មាន។ ហើយបន្ទាប់មកយើងឃើញថា មានអ្វីកើតគឺនៅបន្ទាត់ខាងក្រោម ដោយអង្គការស្រុកបានសម្រេចឲ្យយើងចាប់មនុស្សពីរនាក់បញ្ជូនមកមន្ទីរអប់រំស្រុក ហើយគេបានកំណត់ឈ្មោះមនុស្សដែលត្រូវចាប់ខ្លួនទាំងពីរនេះ។

[១៣:៤៨:៥៧]

ហើយនៅផ្នែកខាងក្រោមនៃការទំនាក់ទំនងគ្នានេះ ហេតុដូចខាងលើនេះ សូមសមមិត្តទទួលយកផងចុះ សមមិត្តបងទទួលយកផងចុះ។ អង្គការស្រុក។ ហើយឯកសារបន្ទាប់គឺ IS18.26។ នេះជារបាយការណ៍មកពីស្រុក ផ្ញើទៅមន្ទីរសន្តិសុខស្រុក -- (សូមទោស សូមកែប្រែ) របាយការណ៍ពីថ្នាក់ឃុំទៅមន្ទីរសន្តិសុខស្រុក។ របាយការណ៍នេះ គឺរបាយការណ៍ផ្ញើមកពីឃុំអង្គតាសោម ហើយផ្ញើជូនទៅសមមិត្តប្រធានមន្ទីរអប់រំស្រុកត្រាំកក់។ ខ្លឹមសារនៃការទំនាក់ទំនងគ្នានេះ តាមរយៈនេះផ្ញើជូនឈ្មោះ ពៅ ជល់ ដែលជាប្រជាជនថ្មី មកកាន់មន្ទីរសន្តិសុខស្រុក។ ហើយបន្ទាប់មកទៀត យើងខ្ញុំសូមបង្ហាញជូននូវទម្រង់នៃប្រព័ន្ធទំនាក់ទំនងមួយទៀត ដែលមានចំណងជើងនេះគឺ -- នេះជាទម្រង់នៃប្រព័ន្ធទំនាក់ទំនងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រៅពីសារទូរលេខ សុន្ទរកថា កំណត់ហេតុប្រជុំ ជាដើម។ល។

ហើយឯកសារទី១ នោះគឺ D232/78.2 នេះគឺជាលិខិតទេ លិខិតចុះថ្ងៃទី០១ ខែសីហា ឆ្នាំ ១៩៧៧ ជាលិខិតមកពីឈ្មោះ អាន ទៅកាន់ ផ្ញើជូនទៅកាន់ឈ្មោះ បឿន។ និយាយអំពីការចាប់ខ្មាំងពីរនាក់ ហើយនៅក្នុងចម្លើយសារភាព ក៏គេបានសរសេរឈ្មោះទាំងពីរនាក់ ដែលបានចាប់កន្លងមកនោះ។ យើងឃើញនៅក្នុងលិខិតនេះដាក់ថា "មកសមមិត្ត បឿន ជ្រាប ស្នើសមមិត្តចាត់តាំងកម្លាំងឈ្លប ឲ្យចាប់អាខ្មាំងពីរនាក់ នៅភូមិស្រែគ្រូ ហើយខាងក្រោមមានឈ្មោះរបស់ពួកគេ។ អ្នកទាំងពីរនេះមានផែនការរត់គេចខ្លួនទៅកាន់ប្រទេសវៀតណាម។ ក្នុងចម្លើយសារភាពគេបានសរសេរឈ្មោះទាំងអស់នេះ ថា មានឈ្មោះ អាអ៊ីញ និងឈ្មោះ អាថន"។

[១៣:៥២:១៥]

ខ្ញុំគិតថា លិខិតនេះ ជាលិខិតមួយ ដែលមានទម្រង់បែបជាសារទូរលេខ ហើយបន្ទាប់មកទៀតឯកសារ E3/859។ នេះជាឯកសារចុះថ្ងៃទី១៥ មេសា ១៩៧៨ អ្នកដែលធ្វើការទំនាក់ទំនងនោះគឺត្រូវបានគេជូន គេមានចម្លងជូនផងដែរ ខ្ញុំនឹងជម្រាបជូននៅផ្នែកខាងក្រោម នៃឯកសារនេះ។ ឯកសារនេះគឺមានចំណងជើងរបស់វា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី១៥ មេសា ១៩៧៨, ជម្រាបអំជាទីគោរព ជាទីស្នេហានឹករឭក"។ ហើយឯកសារនោះ ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅភូមិភាគបូព៌ា ជាពិសេសគឺព្រឹត្តិការណ៍ពាក់ព័ន្ធទៅនឹងតំបន់២៤ ដែលនិយាយអំពីទូរស័ព្ទសម្ងាត់។ ហើយនៅក្នុងឯកសារនិយាយអំពីទូរស័ព្ទសម្ងាត់នេះដែរ ឯកសារបន្ទាប់គឺ E3/1082 នេះជាឯកសារចុះថ្ងៃទី១២ ខែសីហា ១៩៧៧ ជាឯកសារមកពីឈ្មោះ មុត ឯកសារមកពីសមមិត្ត មុត។ ឯកសារនេះមានចំណងជើងថា "របាយ-ការណ៍ ចុះថ្ងៃទី១២ សីហា ១៩៧៧"។ ហើយក្នុងនេះក៏មានចំណារនៅក្នុងកថាខណ្ឌទី១ នៃរបាយ-ការណ៍នេះផងដែរ។

[១៣:៥៤:៤៦]

ចំណារនៅក្នុងកថាខណ្ឌទី១ និយាយថា "យោងទៅតាមការទំនាក់ទំនងទូរស័ព្ទជាមួយសមមិត្ត មុត"។ ចំណុចនេះ គឺពាក់ព័ន្ធទៅនឹងការនេសាទ ហើយមានចំណារដោយផ្ទាល់ដៃ នៅត្រង់ជ្រុងកៀនខាងឆ្វេង "ផ្ញើជូនអង្គការ យើងខ្ញុំស្នើសុំឲ្យស្វែងរកបណ្ដាញៗចេញចូលនូវសមាសភាពក្បត់នៅតាមព្រំដែន"។ ហើយឯកសារនេះ ចុះហត្ថលេខាដោយឈ្មោះ ខៀវ នៅថ្ងៃទី១៣ សីហា មួយពាន់ប្រាំបួន--បាទ គឺត្រឹមតែថ្ងៃទី១៣ សីហា ហើយយើងឃើញមានចម្លើយសារភាពឯកសារទី១ E3/1289។ នេះគឺជាឯកសារ។ ខ្ញុំសូមផ្ដល់ ERN 00224163, ERN ជាភាសាបារាំង 00324920, ហើយ ERN

អង់គ្លេស 00169190។ ទំព័រនេះ ពាក់ព័ន្ធជាមួយនឹងចម្លើយសារភាព ហើយនៅត្រង់ទំព័រនេះ គឺជាចម្លើយសារភាព ដែលត្រូវបានយកទៅផ្សាយតាមសេវាផ្សព្វផ្សាយទីក្រុងភ្នំពេញ នៅក្នុងប្រទេសកម្ពុជា នៅម៉ោងដប់មួយយប់ នៅថ្ងៃទី០១ កុម្ភៈ ១៩៧៨។ អ្វីដែលបានផ្សព្វផ្សាយនោះ គឺចាផ្សព្វផ្សាយចម្លើយសារភាព ចុះថ្ងៃទី២៩ ខែមករា ៧៨ គឺ ខ្ញុំឈ្មោះ ម៉ូ ឈិន ដែលជាឈ្មោះនេះ បង្ហាញថាជាជនជាតិវៀតណាម។

[១៣:៥៧:១៥]

ហើយចុងក្រោយនោះ គឺឯកសារ E3/1362 ERN ជាភាសាខ្មែរ 00701795, ERN ជាភាសាបារាំង 00701785, ហើយERN ជាភាសាអង់គ្លេស 00169986។ ទំព័រនោះ ពាក់ព័ន្ធទៅនឹងចម្លើយសារភាពនៃជនជាតិវៀតណាមដែលបានចាប់ខ្លួន ហើយត្រូវបានយកចម្លើយសារភាពនេះមកផ្សព្វផ្សាយសេវាផ្សព្វផ្សាយទីក្រុងភ្នំពេញ នៅម៉ោងដប់មួយយប់ នៅថ្ងៃទី២៥ កុម្ភៈ ១៩៧៨។ ហើយអ្វីដែលយកទៅរាយការណ៍ គឺយកទៅរាយការណ៍នូវចម្លើយសារភាព ចុះថ្ងៃទី១៥ មេសា នៃទាហានវៀតណាមដែលបានចាប់ខ្លួននៅថ្ងៃទី០៧ ខែកុម្ភៈ -- (សូមកែប្រែ) ថ្ងៃទី០៧ ខែមេសា។

[១៣:៥៨:៣៣]

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់តែត្រឹមនេះសិន នៃការបង្ហាញឯកសារប្រភេទនេះ គឺឯកសារទាក់ទងទៅនឹងប្រព័ន្ធទំនាក់ទំនង ដើម្បីបង្ហាញឲ្យឃើញប្រព័ន្ធទំនាក់ទំនងនៅថ្នាក់លើ ប្រព័ន្ធទំនាក់ទំនងនៅថ្នាក់ភូមិភាគ ហើយទាក់ទងពីភូមិភាគទៅតំបន់ តំបន់ទៅស្រុក ស្រុកទៅឃុំរួមទាំងទំនាក់ទំនងជាមួយមន្ទីរសន្តិសុខស្រុកផង ហើយក៏ដូចជាការផ្សព្វផ្សាយយ៉ាងទូលំទូលាយ។

លោកប្រធាន ខ្ញុំបញ្ចប់ការបង្ហាញត្រឹមនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកា ជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

កុំអាលទាន់ធ្វើសកម្មភាពអី លោកតំណាងមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី រង់ចាំស្តាប់នូវមតិយោបល់របស់លោកមេធាវីជាតិការពារក្តីលោក អៀង សារី។

សូមអញ្ជើញលោកមេធាវី!

[១៣:៥៩:៤៩]

**លោក អាង ឧត្តមៈ**

សូមអរគុណលោកប្រធាន ហើយសូមគោរពលោក លោកស្រីចៅក្រម។

សួស្តីសហព្រះរាជអាជ្ញា សហភាគាទាំងអស់ ហើយ សួស្តីលោកអ្នកទាំងឡាយដែលចូលរួមនៅសវនាការនេះ ហើយសូមអធ្យាស្រ័យដោយបានឡើងមកកាត់ ហើយដំណើរការរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការឡើងបង្ហាញឯកសារ។

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំមានការជូនដំណឹងមួយ ហើយក៏ភ្ជាប់ទៅនឹងសំណូមពរផងដែរ ពីព្រោះវាទាក់ទងទៅនឹងការបង្ហាញឯកសាររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃនេះ។

[១៤:០០:៣៦]

ហើយយើងខ្ញុំសូមជូន សូមជម្រាបជូនដំណឹងផងដែរថា ការបង្ហាញឯកសាររបស់សហមេធាវីអន្តរជាតិដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្ញើតាមសារអេឡិចត្រូនិច ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២ វេលាម៉ោងដប់ពីរ និងសាមសិបប្រាំនាទីថ្ងៃត្រង់ ដែលមានកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី ដែលក្នុងនោះលោក អៀង សារី មិនទាន់ត្រូវបានផ្តល់លទ្ធផលឱ្យបានតទល់ចម្លើយនោះនៅឡើយ ដែលចម្លើយទាំងនោះ វាទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តិទាំងឡាយរបស់ជនជាប់ចោទ។

ខ្ញុំសូមយោងទៅលើឯកសារ១ អេឡិចត្រូនិចរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ វេលាម៉ោងពីរ និងប្រាំបីនាទីរសៀល ដែលឆ្លើយតបទៅនឹងលិខិតរបស់ក្រុមមេធាវីការពារក្តីរបស់លោក អៀង សារី ដែលបានផ្ញើចេញនៅថ្ងៃដដែលនោះ។ សារអេឡិចត្រូនិចនោះថ្លែងថា "អង្គជំនុំជម្រះសាលាដំបូងមានបំណងរំឭកដល់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីថា អនុលោមទៅតាមសេចក្តីសម្រេច (ខ្ញុំចង់និយាយថាជាសេចក្តីសម្រេចលេខ E96/7) ដែលថាកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី ដែលយកមកបង្ហាញជំនួសឱ្យការស្តាប់សក្ខីកម្មដោយផ្ទាល់មាត់ មិនអាចទទួលយកជាភស្តុតាងបានឡើយ ប្រសិនបើចម្លើយទាំងនោះទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ"។

[១៤:០២:៥០]

ហើយថ្ងៃនេះ គឺថ្ងៃនេះតែម្តង ហើយមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានអះអាងបញ្ជាក់បន្ថែមទៀតថា ភាគីត្រូវបានលើកចិត្តឱ្យប្រើប្រាស់ពេលវេលាដែលបានផ្តល់ទៅឱ្យពួកគេ

សម្រាប់ធ្វើសវនាការលើឯកសារ ដើម្បីការបង្ហាញលើឯកសារទាំងនោះ ដែលអង្គជំនុំជម្រះសាលាដំបូង មានលទ្ធភាពអាចផ្តល់តម្លៃ និងទម្ងន់ទៅលើភស្តុតាងទាំងនោះបាន។ ខ្ញុំស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាកុំអនុញ្ញាតឲ្យសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញឯកសារដែលមានលេខរៀង ទី៥ រហូតទៅដល់ទី១៥ នៃបញ្ជីរបស់ពួកគាត់ ដែលបានផ្ញើចេញនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ដដែល។ ពីព្រោះថាឯកសារទាំងនោះយើងខ្ញុំបានបញ្ជាក់ជូនហើយខាងដើម បើមិនដូច្នេះទេ វាប៉ះពាល់ដល់ អាចប៉ះពាល់ដល់លទ្ធភាព ដូចខ្ញុំបានជម្រាបជូនខាងដើមរួចហើយ។ ទោះជាសវនាការនេះមិនមែនជាសវនាការដេញដោលលើភស្តុតាង ឬគ្មានតម្លៃជាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកក្តី ក៏ប៉ុន្តែបើសិនជាយើងយកឯកសារមួយមកអានហើយ ហើយស្រាប់តែឯកសារនេះថ្ងៃក្រោយត្រូវបានជំទាស់តវ៉ាអីៗទៅ ហើយមិនលើកយកមកតទល់ ហើយអាចស្តាប់ទៅថា ជនរងគ្រោះ ឬសាក្សីមួយចំនួនអាចមានការភ័ន្តច្រឡំ។ អ៊ីចឹងខ្ញុំបាទ សូមលោកប្រធានមេត្តាទទួលយកសំណើសុំកុំឲ្យសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អានឯកសារដែលខ្ញុំបានលើកអម្បាញ់មិញនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានអីលើកឡើងតបទៅនឹងសំណើសុំរបស់មេធាវីជាតិការពារក្តីលោក អៀង សារី ដែរឬទេ?

[១៤:០៥:៣៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំចង់ឆ្លើយតប។ អ្វីដែលខ្ញុំចង់និយាយជាបឋមនោះ គឺថានៅក្នុងបញ្ជីខ្ញុំពុំមានកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះទេ គឺថាមានតែចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយមិនមែនឯកសារទាំង១០ ដែលលោកបានលើកឡើងនោះទេ។ ហើយខ្ញុំចង់បន្ថែមផងដែរថា ភាគីការពារក្តីរបស់ អៀង សារី បាននិយាយអំពីលិខិតកាលពីសប្តាហ៍មុននោះ ដែលត្រូវបានសរសេរមុនបន្ទាប់ពីបញ្ជីទី១ ដែលមុនបញ្ជីដែលវែង លោក ពេជ អង្គ អង្គាល់នោះនុះ គាត់បាននិយាយពីបញ្ជីមួយចំនួនដែលនៅក្នុងបញ្ជី ហើយសំបុត្ររបស់លោក អៀង សារី សរសេរពេលក្រោយ ហើយលោក ពេជ អង្គ បានកែប្រែបញ្ជីទាំងស្រុងតែម្តង។ ហើយនៅថ្ងៃនេះគឺថាមានបញ្ជីខ្ញុំ ដែលធ្វើយឺតពេកបន្តិចហើយ ដែលមិនមានតែ ១៣ទេ មិនមែនមានដល់១៥ឯកសារនោះទេ។ នៅក្នុងចំណោមឯកសារទាំងអស់នេះ ពុំមានឯកសារដែលនិយាយអំពីអាកប្បកិរិយារបស់ ឬក៏អំពើរបស់ជនជាប់ចោទនោះទេ ហើយនេះដែលមានសេចក្តី

ចែង និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ហើយបានចែងថា នៅពេលដែលយើងនិយាយអំពីអាកប្បកិរិយា ឬក៏អំពើរបស់សាក្សីនោះ យើងនិយាយ យើងមិននិយាយអំពីការចូលរួមផ្ទាល់ខ្លួននោះទេ។

[១៤:០៧:០៣]

ហើយមានឯកសារមួយទៀតនិយាយអំពីការចូលដោយផ្ទាល់ ហើយនិងអំពើរបស់ជនជាប់ចោទណាមួយ។ មានឧទាហរណ៍ដូចជាការសម្ភាស ឬក៏ខ្សែអាត់ វ៉ាដ្យូ ហើយមានពាក្យបណ្តឹងរបស់ដើមរដ្ឋប្បវេណីពីរនាក់ ដែលមិននិយាយអំពីអំពើរបស់ជនជាប់ចោទនោះទេ។ ហើយៗមានឧបសម្ព័ន្ធដែលជាសុទ្ធតែជា មានលក្ខណៈសត្យានុម័តិ ហើយមានអត្ថបទកាសែតមួយចំនួនដែលមិនចោទប្រកាន់ទៅលើជនជាប់ចោទទាក់ទងនឹងទង្វើ និងអាកប្បកិរិយារបស់គាត់នោះទេ។

ហើយមានឯកសារពីរទៀតដែលអាចថាចោទជាបញ្ហា គឺជាកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់គឺឯកសារ D368/2 ហើយនិងឯកសារ D199/14។ បាទ ចំពោះខ្ញុំកំណត់ហេតុស្តាប់ចម្លើយទាំងពីរនេះ មិនចោទប្រកាន់ទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះទេ។ បើសិនជាអង្គជំនុំជម្រះចង់ដកឯកសារទាំងពីរនេះចេញនោះ ខ្ញុំមិនយល់ទាស់អ្វីទេ។ ក៏ប៉ុន្តែខ្ញុំយល់ឃើញថាឯកសារផ្សេងៗទៀតមិនបានចោទប្រកាន់លើអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះទេ។

ហើយបើសិនជាមានឯកសារណាមួយដែលចោទប្រកាន់នោះ គឺថាសូមឲ្យខាងភាគីការពារក្តីនោះបង្ហាញភស្តុតាង ហើយចំពោះភាគីការពារក្តី អៀង សារី នោះ គឺថាចំពោះគាត់ប្រហែលជាពិបាកនឹងបង្ហាញថា មានឯកសារណាដែលចោទប្រកាន់។ ហើយគឺថាពាក់ព័ន្ធនោះអាចមានតែឯកសារពីរនុ៎ងទេ លោកប្រធាន។ នេះខ្ញុំចង់បង្ហាញតែប៉ុណ្ណោះឯង។

[១៤:០៩:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សួស្តីលោក លោកស្រីទាំងអស់គ្នា។ ចំណុចនេះពាក់ព័ន្ធទៅនឹងសំណើសុំព្រឹកមិញ ទាក់ទងទៅនឹងទម្ងន់ដែលត្រូវផ្តល់ជូនទៅលើយោបល់របស់ជនជាប់ចោទ ហើយក៏រួមទាំងប្រធានបទដែលយើងកំពុងជជែកគ្នានៅពេលនេះ។ ថាតើតម្លៃភស្តុតាងនោះ តម្លៃភស្តុតាងរបស់

ឯកសារចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺវាយ៉ាងម៉េច? គឺយើងត្រូវពិចារណាលើចំណុចនេះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានខ្ញុំឆ្ងល់ណាស់ ហេតុអ្វីបានជាដំណាក់កាលនេះទៅហើយ គេនៅតែនិយាយអំពីតម្លៃជាភស្តុតាងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។ សូមឲ្យអង្គជំនុំជម្រះអ្នកវាយតម្លៃ កំណត់តម្លៃខ្លួនឯងទៅ ហើយខ្ញុំយល់ឃើញថា មិនមានការគោរពក្នុងការនិយាយថា នេះសាក្សី -- សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះមិនមានតម្លៃជាភស្តុតាងនោះទេ។ ហើយអ៊ីចឹងសូមឲ្យអង្គជំនុំជម្រះហ្នឹង អង្គជំនុំជម្រះធ្វើការសម្រេចលើតម្លៃនេះ ដោយខ្លួនឯងទៅចុះ។

[១៤:១០:៥៦]

**ប្រធានអង្គជំនុំ៖**

បញ្ហាអីទៀត? លោកមានបញ្ហាអីទៀតទេ?

**លោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

ខ្ញុំមានលោកប្រធាន។ ខ្ញុំគ្រាន់តែចង់ឆ្លើយតបដោយខ្លី ខ្ញុំមិនមែននិយាយថា ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនមានតម្លៃភស្តុតាងនោះទេ។ ខ្ញុំមិនដែលនិយាយដូច្នេះនោះទេ ខ្ញុំគ្រាន់តែស្នើសុំអង្គជំនុំជម្រះថា តើទម្ងន់ដែលត្រូវផ្តល់ឲ្យចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺមានទម្ងន់ប៉ុនណា? ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមកចូលខ្លួននៅក្នុងតុលាការ។ ខ្ញុំសូមបញ្ជាក់ថា អង្គជំនុំជម្រះគឺមានឆន្ទៈក្នុងការផ្តល់ឲ្យយើងក្នុងការកំណត់ទៅលើទម្ងន់ នៃចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសទៅលើចម្លើយ និងមតិយោបល់របស់ជនជាប់ចោទ។ អង្គជំនុំជម្រះនឹងពិចារណាទៅលើចំណុចនេះជាលម្អិត ហើយខ្ញុំនិយាយនេះ គឺយោងទៅលើប្រតិចារឹកកាលពីព្រឹកមិញ។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា ខ្ញុំមិនបាននិយាយថា ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនមានទម្ងន់ តម្លៃជាភស្តុតាងនោះទេ។ គ្រាន់តែខ្ញុំចង់ដឹងតែប៉ុណ្ណោះថា តើបទដ្ឋាននៃតុលាការនេះ គឺអនុវត្តយ៉ាងម៉េចចំពោះទម្ងន់ដែលត្រូវផ្តល់ទៅលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នេះក៏ពាក់ព័ន្ធទៅនឹងសំណើររបស់ខ្ញុំកាលពីព្រឹកមិញផងដែរលោកប្រធាន។

[១៤:១២:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញសហមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បានអះអាងថា ឯកសាររបស់គាត់ចុងក្រោយនេះ មានតែ១៣ទេ គឺដកឯកសារពីរចេញ គឺឯកសារ D199/14 និង D368/2។ តាមពិតឯកសារដែលខ្ញុំរៀបរាប់តាំងពីទី៥ រហូតដល់ទី១៥ នេះ គឺឯកសារទាក់ទងនឹងសាក្សីពីរនាក់នុ៎ង។ ដូច្នេះមិនអាចដកៗយកតែកំណត់ហេតុសាកសួរចេញ ហើយដករក្សាពាក្យបណ្តឹងហ្នឹងនៅដដែលទេ ហើយឯកសារប៉ុន្មានទាំងអស់ គឺទាក់ទងតែសាក្សីពីរនាក់ហ្នឹងដែលយើងខ្ញុំមិនទាន់មានឱកាស ដូចខ្ញុំជម្រាបអំមិញហើយថា តទល់នឹងឯកសារទាំងនោះបាននៅឡើយ។ អ៊ីចឹងបើសិនជាដកតែពីរនេះចេញ ហើយនៅប៉ុន្មានទាំងអស់ទៀត វាអត់ៗន័យ អត់ខ្លឹមសារទេ។

អ៊ីចឹងខ្ញុំសូមៗរក្សាដដែល ឯកសារពីលេខ ១៥ ដល់ អ៎! សូមទោស ពីលេខ៥ ដល់លេខ១៥ ហ្នឹងគឺសូមឲ្យសហមេធាវីមិនបាច់អានទេ។ សូមអរគុណ។

[១៤:១៣:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំចង់ឲ្យច្បាស់ ថាយើងនិយាយអំពីបញ្ជីតែមួយដែលថានឹងបង្ហាញខាងមុខនេះ ខ្ញុំដូចជាមិនច្បាស់ទាល់តែសោះ។ តើភាគីការពារក្តីរបស់លោក អៀង សារី អាចជម្រាបជូនតុលាការថា ខ្លួនចង់សំដៅលើបញ្ជីមួយណា? តើជាបញ្ជីចុងក្រោយដែលៗផ្ញើជូនដោយមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ៗជាបញ្ជីផ្សេងទៀតដែលថា ខ្លួនខាងការពារក្តីលោក អៀង សារី នេះចង់ជំទាស់នេះ? បាទ ខ្ញុំហាក់ដូចជាយល់ថា កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់នោះត្រូវបានដកចេញពីបញ្ជីបឋមហើយ។

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធានសាថ្មី។ ហើយឯកសារដែលខ្ញុំលើកមកនេះ គឺឯកសារៗ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្ញើ តាមរយៈសារអ៊ីម៉ែល ចុះថ្ងៃទី១១ ខែតុលា នេះឯង។ ក្នុងនោះបញ្ជីឯកសារមាន១៥ តែសម្រាប់បញ្ជីឯកសារថ្មី ហើយខ្ញុំអត់បាន ឬមួយ ខ្ញុំអត់ទាន់បានទទួល? អំមិញដើមបណ្តឹងរដ្ឋប្បវេណីថា នៅសល់តែ១៣ទេ ដកពីរ។ អ៊ីចឹងឯកសារនេះយោង ហើយភ្ជាប់ជាមួយនឹងឯកសារផ្ញើ

តាមសារអេឡិចត្រូនិច ចុះថ្ងៃទី១១ ខែតុលា ហ្នឹងឯង។ សូមអរគុណ។

[១៤:១៥:៣៣]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ប្រហែលជា--

**ប្រធានអង្គជំនុំ៖**

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមបំភ្លឺស្ថានភាពនេះបន្តិចលោកប្រធាន។ ខ្ញុំសូមអភ័យទោស ដែលបង្កឲ្យមានស្ថានភាពបែបនេះ ពីព្រោះថាយើងបានផ្ញើបញ្ជីទៅជាច្រើនជាបន្តបន្ទាប់ ជាមួយនឹងបញ្ហារយៈពេលមួយចំនួនដែលយើងអវត្តមានរយៈពេលកន្លងផុតមកនេះ។ គឺថាបញ្ជីទី១ គឺជាបញ្ជីដែលធ្វើដោយក្រោមសំណើរបស់លោក អង្គ ពេជ បញ្ជីនេះវែង ហើយក្នុងបញ្ជីនេះមានកំណត់ហេតុស្ដាប់ចម្លើយសាក្សី ហើយបន្ទាប់ពីមានលិខិតរបស់លោក អៀង សារី ហើយនិងបន្ទាប់ពីមូលហេតុផ្សេងៗទៀតនោះ បញ្ជីនោះក៏បានផ្ញើម្ដងទៀត ដូចដែលបញ្ជីដែលបានផ្ញើដោយព្រះរាជអាជ្ញាជាតិផងដែរ។ ហើយខ្ញុំខ្លួនឯងផ្ទាល់នេះ ខ្ញុំបានផ្ញើបញ្ជីឯកសារចំនួន១៥ នៅថ្ងៃទី១១ ខែតុលា ហើយខ្ញុំបានដកពីរឯកសារចេញហើយ ហើយខ្ញុំបានផ្ញើទៅទៀត ឯកសារមួយទៀត ដែលមាន១៣ឯកសារ ដែលខ្ញុំទើបតែលើកឡើងអម្បាញ់មិញនេះ។ នៅក្នុងបញ្ជីដែលមាន១៣ឯកសារនេះ ពុំមានកំណត់ហេតុស្ដាប់ចម្លើយសាក្សីនោះទេ មានតែគឺថា មានកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីតែពីរទេ ដែលអាចចោទជាបញ្ហានោះ។ ហើយមួយទៀត គឺថាមានបញ្ជីរបស់លោក ពេជ អង្គ ដែលមានបញ្ជី -- ដែលលោក ពេជ អង្គ ផ្ញើទៅនោះ ហើយគាត់នឹងលើកឡើងបន្តិចទៀតនេះ ហើយមិនមានជាបញ្ហាចោទអីនោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ហើយសូមឲ្យក្បោះក្បាយ ហើយឲ្យចប់តែម្ដងពេលហ្នឹងទៅ ដើម្បីងាយអង្គជំនុំជម្រះនឹងកាត់បន្ថយពេលវេលា ដើម្បីថយទៅពិចារណាសម្រេចលើបញ្ហានេះ។ បើដើបចុះដើបឡើងៗអ៊ីចឹងជា១០ដងទៀត ទំនងជាមិនដាច់ស្រេចទេ ស្ដាប់បញ្ហានេះឲ្យបានច្បាស់ ហើយលើកតែម្ដងទៅជំទាស់តែម្ដងទៅវាចប់ ហើយវាត្រឹមត្រូវតាមគោលការណ៍ណែនាំពីមុនៗមកផង។

[១៤:១៨:០៥]

**លោក អាង ឧត្តម៖**

បាទ សូមអរគុណ ហើយសូមអធ្យាស្រ័យផងបាទទាន ដោយសារតែចង់លឿនដែរ ប៉ុន្តែអាចច្រឡំច្របូកច្របល់ខ្លះ។ ឯកសារដែលដើមបណ្ដឹងរដ្ឋប្បវេណីគាត់ថា ដកចេញអំមិញ សូមអភ័យទោស ខ្ញុំទើបបានទទួលសារ ដែលខាងដើមបណ្ដឹងរដ្ឋប្បវេណីបានទទួល បានផ្ញើមកអំមិញហ្នឹង ខ្ញុំបានឃើញចុះនៅថ្ងៃហ្នឹងឯងម៉ោងពីរដប់ពីរនាទី។ អ៊ីចឹងសូមអធ្យាស្រ័យ ដោយសារមុនហ្នឹងអត់បានទទួល វាពេលចុងក្រោយថ្មីៗពេក។

ឯកសារដែលថា ដកចេញខ្ញុំមើលឯកសារថ្មីទើបនឹងផ្ញើមកម៉ោងពីរដប់ពីរនាទីថ្ងៃនេះគឺ D368/2 គឺនៅដដែល គឺជាកំណត់ហេតុសាកសួររបស់ភាគីរដ្ឋប្បវេណី ហើយនិង D199/14 គឺនៅដដែលទៅវិញ។ មុននឹងខ្ញុំស្ដាប់ឮថា ឯកសារពីរហ្នឹងដកចេញ ប៉ុន្តែឥឡូវចូលឯកសារពីរហ្នឹងមកវិញដដែល។ សូមបញ្ជាក់ថា សាក្សីពីរនេះគឺពាក់ព័ន្ធដោយផ្ទាល់ ពិនិត្យមើលទៅគឺ ដោយសារមានឈ្មោះសាក្សីពីរនាក់ហ្នឹង វាពាក់ព័ន្ធទៅនឹងករណីរបស់លោក អៀង សារី ខ្លាំងដែរ ហើយដោយលោក អៀង សារី អត់ទាន់បានពិនិត្យមើលផងនោះ តើយកឯកសារនោះមកយ៉ាងម៉េច? អានេះខ្ញុំគ្រាន់តែជម្រាបជូនតែប៉ុណ្ណឹង។ ខ្ញុំមិនចង់លើកឈ្មោះទេ ក្រែងលោពីព្រោះក្នុងនេះអត់មានដាក់លេខ អត់មានលេខកូដ ខ្លាចប៉ះពាល់ដល់ការសម្ងាត់របស់តុលាការ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៤:១៩:៥៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើភាគីដើមបណ្ដឹង -- ភាគីការពារលោក អៀង សារី នេះចង់ជំទាស់តែឯកសារពីរនេះទេឬ គឺថា D368/2 ហើយនិងឯកសារ D199/14 ដែលសហមេធាវីនាំមុខនេះ បានបង្ហាញអំមិញ។ តើមានតែឯកសារពីរហ្នឹងទេឬ ដែលលោកចង់ជំទាស់នោះ? ហើយបើសិនមានជាឯកសារផ្សេងទៀត ដែលលោកចង់ជំទាស់នោះ តើលោកសំអាងលើមូលហេតុអ្វីដែរ?

[១៤:២០:២៩]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។

ឯកសារដែលយើងចង់ជំទាស់មិនមែនមានតែពីរហ្នឹងទេ។ ពីរនេះ គឺជាសាក្សី ជាឈ្មោះសាក្សី -- ដែល -- សូមទោសមិនមែនសាក្សី ជាដើមបណ្ដឹងរដ្ឋប្បវេណី ទាំងពីរនាក់ហ្នឹង ហើយឯកសារ១៣ ផ្សេងទៀត វាទាក់ទងនឹងសាក្សីហ្នឹងទាំងអស់ អ៎! សូមទោស ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរនាក់ហ្នឹង។ អ៊ីចឹង យើងមិនអាចបដិសេធមួយ ហើយទុកមួយទេ គឺយើងបដិសេធនឹងបញ្ជី បើខ្ញុំយោងទៅនឹងបញ្ជីមុននេះ គឺបញ្ជីទី១ ដែលមាន១៥នាក់។ ១៥នាក់សាក្សី -- សូមៗទោស ១៥ឯកសារ ហើយបញ្ជីថ្មីនេះ ១៣ឯកសារ។ គឺខ្ញុំសូមតវ៉ា សូមមេត្តាសូមកុំអានឯកសារពីលេខរៀងទី៥ ទៅដល់លេខ១៥ ហ្នឹង គឺមានចំនួន១១ឯកសារ បើយោងទៅតាមឯកសារដែលផ្ញើមុននេះ។ ចំណែកឯកសារផ្ញើថ្មីនេះ ខ្ញុំអត់ទាន់បានពិនិត្យមើល តើឯកសារណាត្រូវបានដកចេញទេ។ នេះ សូមមេត្តាជ្រាប សូមអរគុណ។

[១៤:២១:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២១:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន គឺថាមិនមែនជាគ្រប់គ្រាន់នោះទេ ថាមិនមែនជាការត្រឹមត្រូវទេ ដែលថាយើងជំទាស់ឯកសារហើយ អត់ឱ្យមូលហេតុ។ ហើយមូលហេតុដែលសមស្របនោះ ត្រូវបង្ហាញថាឯកសារដែលយើងកំពុងតែបង្ហាញនេះ គឺថាចោទប្រកាន់លើ ពាក់ព័ន្ធលើអាកប្បកិរិយា ហើយនិងអំពើរបស់ជនជាប់ចោទ។ ក៏ប៉ុន្តែក្នុងបញ្ជីខ្ញុំនេះ ក្រៅពីឯកសារពីរនុ៎ង ពុំមានឯកសារណាផ្សេងទៀត ទាក់ទងទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះទេ។ ហើយក្នុងសវនាការមុននោះ គឺថាតុលាការបានអនុញ្ញាតឱ្យយើងបង្ហាញចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ នេះជាអ្វីដែលយើងចង់ធ្វើនៅថ្ងៃនេះ ហើយចម្លើយទាំងអស់នេះមិនពាក់ព័ន្ធ ឬក៏ចោទប្រកាន់ទៅលើអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទទេ ហើយនៅក្នុងឧបសម្ព័ន្ធនោះ ក៏ពុំមានដែរ។

ដូច្នេះ ខ្ញុំសូមស្នើថា កុំឱ្យខាតពេលវេលាច្រើនពេកនោះ សុំឱ្យមេធាវីរបស់លោក អៀង សារី គឺថានៅពេលណាមួយ នៅពេលដែលគាត់យល់ឃើញថា មានឯកសារណាដែលថា និយាយពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់លោក អៀង សារី នេះ សូមឱ្យគាត់ក្រោកឡើងជំទាស់ទៅ។ ហើយអ៊ីចឹង

យើងមិនអាចនិយាយអំពីបញ្ជី ហើយយើងមិនចូលទៅដល់ព័ត៌មានលម្អិតនៅក្នុងឯកសារនៃបញ្ជីនោះទេ លោកប្រធាន។

[១៤:២៣:២៤]

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីថ្មីទេ លោកមេធាវី? យើងបានជម្រាបលោកហើយអំមិញ តើលោកមានបញ្ហាអីថ្មីទៀតទេ? បើមានថ្មី ហើយប្លែកពីអ្វីដែលលោកបាននិយាយរួចហើយ សូមលោកនិយាយ យើងនឹងអនុញ្ញាតឲ្យនិយាយចុងក្រោយ។ បើពុំដូច្នោះទេ គឺលោកនឹងដើបឈរ ដើបអង្គុយហ្នឹង ប្រហែលជា១០ដង ឬ១០០ដង ទំនងជាមិនទាន់ចប់ មិនអាចចប់ទេ បើធ្វើការងាររបៀបនេះ។

[១៤:២៣:៥០]

**លោក អាង ឧត្តម៖**

សូមទោសលោកប្រធាន ដោយសារឯកសារទើបតែផ្ញើទៅមកៗ ថ្មីៗពេក រៀបចំអត់ទាន់។ ខាងខ្ញុំ ក៏ទើបផ្ញើថ្ងៃហ្នឹង ខាងណោះ ក៏ទើបផ្ញើមកអំមិញដែរ។ ដូច្នេះ មិនអាចដោះស្រាយបានទាន់ពេលវេលា។ ឥឡូវ ខ្ញុំជ្រើសរើសយកជម្រើសទី របស់ខ្ញុំចុះ ព្រោះជម្រើសរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអំមិញគឺថា ចាំគាត់អានឯកសារហើយ ជំទាស់យកទៅតែម្ដងទៅ។ តែខ្ញុំចង់ជូនឈ្មោះឯកសារដែលខ្ញុំសុំឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមិនអាននោះ គឺផ្អែកទៅបញ្ជីរបស់គាត់ដាក់។

ទី១ ឯកសារ D22/289, ឯកសារលេខទី៤ D368/2, ឯកសារលើលេខរៀងទី៥ D22/289.21, ឯកសារលើលេខរៀងទី៦ D22/289.11, ឯកសារលេខរៀងទី៧ D22/289.14, ឯកសារលើលេខរៀងទី៨ D22/44, ឯកសារលើលេខរៀងទី៩ D199/14, ឯកសារលើលេខរៀងទី១០ D22/44.11 និងឯកសារលើលេខរៀងទី១១ D22/44.13។ សូមអរគុណ។

[១៤:២៦:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយដោយសង្ខេបទេ គឺថាយើងត្រូវតែសង្កេតឃើញថាក្រៅពីឯកសារទាំងពីរនេះ ដែលជាកំណត់ហេតុស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះ ភាគី

ការពារក្តីមិនមានសមត្ថភាពក្នុងការបង្ហាញពីមូលហេតុ ថាហេតុអីក៏ឯកសារដែលគាត់ជំទាស់នោះ មិនត្រូវ មិនយកមកបង្ហាញនោះទេ បើសិនជាអត់មានសមត្ថភាពទេ គាត់មិនអាចជំទាស់បានទេ ហើយត្រូវតែបង្ហាញពីមូលហេតុជាក់លាក់ដើម្បីជំទាស់។ ហើយខ្ញុំគិតថា ឥឡូវនេះ បើសិនគាត់ជំទាស់ឥឡូវនេះ ប្រហែលជាពុំមែនជាវិធីសាស្ត្រល្អនោះទេ ហើយនិយាយមិនចេះចប់មិនចេះហើយទេ កាត់គ្នាទៅវិញទៅមកនោះ។ អ៊ីចឹងសូមឲ្យដល់ពេលបង្ហាញ បើសិនឃើញថាមានមូលហេតុជាក់លាក់ណាមួយ ហើយមានភាពស៊ីសង្វាក់ណាមួយ អ៊ីចឹងពេលនោះគាត់ជំទាស់បាន។ បាទ សូមអរគុណលោកប្រធាន។

[១៤:២៧:១២]

**ប្រធានអង្គជំនុំ៖**

ម៉េចហើយមានការអីទៀតទៅ? មួយហើយមួយទៀត ហើយកំពុងតែប្រឈមនឹងបញ្ហាយឺតយ៉ាវ ហើយដំណើរទៅប្រព្រឹត្តទៅអ៊ីចឹងណេះ! ដូចជាខុសពីការណែនាំឆ្ងាយណាស់។ ភាគីនីមួយៗត្រូវលើកឲ្យបានព្រមគ្នា គាំទ្រគ្នា ឬក៏យ៉ាងម៉េច ដើម្បីឲ្យដំណើរការហ្នឹងវាឆាប់រហ័ស។ បែរជាភាគីមួយនិយាយចប់ហើយ ភាគីបកត្រឡប់ទៅខាងឆ្លើយតប ឥឡូវមកភាគីមួយទៀត ដែលជាភាគីដាក់បញ្ហា។

សូមអញ្ជើញ! ឲ្យមួយទៀតណ៎ះ ចំណាយពេលខ្លីបានហើយ!

**លោក អាកទួរ វែកគែន៖**

បាទ លោកប្រធានខ្ញុំគ្រាន់តែរំឭកទៅសហព្រះរាជអាជ្ញាថា យើងបានទទួលបញ្ជីចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ៣នាទីមុននេះនោះទេ។ គឺថាដូច្នេះនៅពេលដែលនិយាយថា ខាងការពារក្តីពុំមានសមត្ថភាពនោះ ខ្ញុំឆ្ងល់ដែរ ថាតើខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសមត្ថភាពដែរឬទេ បើផ្ញើបញ្ជីតែ៣នាទីមុននេះ? អ៊ីចឹងគឺថាយើងគិតពីរបៀបធ្វើការដែរ គឺថានៅម៉ោងដប់បួនដប់ប្រាំនាទី ដែលពេលដើមបណ្តឹង -- មេធាវីដើមបណ្តឹងនេះបានចោទសំណួរ។ អ៊ីចឹងលោកសហព្រះរាជអាជ្ញា សូមលោកយោគយល់ផង។

[១៤:២៨:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៣:០៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អង្គជំនុំជម្រះបានទទួលពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី នូវបញ្ជីមួយដែលជាបញ្ជីមានឯកសារចំនួន១៥ ហើយទទួលបាននៅថ្ងៃទី១១ ខែតុលា។ ភាគីទើបតែទទួលបញ្ជីនេះនៅម៉ោងដប់បួន ឬក៏ម៉ោងដប់បួនជាងបន្តិចបន្តួច នូវបញ្ជីមួយដែលមានឯកសារចំនួន១៣។ ដូច្នេះ យើងពុំមានពេលពិនិត្យឯកសារបញ្ជីឯកសារនេះជាលម្អិតនោះទេ ប៉ុន្តែយើងចង់ដឹងថាតើបញ្ជីឯកសារទាំង១៣នេះ ត្រូវបានដកស្រង់ចេញពីបញ្ជីដែលមានឯកសារចំនួន១៥។ បើសិនជា ឬក៏នៅក្នុងបញ្ជីឯកសារទាំង១៣នេះមានបញ្ជី -- មានឯកសារបន្ថែមផ្សេងទៀត បើសិនជាយ៉ាងដូច្នេះ សូមឲ្យ -- បើសិនជាយ៉ាងដូច្នេះមែន សូមឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជូនដំណឹងដល់ភាគី ហើយនិងអង្គជំនុំជម្រះជាមុន។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកចៅក្រម លោកពិតជាត្រឹមត្រូវហើយ យើងត្រូវតែជូនដំណឹងដល់ភាគីឲ្យបានមុន។ បញ្ជីនៃឯកសារទាំងបីនេះ គឺថាដូចបញ្ជីឯកសារទាំង១៥នោះ ដែលគ្រាន់តែដកចេញពីឯកសារនោះទេ ពីព្រោះថាយើងគ្រាន់តែដកចេញតែពីរឯកសារតែប៉ុណ្ណោះលោកចៅក្រម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ នៅក្នុងបញ្ជីឯកសារ១៣ នេះគឺថាលោកស្រីអាចឲ្យដកឯកសារចំនួនពីរទៀត គឺថាជាកំណត់ហេតុស្តាប់ចម្លើយសាក្សី?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

បើសិនជាតុលាការយល់ឃើញថា ឯកសារកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនេះពាក់ព័ន្ធនឹងអំពើ ហើយនិងអាកប្បកិរិយារបស់ជនជាប់ចោទនោះ អង្គជំនុំជម្រះអាចដកចេញបានបើសិនជាចង់ដកឯកសារទាំងពីរហ្នឹង។ អ៊ីចឹងបើថា នៅចុងក្រោយអាចយកតែ១១ ឯកសារក៏បានដែរលោកប្រធាន។

[១៤:៣៥:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៥:៤៨]

**លោក អាកទួរ វែកកែន៖**

លោកប្រធាន!

E1/134.1

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ?

**លោក អាកទូរ វែកគែន៖**

លោកប្រធាន គ្រាន់តែចង់បំភ្លឺអំពីការលំបាករបស់យើងខ្ញុំ គឺថាគេទើបនឹងប្រាប់យើងថា មានភស្តុតាងមួយដែលខុសពីអ្វីដែលខាងសហភាគីខ្ញុំនេះបានលើកឡើង គឺថាឯកសារនៅក្នុងបញ្ជីចុងក្រោយនោះមិនមាននៅក្នុងបញ្ជី ដែលថាមានឯកសារទាំង១៥នោះទេ។ គឺថាបញ្ជីអម្បាញ់មិញនេះគឺថាឯកសារលេខ១១ លោកប្រធាន -- លេខ១២ សូមទោស។ ខ្ញុំនៅក្នុងបញ្ជីដែលមានឯកសារទាំង១៥នោះ ខ្ញុំមិនឃើញមានឯកសារ ដែលមានលេខកូដ E3/1713។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមឆ្លើយតប។ ខ្ញុំបង្ហាញឯកសារ D22/289.17 នេះជាសៀវភៅ ហើយជាភ្ជាប់ទៅនឹងចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីមួយដែលមានលេខៗ D22/299.17។

[១៤:៣៧:២៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៩:១០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះនឹងយោងទៅនឹងបញ្ជីដែលធ្វើឡើង ដែលដាក់ឡើង ហើយនិងជូនដំណឹង នៅថ្ងៃទី១១ តុលា។ នេះគឺជាឯកសារដែលជូនដំណឹងក្នុងពេលសមស្របដល់ភាគីទាំងអស់ ក៏ប៉ុន្តែទន្ទឹមនឹងនោះនៅក្នុងបញ្ជីនេះ យើងនឹងដកឯកសារដែលលែងមាននៅក្នុងឯកសារដែលទើបតែនឹងដាក់អម្បាញ់មិញនេះ។ ដូច្នេះ យើងនឹងទុកតែ ១៣ឯកសារ តែប៉ុណ្ណោះ ហើយយើងនឹងដើម្បីកុំឲ្យខាតពេលវេលានោះ យើងនឹងដកចេញពីបញ្ជីចុងក្រោយនេះ នូវកំណត់ហេតុស្តាប់ចម្លើយពីរបន្ថែមពីលើហ្នឹងទៀត។

បាទ ខ្ញុំសូមទាក់ទាញចំណាប់អារម្មណ៍ដើមបណ្ដឹងរដ្ឋប្បវេណី ថាយើងខាតពេលវេលាច្រើន បើសិនជាដើមបណ្ដឹងរដ្ឋប្បវេណីបានជូនដំណឹងទៅភាគីទាំងអស់នោះ ក្នុងពេលសមស្របវិញនោះ បញ្ជី

ឯកសារដែលខ្លួនចង់ប្រើនៅពេលនោះ មិនមានបញ្ហាកើតឡើងនោះទេ។ ដូច្នេះ សូមឲ្យ កុំឲ្យមានបញ្ហានេះ កើតឡើងទៀត ហើយវាធ្វើឲ្យប៉ះពាល់ដំណើរការល្អដល់តុលាការនេះ។

[១៤:៤១:០២]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវពេលនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:១១ នាទី)*

[១៥:១១:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់បង្ហាញឯកសារ ចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបញ្ជាក់បន្ថែមលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានសម្រេចលើសេចក្តីជំទាស់របស់មេធាវីជាតិការពារក្តីឲ្យលោក អៀង សារី លើឯកសារទាំងឡាយដែលមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ដែលមានបញ្ហាមុនពេលឈប់សម្រាកអម្បាញ់មិញនេះ។ ហើយបន្ទាប់មកគឺឲ្យលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដដែលសម្រេចលើសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា ពាក់ព័ន្ធនឹងទម្ងន់ និងតម្លៃនៃភស្តុតាងដែលគាត់ចង់ឲ្យអង្គជំនុំជម្រះបញ្ជាក់ជូនគាត់ជាបន្ថែមទៀត ទៅលើសេចក្តីសម្រេចរបស់លោកស្រីចៅក្រម -- របស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចដោយលោកស្រីចៅក្រមកាលពីពេលមុន។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ បាទ ជាបឋមខ្ញុំសូមធ្វើការបំភ្លឺទាក់ទងទៅនឹងសំណើរបស់លោក

មេធាវីរបស់លោក អៀង សារី។ យើងកាលអម្បាញ់មិញនេះ គឺថាលើសពីឯកសារចំនួន១១ ដែលនឹងបង្ហាញដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយឯកសារទាំង១១នេះ គឺថា ខាងមេធាវី អៀង សារី នេះចង់ជំទាស់លើសហ្នឹងទៅទៀត។ ការជំទាស់បន្ថែមនេះ អង្គជំនុំជម្រះមិនទាន់បានធ្វើសេចក្ដីសម្រេចនោះទេ ក៏គ្រាន់តែបានកត់សម្គាល់ថា មានការជំទាស់ជាលក្ខណៈទូទៅមួយ ដែលបង្ហាញថាឯកសារទាំងអស់នេះ អាចទាក់ទងទៅនឹងធាតុផ្សំភស្តុតាង អំពីអំពើ ហើយនិងអាកប្បកិរិយារបស់ជនជាប់ចោទ។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ ការជំទាស់ទាំងអស់នេះមិនទាន់ត្រូវបានបញ្ជាក់ឲ្យច្បាស់លាស់នោះទេ។

ដូច្នេះអង្គជំនុំជម្រះមិនអាចចេញសេចក្ដីសម្រេចមួយ ឲ្យបានច្បាស់លាស់នោះទេ ហើយនឹងធ្វើសេចក្ដីសម្រេចនៅពេលក្រោយទៀត នៅពេលខ្លួនចេញសាលក្រម ហើយនឹងបង្ហាញថាតើអង្គជំនុំជម្រះចង់យោងទៅនឹងឯកសារភស្តុតាងទាំងអស់នេះដែរឬអត់នោះ?

[១៥:១៤:៥៨]

ឥឡូវនេះទាក់ទងទៅនឹងសំណើរបស់មេធាវីរបស់លោក នួន ជា ទាក់ទងទៅនឹងគោលជំហររបស់តុលាការអំពីតម្លៃភស្តុតាង ហើយនិងសេចក្ដីអត្ថាធិប្បាយដែលធ្វើដោយជនជាប់ចោទណាម្នាក់នៅក្នុងសវនាការយើងនេះ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ការចង្អុលបង្ហាញដែលធ្វើឡើងដោយលោកស្រីចៅក្រម ខាតវ៉ាយថ៍ ជូនមុខឲ្យតុលាការទាំងអស់ -- ចៅក្រមទាំងអស់នៅតែមានសុពលភាពនៅឡើយ។ អង្គជំនុំជម្រះសូមរំឭកផងដែរថា តម្លៃជាភស្តុតាងនៃសេចក្ដីអត្ថាធិប្បាយរបស់ជនជាប់ចោទ និង ក៏ដូចជាភស្តុតាងផ្សេងទៀតដែរ ដែលបង្ហាញនៅលើនៅក្នុងសវនាការនឹងត្រូវការវាយតម្លៃអនុលោមតាមវិធានផ្ទៃក្នុងនៅពេលដែលអង្គជំនុំជម្រះធ្វើសេចក្ដីសម្រេច ចេញសាលក្រម។ ហើយអង្គ -- សាលដីកា -- សាលក្រមនេះនឹងមានសំអាងហេតុត្រឹមត្រូវ។

[១៥:១៦:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការដាក់បង្ហាញឯកសារភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីដើមបណ្តឹងរដ្ឋប្បវេណី និង សាធារណជន។ ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការបង្ហាញឯកសារមួយចំនួន។ ឯកសារដែលយើងខ្ញុំបានដាក់ជូនលោកប្រធាន ជាការពិតនៅក្នុងបញ្ជីទី១ គឺមានចំនួនច្រើន ហើយខ្ញុំក៏បានដក ជាពិសេសពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីមួយចំនួន។ ហើយនៅក្នុងចំណោមឯកសារដែលនៅសេសសល់នេះ ខ្ញុំនឹងមិនមានចេតនានៅក្នុងការបង្ហាញឯកសារទាំងអស់នោះទេ គឺបង្ហាញមួយចំនួនតូចនៅក្នុងចំណោមទាំងអស់នោះ ដោយសារថាឯកសារជាច្រើននៅក្នុងចំណោមឯកសារដែលខ្ញុំបានស្នើនោះ គឺត្រូវបានបង្ហាញរួចហើយដោយការិយា-ល័យសហព្រះរាជអាជ្ញា។ ដូច្នេះឯកសារដែលខ្ញុំនឹងបង្ហាញ គឺមានមួយចំនួនតូចតែប៉ុណ្ណោះ។ ឯកសារដែលខ្ញុំបង្ហាញនេះ គឺមានជាឈុតនៃវីដេអូ ហើយនិងឯកសារជាសៀវភៅ ហើយដែលនិយាយអំពីទំនាក់ទំនង -- រចនាសម្ព័ន្ធទំនាក់ទំនង និងនិយាយអំពីរចនាសម្ព័ន្ធផ្នែករដ្ឋបាលនៃបក្សកុម្មុយនីស្តកម្ពុជា។

[១៥:១៧:៥២]

ជាដំបូង ខ្ញុំនឹងសូមអនុញ្ញាតលោកប្រធានដើម្បីបង្ហាញនូវឯកសារដែលជាឈុតវីដេអូ មួយដែលជាបទសម្ភាសន៍ជាមួយលោក នួន ជា ដែលមានលេខឯកសារ E186.1R ដែលមានចំណងជើងថាជាភាសាអង់គ្លេស "*អេនីមី អូហ្វ ដឺ ភីបផូល* –សត្រូវរបស់ប្រជាជន" ហើយខ្ញុំនឹងមិននិយាយអំពីឯកសារនោះជាឯកសាររបស់អ្នកណា -- ឯកសារនោះផលិតឡើងដោយអ្នកណាទេ។ ហើយដូច្នេះសូមលោកប្រធានអនុញ្ញាតឲ្យមន្ត្រីរបស់តុលាការបញ្ចាំងឯកសារនេះ ហើយជាដំបូងដោយចាប់ផ្តើមឈុតវីដេអូទី១។ បាទ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

ផ្នែក អាយ.វី បង្ហាញវីដេអូ លើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ!

**លោក ពេជ អង្គ៖**

បាទ សូមបញ្ជាក់ថែមបន្តិច នៅឯកសារនោះ គឺជាឯកសារដែលមាន ដែលជាកិច្ចសម្ភាសន៍ជាមួយលោក នួន ជា ដែលមានលេខ E186.1R ដែលនៅក្នុងឈុតនោះ គឺចាប់ផ្តើមពីនាទីទី៩ វិនាទី៤១ រហូតដល់នាទី១១ វិនាទីទី១០។ ហើយនេះគឺជាឈុតទី១ ដែលខ្ញុំបានជូនរួចហើយទៅអ្នកមន្ត្រីខាង

អាយ.វី។ សូមលោកមន្ត្រីផ្នែកខាង អាយ.វី ជួយបង្ហាញឯកសារ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងខាងផ្នែកសោតទស្សន៍មើល៍ថាតើមានបញ្ហាអី?

[១៥:២០:៥៤]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព "សត្រូវរបស់ប្រជាជន")*

*"ខ្ញុំទេ ត្រូវធ្វើលេខាបក្ស ពីព្រោះអត់ពី តាទូ ទៅ តាទូ គាត់ជាលេខាណ៎ា លេខា ហើយខ្ញុំក៏អ្នក -- អំអង្គាល់នុំងខ្ញុំជាអនុគាត់ អនុលោក តាទូ ណ៎ា។ ពីព្រោះ ខ្ញុំសង្កេតឃើញអ៊ីចេះ ប៉ុល ពត ហ្នឹងគាត់មានលក្ខណៈឯករាជ្យ។ ហើយគាត់មានសមត្ថភាពក្នុងការវិភាគ ក្នុងការអីៗ។ ហើយពេលនោះណ៎ យើងនៅត្រូវការបញ្ញាជនមួយចំនួនដែរ ដើម្បីគេចូលរួមក្នុងការតស៊ូ។ ដូច្នោះបានជាខ្ញុំយល់ឃើញថា ខ្ញុំមិនមែនជា -- ខ្លះគេថាខ្ញុំបញ្ញាជនដែរ ប៉ុន្តែមិនមែនទេ ខ្ញុំបញ្ញាជនថ្នាក់ក្រោមណ៎ា។ ដូចអ៊ីចុះបានជាខ្ញុំគិតអ៊ីចឹង បានខ្ញុំទៅប្រាប់ ប៉ុល ពត ថាក្នុងសភាពការណ៍បច្ចុប្បន្ននេះណ៎ា ខ្ញុំទទួលនាទីជាលេខាមិនសមរម្យទេ មិនបានចម្រើនដល់បក្សទេ។ ស្នើសមមិត្តទទួលយកភារកិច្ចហ្នឹងទៅ ឲ្យ ប៉ុល ពត ទទួលយកភារកិច្ចជាលេខាទៅ។ គាត់គិតមួយសន្ទុះ គិតមើល គាត់គិតវិភាគអីមើល បានគាត់ថា មានអីបើថាអ៊ីចឹងយល់ព្រម ប៉ុន្តែយើងរួមគ្នាធ្វើការងារទាំងអស់គ្នា។ អានេះបញ្ហាមានប៉ុណ្ណឹង។ ដូច្នោះគាត់ធ្វើលេខាបក្សតាំងពីហ្នឹងមក។ បាទ ដូច្នោះគ្មានបញ្ហាអីទេ។ ឯម្យ៉ាងទៀត មួយទៀត ដែលខ្ញុំភ្លេច កាលណោះក្រុមប្រជាជន កាលណោះ--"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:២២:២៦]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណ។ នៅក្នុងកិច្ចសម្ភាសន៍នេះ ខ្ញុំគ្រាន់តែគូសបញ្ជាក់បន្តិច គឺនៅក្នុងពេលដែលលោក នួន ជា ពិភាក្សាជាមួយលោក ប៉ុល ពត។ លោក នួន ជា -- ក៏លោក ប៉ុល ពត បានស្នើថាគាត់ទទួលតួនាទីជាលេខាបក្សនេះ ក៏ប៉ុន្តែនៅក្នុងការងាររវាងពួកគាត់ គឺគាត់ -- លោក ប៉ុល ពត ស្នើថាលោក នួន ជា និងលោក ប៉ុល ពត ធ្វើការជាមួយគ្នានៅក្នុងការបំពេញការងារនៅក្នុងបក្សនេះ។

បាទ ជាបន្តសូមមេត្តាដាក់ឃ្លីបវីដេអូលេខ២ សូមខាង អាយ.វី មេត្តាដាក់។ ហើយឃ្លីបវីដេអូលេខ២ នេះគឺចាប់ផ្តើមពីនាទី១១ និង៣៦វិនាទី ដល់នាទីទី១២ និង៤៣វិនាទី។ សូមមេត្តាដាក់។

[១៥:២៣:៣៤]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព “សត្រូវរបស់ប្រជាជន”)*

*“ស៖ (ឮមិនច្បាស់) ឆ្នាំ៦០។ ឆ៖ បាទ។ ស៖ ត្រូវធ្វើអី ក៏ត្រូវពិភាក្សាជាមួយអ៊ីដែរហ្នឹង?*

*ឆ៖ បាទ។ ស៖ អ៊ីចឹងបានន័យថា គាត់នៅគោរពពាក្យសន្យាគាត់? ឆ៖ ទេ គាត់នៅ គាត់មានការធម្មតាការអី -- ចុះវាមានអ៊ីចេះ ពេលណាមិនហៅ ពេលណាមិនមែនប្រជុំទេ គេហៅថា ជួបគ្នាផ្លាស់ប្ដូរមតិគ្នា។ អានេះមិនមែនជាប្រភេទប្រជុំទេ។ បើប្រជុំវាផ្សេង ទៅអង្គុយអីស្រួលបួល។ អានេះវាអត់ ជួបគ្នា មកមិត្ត ខ្ញុំមានបញ្ហាមួយចង់ពិភាក្សា មក។ អានេះគេហៅថា ពិគ្រោះពិភាក្សា ១គ្នាសួរមតិគ្នាខាងក្រៅប្រជុំ។ ដូច្នោះ វាអ៊ីចឹង វារហ័ស ទាក់ទងអ៊ីចឹងណា។ មានការអីទាក់ទងគ្នាភ្លាម។ ដូចខ្ញុំថា មិនបាច់ប្រជុំក៏បានដែរ មក គេហៅថា ផ្លាស់ប្ដូរមតិគ្នា។ ពាក្យថា ប្រើកាលណោះ ផ្លាស់ប្ដូរមតិគ្នា។ អានេះ ត្រូវធ្វើញឹកញាប់ដែរ ពីព្រោះមានការអីមិន១ មិនចេះតែហៅប្រជុំទេ ពីព្រោះវាគ្មានពេលប្រជុំផង។ បន្តិចរឿងនេះ បន្តិចរឿងនោះ ដូច្នោះមាន១រឿងអីផ្លាស់ប្ដូរគ្នា។ អាហ្នឹងវាអ៊ីចឹង។”*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:២៤:៤៦]

**លោក ពេជ អង្គ៖**

បាទ នៅក្នុងឈុតវីដេអូនេះ នៅពេលដែលលោក ប៉ុល ពត បាននិយាយនឹងត្រូវធ្វើការរួមគ្នាជាមួយលោក នួន ជា។ បន្ទាប់ពីពេលនោះមក គឺការធ្វើការភាគច្រើនគឺ ធ្វើឡើងតាមរយៈការផ្លាស់ប្ដូរមតិគ្នា ក្រៅពីការប្រជុំការផ្លាស់ប្ដូរមតិគ្នា លក្ខណៈជាក្រៅផ្លូវការ ជាវិធីមួយនៅក្នុងការផ្លាស់ប្ដូរមតិ -- អ៊ំ! ការធ្វើការជាមួយគ្នារវាងលោក នួន ជា និងលោក ប៉ុល ពត។

ហើយខ្ញុំសូមអនុញ្ញាតផងដែរ ឲ្យបញ្ចាំង--

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអធ្យាស្រ័យលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអធ្យាស្រ័យ ដែលខ្ញុំកាត់នៅត្រង់នេះ។ ខ្ញុំមិនជំទាស់ក្នុង -- ចំពោះការបញ្ចាំងខ្សែវីដេអូនោះ

ទេ ក៏ប៉ុន្តែខ្ញុំជំទាស់ចំពោះការកំណត់ប្រភេទ នៃសម្ភារៈឯកសារនេះដោយមេធាវី។ ហើយដែលក្នុងនេះវាមិនមែនជាសេចក្តីសន្និដ្ឋានបញ្ចប់ ឬសេចក្តីសន្និដ្ឋានណាមួយនោះទេ គឺមេធាវីមិនគួរធ្វើសេចក្តីសន្និដ្ឋាននោះទេ គឺគាត់អាចបញ្ចាំងខ្សែវីដេអូបាន។ ប៉ុន្តែគាត់មិនត្រូវធ្វើការកំណត់ថាវាជា ហើយលើកជាការសន្និដ្ឋាននៅទីនោះឡើយ។

[១៥:២៦:២១]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណចំពោះការលើកជាយោបល់។ ខ្ញុំនឹងជៀសវាងតទៅទៀតនេះ ធ្វើការអធិប្បាយបែបមានលក្ខណៈជាសន្និដ្ឋាន ដោយគ្រាន់តែលើកពីចំណុច ដែលមិនចូលជាលក្ខណៈសន្និដ្ឋាន។

ជាបន្ត សូមបញ្ចាំងឃ្លីប វីដេអូទី៤ ដែលចាប់ផ្តើមអំពីនាទី ទី១៤ និង២៤វិនាទី ដល់នាទី ទី១៥ និង៣៥វិនាទី ដែលនាទីនេះ និយាយអំពីការទិតៀន និងការស្វ័យទិទៀន។ សូមអញ្ជើញបញ្ចាំង។

[១៥:២៧:២២]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ស៖ រវាងអ៊ំ ហើយនិង ប៉ុល ពត មានការស្វ័យទិតៀនគ្នាយ៉ាងណាបាទ? សូមអ៊ំជួយលើកពីរឿង ប៉ុល ពត ស្វ័យទិតៀនអ៊ំ ហើយអ៊ំស្វ័យទិតៀន ប៉ុល ពត វិញបាទ។ ឆ៖ តាមខ្ញុំចាំគឺ ប៉ុល ពត ហ្នឹងទិតៀន ខ្ញុំលើបញ្ហាមាគ៌ានយោបាយរណសិរ្ស ជាមួយស្រទាប់លើ មិនសូវហ្មត់ចត់ គឺថាមិនសូវល្អិតណ៎ា គឺខ្ញុំច្រើនតែមិនសូវអនុវត្តនូវ អ៎! មិនសូវការនិយាយស្តីអីជាលក្ខណៈរណសិរ្សនែ៎ គឺថាមិនសូវទន់ភ្លន់។ អាហ្នឹងក៏មានអ៊ីចឹង។ ឯខ្ញុំទិតៀន ប៉ុល ពត វិញរឿង មួយ រឿងសុខភាព។ ពីរ ទៀតនោះ ខ្ញុំភ្លេចហើយអាទ៎ុង វាច្រើនពេក។ អ្ហ៎ មួយទៀត រឿងគាត់ដូចរហ័សទុកចិត្តគេ រហ័សទុកចិត្តអ្នកដទៃណាស់។ អាហ្នឹងតាមខ្ញុំចាំ ប៉ុន្តែក្រៅពីហ្នឹងអារឿងកំប៉ិកកំប៉ុក ជួនណាការរស់នៅប្រចាំថ្ងៃអីក៏មានដែរ"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:២៨:៣៥]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណ។ បញ្ហាទិតៀននេះក៏មាននិយាយផងដែរ នៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីបញ្ចាំង -- ឲ្យជំនួយការរបស់ខ្ញុំបាទ បញ្ចាំងឯកសារមួយដែលស្តីពីលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា លេខ IS9.1 ត្រង់ចំណុច៧ នៃលក្ខន្តិកៈ

នេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១៥:២៩:១១]

**លោក ពេជ អង្គ៖**

ហើយខ្ញុំសូមអានតែម្តង។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា "ចំណុច៧ បក្សកុម្មុយនីស្តកម្ពុជាយកការទិតៀន និងស្វ័យទិតៀន ជាមធ្យោបាយប្រចាំថ្ងៃ ដើម្បីតស៊ូកសាងផ្ទៃក្នុងបក្សក្នុងការកម្ចាត់ និងកែប្រែគុណវិបត្តិ និងការភ័ន្តច្រឡំផ្សេងៗ ដែលមាននៅក្នុងបក្ស ហើយនិងជំរុញពង្រីកគុណសម្បត្តិដែលមាននៅក្នុងបក្សឲ្យចម្រើន និងជឿនលឿន មិនឈប់ឈរ"។

បាទ ជាបន្តទៅទៀតនេះ ខ្ញុំសូមអនុញ្ញាតអានចំណុចទី៧ នៃជំពូកទី២ របស់លក្ខន្តិកៈនេះ ដោយខ្ញុំសូមអានដូចតទៅ៖

"ចំណុចទី៧ ជំហរបដិវត្តន៍រឹងប៉ឹងខាងការធ្វើ និងត្រួតពិនិត្យប្រវត្តិរូប និងជីវទស្សនៈបដិវត្តន៍ត្រូវមានគោលជំហរបដិវត្តន៍ត្រឹមត្រូវ និងរឹងប៉ឹង ដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការធ្វើការត្រួតពិនិត្យ និងកសាងប្រវត្តិរូបបដិវត្តន៍ ជីវទស្សនៈបដិវត្តន៍របស់ខ្លួនជាបន្តបន្ទាប់។ ត្រូវស្មោះត្រង់ក្នុងការត្រួតពិនិត្យប្រវត្តិរូប និងជីវទស្សនៈបដិវត្តន៍របស់ខ្លួន ហើយនៅក្នុងការកែប្រែគុណវិបត្តិតូចធំរបស់ខ្លួនដាច់ខាត ហើយនិងជំរុញការកសាង ពង្រឹងពង្រីក គុណសម្បត្តិរបស់ខ្លួន ឲ្យរីកចម្រើនឆាប់រហ័សជាបន្តបន្ទាប់"។ នេះ អម្បាញ់មិញ គឺនិយាយអំពីការស្វ័យតិទៀន តែក្រៅពីស្វ័យតិទៀន ក៏មានការធ្វើប្រវត្តិរូប ហើយនិងធ្វើជីវទស្សនៈបដិវត្តន៍ផងដែរ។

បាទ ខ្ញុំមិនបានផ្តល់លេខ ERN ទេ តែដោយខ្ញុំបានជម្រាបអំពីចំណុចនៅក្នុងលក្ខន្តិកៈនេះហើយដូច្នេះ វាមិនចោទជាបញ្ហាប៉ុន្មានទេនៅក្នុងការស្វែងរក។

ជាបន្ត សូមអនុញ្ញាតលោកប្រធាន បញ្ចាំងវីដេអូឃ្លីប នៃឯកសារដដែល ដែលជាការសម្ភាសជាមួយលោក នួន ជា គឺលេខ -- ឃ្លីបលេខ5A ដែលមាននាទីពី ១៧នាទី និង១៦វិនាទី ដល់១៧នាទី ៤៩វិនាទី។ សូមមន្ត្រីខាងសោតទស្សន៍មេត្តាបញ្ចាំង សូមអរគុណ។

[១៥:៣២:០០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*“សៈ ធ្លាប់មានការពិភាក្សាណាមួយ ដ៏តឹងរ៉ឹង នឹងគ្នាមានទេបាទ ពេលដែលគ្រប់គ្រងអំណាចដល់ ៧៥-៧៩ នោះបាទ? ឆៈ ដូចគ្មានទេ។ គ្មានទេ។ មិនមានទេ ៧៥-៧៩។ មិនមានបញ្ហាអីជាមួយគ្នាទេ អត់ទេ”។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:៣២:២៨]

បាទ សូមអរគុណ ឈុតវីដេអូនេះ និយាយអំពីថាតើនៅពេលដែលធ្វើការជាមួយគ្នា នៅឆ្នាំ៧៥ រហូតដល់ ៧៩ ហ្នឹង រវាងលោក នួន ជា និង លោក ប៉ុល ពត តើសភាពនៅក្នុងការពិភាគ្នាហ្នឹង មានលក្ខណ:យ៉ាងដូចម្ដេច? បាទ ជាបន្ត សូមមន្ត្រីសោតទស្សន៍បញ្ចាំងឯកសារលេខ5C។ សូមអរគុណ។

[១៥:៣៣:១៥]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*“រំដោះហើយណ៎ះ ឃើញបញ្ហានេះទេ ឃើញខ្លះតែមិនច្បាស់ បញ្ហាចារកម្មនេះ។ ប៉ុន្តែយើងឃើញភេទមិនតិចមិត្ត -- ភេទមិនល្អ នៅក្នុងជួរកម្មាភិបាលយើង។ ភេទអី? អំណាច ឧកញ៉ា អាជ្ញា ស្រី ស្រា។ ស្រា ពិតមែនគ្មានលក់ គ្មានចាយលុយ ដុល្លារស្រា។ អ៊ីចឹងយើងមិនខ្វះអី លុយកាក់ស្រី ស្រា។ ដូច្នោះ នេះហើយផ្ទៃក្នុងបក្ស បានពិភាក្សាគ្នាជាមួយ ប៉ុល ពត ថា បក្សយើងខ្លីណាស់ បក្សយើងនៅខ្លី ទើប--”។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:៣៣:៥៨]

បាទ សូមអរគុណ ហើយឃ្លីបបន្តទៀត ក៏និយាយផងដែរ អំពីថាតើបញ្ហាអ្វីខ្លះដែលលោក នួន ជា ហើយនិង លោក ប៉ុល ពត ធ្លាប់ពិភាក្សាគ្នាកន្លងមក ហើយឃ្លីបនេះ គឺជាឃ្លីបទី៦ -- អ៎ សូមទោស បាទ ឃ្លីបទី៦ ដែលមាននាទីពី នាទី២៣ និងវិនាទី ទី៣៤ ដល់នាទី២៤ វិនាទី៣៨។ សូមមន្ត្រីសោតទស្សន៍ មេត្តាដាក់បញ្ចាំង។

[១៥:៣៤:៤១]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*“សៈ គឺថាប្រជុំជាមួយ ប៉ុល ពត ត្រូវកម្ចាត់ទាំងប៉ុន្មាននេះ ចង់និយាយថាម៉េច កម្ចាត់នេះ គឺបានន័យថា? ឆៈ កម្ចាត់ធាតុ។ កម្ចាត់ចរិតដែលប្រើអំណាច អាជ្ញា កសាងបក្សណ៎ា គឺថាកុំប្រើអាជ្ញា*

*កុំប្រើអំណាច។ កុំប្រើអំណាច កុំប្រើអាជ្ញា ហើយកុំខូចកាចនឹងស្រីញី កុំវក់វីនឹងស្រា កុំលុយកាក់។ លុយកាក់នេះខ្ញុំចង់និយាយសម្ភារៈណ៎ា បើសម្ភារៈវាគ្របដណ្តប់ហើយ វាទៅបុគ្គលនិយមហើយ។ ដូច្នេះជារួមកសាង ផ្ទៃក្នុងបក្ស គឺកម្ចាត់ធាតុបុគ្គលនិយមសិន។ កម្ចាត់ធាតុណ៎ា! មិនកម្ចាត់មនុស្សទេណ៎ា! កម្ចាត់ធាតុបុគ្គលនិយម ធាតុអត្តនោម័តិ ធាតុអត្តានិយម ខ្លួនឯងគឺត្រូវ ស្អីក៏ខ្លួនឯងត្រូវ ស្អីក៏ខ្លួនពូកែ ស្អីក៏ខ្លួនមិនខុស។ អានេះខ្ចស់ណាស់ ធំណាស់។ ផលប្រយោជន៍ គឺផលប្រយោជន៍បុគ្គល មិនមែនគិតផលប្រយោជន៍រួមឯណា។ អានេះជាធំ"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

បាទជាបន្តសូមអនុញ្ញាតបញ្ចាំងផងដែរនូវឈុតវីដេអូបន្ទាប់ គឺឈុតវីដេអូ 5B ដែលមាននាទីពី នាទី ១៨:០០ ដល់ នាទី ១៨:៥៦។ សូមមន្ត្រីសោតទស្សន៍មេត្តាបញ្ចាំង។

[១៥:៣៦:១៦]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ស៖ ចំពោះអ៊ំមានទស្សនៈផ្សេង បាទ ខុសពីអ្នកផ្សេងបាទ។ ឆ៖ ហេតុអីបាទ? ស៖ អ៊ំមានទស្សនៈ គាត់ថា ប៉ុល ពត នៅតែគាំទ្រ ប៉ុល ពត ដដែល។ ឆ៖ ពីព្រោះខ្ញុំឃើញ ប៉ុល ពត គាត់ស្រឡាញ់ជាតិ គាត់សម្លាប់ពួកក្បត់តើ! គាត់មានសម្លាប់ប្រជាជនឯណាគាត់។ គាត់សម្លាប់ប្រជាជនអាណាសម្លាប់? ពួកអាក្បត់វាសម្លាប់។ ស៖ ចំពោះអ៊ំ អ៊ំ -- គេថា ប៉ុល ពត ជាឃាតក បើសិនចំពោះអ៊ំ អ៊ំ ទស្សនៈគេហ្នឹង ដែលគេថា ប៉ុល ពត ជាឃាតកយ៉ាងណា ទស្សនៈអ៊ំ? ឆ៖ ខ្ញុំថាមិនមែនថាឃាតក។ ឃាតកគឺសម្លាប់ដែលមិនមានទោសមានពៃរ៍អី សម្លាប់ដោយឥតហេតុផល។ អាហ្នឹងឃាតកហើយ។ ស៖ សូមអ៊ំបញ្ជាក់ផងថា ប៉ុល ពត បាទ គាត់ --។ ឆ៖ អ្ហែ៎ ប៉ុល ពត គាត់មិនមែនជាឃាតកទេ។ គាត់សម្លាប់ ដោះស្រាយមនុស្សដែលក្បត់ជាតិ ក្បត់ប្រជាជន លក់ដីឱ្យបរទេស"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:៣៧:១៧]

បាទ សូមអរគុណ ហើយសម្រាប់ឈុតវីដេអូ ចុងក្រោយទាក់ទងទៅនឹងបទសម្ភាសន៍ជាមួយលោក នួន ជា នេះគឺឈុតវីដេអូលេខ 7។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក អាកទួរ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។ ក្នុងដំណាក់កាលនេះ គឺថាការបញ្ចាំងវីដេអូនេះ គឺថាវា -- ខ្ញុំមិនយល់ពីទំនាក់ទំនងរវាងវីដេអូទាំងអស់នេះ ហើយនិងរចនាសម្ព័ន្ធរដ្ឋបាល ហើយនិងប្រព័ន្ធទំនាក់ទំនងទេលោកប្រធាន។ ដូចខ្ញុំមិនយល់។

**លោក ពេជ អង្គ៖**

បាទ ឈុតវីដេអូទាំងនេះគឺជាបទសម្ភាសន៍ ដែលនិយាយអំពីប្រព័ន្ធនៃព័ត៌មាន ដូចខ្ញុំបានជម្រាបរួចហើយ ថាតើរវាងលោក នួន ជា និងលោក ប៉ុល ពត ទាំងពីរនាក់ហ្នឹង ចែករំលែកព័ត៌មានគ្នាយ៉ាងណា ហើយធ្វើការពិភាក្សាជាមួយគ្នាយ៉ាងណា? ហើយលោក នួន ជា យល់យ៉ាងណាអំពីអ្វីដែលលោក ប៉ុល ពត និយាយ និងធ្វើ?

ដូច្នេះបញ្ហាទាំងអស់នេះ គឺជាបញ្ហាទំនាក់ទំនងព័ត៌មាន។ ដូច្នេះ ស្ថិតនៅក្នុងក្របខ័ណ្ឌនៃសវនាការដាក់ឯកសារនេះ។ សូមអរគុណ។

[១៥:៣៨:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្ត!

**លោក ពេជ អង្គ៖**

បាទ ឈុតចុងក្រោយនៃបទសម្ភាសន៍នេះ គឺឈុតទី៧ ដែលពាក់ព័ន្ធទៅនឹងបញ្ហាចម្លើយសារភាព ហើយនិង ស-២១ ហើយដែលមាននាទីពី ២៦ និង៤០វិនាទី ដល់នាទីទី ២៧ និង៣០វិនាទី។ អ៊ីចឹងសូមមន្ត្រីសោតទស្សន៍បញ្ចាំង។

[១៥:៣៩:៣៨]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ស៖ អ៊ំមានប្រសាសន៍ពីមុនថា អ៊ំតែងតែអានរបាយការណ៍សេចក្តីសារភាពហ្នឹងបាទ របស់ ស-២១ ដើម្បីយកអាហ្នឹងទៅអប់រំកម្មាភិបាល ដើម្បីកុំឱ្យប្រព្រឹត្តតាមហ្នឹងបាទ។ អ៊ំសូមបញ្ជាក់បន្តិចតើៗអ៊ំ គ្រាន់តែបញ្ជាក់ថា តើអ៊ំបានបានអានរបាយការណ៍ហ្នឹងយ៉ាងម៉េច? ហើយតើគេអប់រំកម្មា-ភិបាលថ្នាក់ក្រោមយ៉ាងណាបាទ? ឆ៖ របាយការណ៍ហ្នឹង គ្រាន់ដើម្បី -- ខ្ញុំមិនដែលបានមើលទាំងអស់ទេ ពីព្រោះវាច្រើនពេក ហើយមិនមែនជាភារកិច្ចរបស់ខ្ញុំមើលណា។ តែការអប់រំគ្រាន់តែយកស្មៀតគេ*

*ឧបាយកលវាយ៉ាងម៉េចៗណា យកទៅអប់រំឱ្យដឹងទេ។ ឧបមាថាឧបាយកលស្អីដែលជាគ្រោះថ្នាក់ដល់យើង គឺបញ្ហាស្រី"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:៤០:៣៣]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណ។ ហើយជាបន្តនេះ ខ្ញុំសូមចូលទៅដល់បទសម្ភាសន៍មួយទៀត ដែលធ្វើឡើងដោយបុគ្គលម្នាក់ឈ្មោះ រ៉ូសាន សេនាតា ហើយវីដេអូនេះមានលេខ E109/2.3R ខ្ញុំសូមអានម្តងទៀត E109/2.3R ហើយដែលមានចំណងជើងជាភាសាអង់គ្លេសថា "*ស៊ើវ៉ាយ អ៊ីន ដឺ ហាត អូហ្វ ដឺ ខ្មែររូស មេដណេស*" គឺការបន្តរស់នៅក្នុងបេះដូងនៃភាពលីលារបស់ខ្មែរក្រហម"។ ហើយ -- បាទ សូមទោស ការបកប្រែនេះជាការបកប្រែផ្ទាល់មាត់របស់ខ្ញុំទេ។ អ៊ីចឹងសូមលោកប្រធានអនុញ្ញាតដើម្បីបញ្ចាំងឈុតវីដេអូនេះ ដោយចាប់ផ្តើមពីឈុតវីដេអូទី១ ដែលមាននាទី ៦នាទី និង៣៥នាទី ដល់នាទីទី៨ និង២២វិនាទី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៤២:១០]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ឆះ ស្ទើងជីនិតហ្នឹង ដែលជួបៗ ប៉ុល ពត សាឡុត ស ហ្នឹងជាលើកដំបូង។ សាឡុត ស ដែលខ្ញុំធ្លាប់ស្គាល់នៅរៀននៅកំពង់ចាម។ ប៉ុន្តែខ្ញុំអត់ដឹងថា សាឡុត ស ជាលេខាបក្សទេ មេដឹកនាំទេ ឃើញទេ! ទៅទាំងអស់គ្នា គ្មាន -- មិនមែនតែខ្ញុំ ទាំងអស់គ្នា គ្មានអ្នកណាដឹង ស្មានទេ។ ពីព្រោះ សាឡុត ស អត់មានឮឈ្មោះអីខាងពូកែ មានសញ្ញាបត្រអីពូកែឯណា វាអ៊ីចឹងណា។ ដូច្នេះក៏ភ្ញាក់ដែរ--។ សះ ដល់ពេលជួបគាត់ពេលហ្នឹងទៅបានដឹងថា (ឮមិនច្បាស់)។ ឆះ បាទ។ ហើយដឹងជួបដំបូង ប្រជុំដំបូង ស្តាប់គាត់វែកញែកអី គាត់និយាយឃើញថា គាត់មានសមត្ថភាពវែកញែក។ ទាំងអស់គ្នាទទួលស្គាល់ អ៊ីចឹង ជា ហ៊ូ យន់, ហ៊ូ នឹម, ប៉ុក ដឹសកុមារ អីហ្នឹង, ខ្ញុំអីនៅហ្នឹង ក៏ភ្ញាក់ដែរ ពីដើមអត់បានទេ ដឹងថា សាឡុត ស ចេះកូតទ្រ លេងវីយូឡុង លេងអី ហើយអ្នកទាត់បាល់ --។ ហើយទៅមានបញ្ហាអី ពេលទៅប្រជុំម្តងៗ បញ្ញាជនទៅប្រជុំម្តងៗអ៊ីចឹង ចេញមកវិញ ដូចថាវាយល់ វាច្បាស់ យល់សភាពការណ៍*

*វែកញែកសភាពការណ៍អី វិធានការយ៉ាងម៉េចៗហ្នឹង វាដូចថាឃើញថាត្រូវតែទៅតាមហ្នឹង។ សរុបមក អ៊ីចឹង"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:៤៤:០២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

**លោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ម្ដងទៀត គឺថាសម្រង់វីដេអូទាំងអស់នេះ ពុំមានទំនាក់ទំនងជាមួយនឹងកម្មវត្ថុនៃសវនាការយើងនោះទេ ពីព្រោះយើងបានសម្រេចជាលាយលក្ខណ៍អក្សរហើយពីគោលជំហររបស់យើង យើងនៅទីនេះ ថាសសភាតាយើងថ្ងៃនេះ ថាកំពុងតែដាក់ជូននូវភស្តុតាងដែលមិនទាក់ទងទៅនឹងកម្មវត្ថុនៃសវនាការយើងនោះទេ ដែលអង្គជំនុំជម្រះបានសម្រេចហើយ។ អ្វីដែលយើងទើបតែនឹងឮនេះ ពុំមានទំនាក់ទំនងអ្វីទាល់តែសោះទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ហើយនិងប្រព័ន្ធទំនាក់ទំនង។ ឧទាហរណ៍អំមិញនេះយើងឃើញថា ប៉ុល ពត ជាអ្នកទាល់បាល់ពូកែ ជាអ្នកលេងភ្លេង អ្នកអី ហើយចេញពេលខ្លះទៅសម្រាកនៅទីនេះទីនោះអ៊ីចឹង។ ខ្ញុំមើលទៅឃើញថា -- អ៊ីចឹង ខ្ញុំមិនដឹងថាកំពុងតែនិយាយអំពីអ្វីនោះទេ ហើយអង្គជំនុំជម្រះគួរតែបញ្ឈប់ឲ្យផ្អុះបញ្ចាំងវីដេអូ នេះទៀតទេ នេះជាសំណើរបស់ខ្ញុំលោកប្រធាន។

**លោក ពេជ អង្គ៖**

បាទ សូមធ្វើការឆ្លើយតបលោកប្រធានដោយសារថា ជាការពិតមេធាវីការពារក្ដីឲ្យលោក ខៀវ សំផន លើកអំពីហេតុផលថា វាមិនពាក់ព័ន្ធដោយលើកពីបញ្ហាថា សាឡុត ស ជាអ្នកទាល់បាល់ ជាអ្នកកូតទ្រ ក៏ប៉ុន្តែលោកមិនបាននិយាយផងដែរថាទៅដល់ចំណុចថា លោក ខៀវ សំផន និយាយអំពីការប្រជុំ ហើយនិងការចេញពីប្រជុំមកវិញថា តើលោក ខៀវ សំផន យល់យ៉ាងណាអំពីបញ្ហាពាក់ព័ន្ធទៅនឹងការប្រជុំនេះ។ ហើយដែលវាជាការវាយតម្លៃរបស់លោក ខៀវ សំផន ទៅលើៗសមត្ថភាពរបស់លោក ប៉ុល ពត។ ហើយចំណុចនេះហើយដែលជាចំណុចសំខាន់ ដោយវាពាក់ព័ន្ធទៅនឹងបុគ្គលដែលជាជនជាប់ចោទលោក ខៀវ សំផន ហើយពាក់ព័ន្ធទៅនឹងទំនាក់ទំនងការងារ ឬក៏ព័ត៌មាន ដែលមាននៅក្នុងមជ្ឈិមហ្នឹង ហើយដែលអាច -- ដែលពាក់ព័ន្ធពីមុនជាអតីតកាលក្ដី ឬក៏ថាចូលទៅក្នុងពេល

ក្របខ័ណ្ឌនៃអង្គហេតុ -- យុត្តាធិការពេលវេលានៃអង្គសវនាការ។ ដូច្នេះ ចំណុចទាំងអស់នេះពិតជាមានការពាក់ព័ន្ធច្បាស់លាស់ ពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌនៃការបង្ហាញឯកសារនៅក្នុងរចនាសម្ព័ន្ធទំនាក់ទំនងព័ត៌មាននេះ។ បាទ សូមអរគុណ។

[១៥:៤៧:១៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៨:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះគិតឃើញថា ការបង្ហាញនូវឃ្លីបវីដេអូ នេះក៏មានការពាក់ព័ន្ធទៅនឹងកិច្ចដំណើរការខ្លះៗដែរ នៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះមេធាវីអាចបន្តនូវកិច្ចការរបស់ខ្លួនជាបន្តទៀត។

[១៥:៤៩:១៣]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធព័ត៌មាននេះដែរ គឺៗខ្ញុំស្នើសុំបញ្ចាំងឃ្លីបវីដេអូ ទី៥ ដែលចាប់ផ្ដើមពីនាទី១ និង៥វិនាទី បាទ សូមទោស ទី -- ចាប់ផ្ដើមពីនាទីទី៥ និង២៣វិនាទី ដល់នាទីទី៦ និង៤៤វិនាទី។ សូមមន្ត្រីសោតទស្សន៍ សូមបញ្ចាំង។

[១៥:៥០:០០]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ស៖ កាលហ្នឹងដែលលោកអ៊ំខិតស៊ូ រស់នៅក្នុងព្រៃយូរណាស់មកហើយណ៎ា ហើយដល់ឥឡូវហ្នឹងបានវិលមកភ្នំពេញវិញ។ អារម្មណ៍លោកអ៊ំមកភ្នំពេញដំបូងគេ មានអារម្មណ៍យ៉ាងម៉េចដែរ ចង់--? ឆ៖ ឮស្នូរជ័យជម្នះភ្លាមថ្ងៃ១៧ មេសា ៧៥ ហ្នឹង ខ្ញុំសប្បាយមែនទែន ព្រោះថា--, ស៖ អ៊ំនៅឯណាកាលនោះ? ឆ៖ កាលនោះខ្ញុំនៅ គេហៅថា ខាងលិចខដុង្គបន្ទិច គេហៅភូមិដូង។ អាហ្នឹងគឺជាកន្លែងបញ្ជា-ការរបស់ខ្មែរក្រហមសម្រាប់វ៉ៃផ្ដាច់ភ្នំពេញ។ គេហៅខ្ញុំមក ប្រហែលចុងខែមីនា ហៅមក ដើម្បីខ្ញុំដឹង ខ្ញុំតាមដានសមរភូមិហ្នឹងបណ្ដើរៗណ៎ា។ ហ្នឹងអ៊ីចឹង។ ដល់ឈ្នះភ្លាម ខ្ញុំសប្បាយមែនទែន ប៉ុន្តែស្រាប់ដល់មានយុទ្ធជនមកពីភ្នំពេញ គេនិយាយគ្នាឆ្ការដែរដើងតែគ្នាគេ ពីរឿងប្រជាជនត្រូវដេកចេញពីភ្នំពេញ ហើយអ៊ូអែ ដើរពេញតែផ្លូវទៅ ចេញពីភ្នំពេញទៅណ៎ា។ ខ្ញុំក៏ភ្ញាក់ផ្អើល ដល់សួររកយល់ទៅ*

*បានដឹងថា អ្នំ មានការណែនាំ ជម្លៀសប្រជាជនចេញពីភ្នំពេញ"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:៥១:២៩]

**លោក ពេជ អង្គុះ**

បាទ ជាបន្ត សូមបញ្ចាំងឃ្លីប ទី៣ ដែលមាននាទីទី៥៥ -- ចាប់ផ្ដើមពីនាទីទី៥៥ និង ៤៨វិនាទី ដល់នាទីទី៥៨ និង០៤វិនាទី។ សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត!

[១៥:៥២:០៤]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ស៖ បើសិនជា -- ខ្ញុំចង់សួរថា បើអ៊ំត្រូវសាងជីវិតម្ដងទៀតណា៎ តើលោកអ៊ំជ្រើសរើសដើរធ្វើការក្នុងការតស៊ូរបបខ្មែរក្រហមទៀតដែរឬទេ បើសិនជាគេឲ្យអ៊ំសាដើមជីវិតលោកអ៊ំម្ដងទៀតណា៎? ឆ៖ ទី១ ខ្ញុំសូមជម្រាបថា ការសួរយ៉ាងនេះវាពិបាកឆ្លើយបន្តិចដែរ ពីព្រោះប្រវត្តិសាស្ត្រវាមិនអាចសាដើមឡើងវិញបានទេ។ អ្វីៗវាជាប្រវត្តិសាស្ត្រ វាហួសកន្លងទៅហើយ សាដើមមកវិញអត់បានទេ។ ប៉ុន្តែឥឡូវតើខ្ញុំគិតសរុបពិសោធន៍របស់ខ្ញុំយ៉ាងម៉េច? ខ្ញុំបានជម្រាបហើយថា ខ្ញុំធ្វើអ្វីៗគឺដោយសុទ្ធចិត្ត ហើយមួយជីវិតនេះ ខ្ញុំបានខិតខំអស់ពីចិត្តពីថ្លើមរបស់ខ្ញុំ ខ្ញុំបានពិនិត្យ។ និយាយអ៊ីចឹង តើខ្ញុំសោកស្ដាយទេ មានការសោកស្ដាយទេអំពីព្រឹត្តិការណ៍ ដែលនាំឲ្យមានស្លាប់បាត់បង់ជីវិតបងប្អូនរួមជាតិយើង ច្រើនសន្ធឹកសន្ធាប់យ៉ាងនេះ? ខ្ញុំបានជម្រាបហើយ នៅក្នុងសំបុត្រចំហទី១ របស់ខ្ញុំ។ ខ្ញុំអត់ដឹងរឿងអីមែន។ ប៉ុន្តែខ្ញុំអាច គេអាចចោទប្រកាន់ខ្ញុំបាន ថាខ្ញុំ -- ពីរឿងដែលជម្លៀសប្រជាជន រឿងចាត់តាំងសហករណ៍ អីៗហ្នឹង ខ្ញុំមិនបានតវ៉ាម៉ឺងម៉ាត់ ខ្ញុំគ្រាន់តែលើក។ ដូច្នេះ តើអាហ្នឹង ខ្ញុំត្រូវទទួលទោសកម្រិតណា?"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:៥៤:២៧]

**លោក ពេជ អង្គុះ**

បាទ អ្វីដែលបាននិយាយនៅក្នុងនេះគឺពាក់ព័ន្ធទៅនឹងបញ្ហាការជម្លៀស ការតាំង -- ការចាត់តាំងសហករណ៍ និងបញ្ហាតវ៉ា។ នៅពាក់ព័ន្ធទៅនឹងបញ្ហាចាត់តាំងសហករណ៍នេះ គឺយើងអាចឃើញមាន

នៅក្នុងឯកសារផ្សេងទៀត ដែលក្នុងនេះខ្ញុំសូមអនុញ្ញាតលោកប្រធាន អានឯកសាររបស់លោក ខៀវ សំផន ដែលជានិក្ខេបបទរបស់គាត់ ដែលមានលេខ E3/123 នៅក្នុងនោះ ERN ជាភាសាខ្មែរ គឺមានលេខ 00767387, ជាភាសាអង់គ្លេស 00750604, និងជាភាសាបារាំង 00236575។ ពេលនេះ ខ្ញុំឃើញមានការជំទាស់សូម--។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

[១៥:៥៥:៣៣]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានអារម្មណ៍ថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីច្រឡំសវនាការហើយ គឺថាច្រឡំការជជែកតវ៉ាចុងក្រោយ ហើយនិងដំណាក់កាលនេះ ចង់អានសម្រង់មួយដែលមិនពាក់ព័ន្ធនឹងវិសាលនៃសវនាការយើងនេះ។ វាមិនត្រូវទាល់តែសោះ។ ឥឡូវនេះ គាត់និយាយអំពីសហករណ៍ និយាយពីអ្វីផ្សេងទៅវិញនោះ គឺថាយើងកំពុងតែខាតពេលវេលាហើយលោកប្រធាន។ ព្រោះថា ខ្ញុំមិនឃើញថា មានបញ្ហាសហករណ៍នេះ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ហើយនិងប្រព័ន្ធទំនាក់ទំនងរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ លោកប្រធាន។

**លោក ពេជ អង្គ៖**

បាទ សូមឆ្លើយតប។ រឿងបញ្ហាសហករណ៍នេះ គឺជាផ្នែកមួយនៃរចនាសម្ព័ន្ធ ដែលមានតាំងពីមជ្ឈិម ហើយសហករណ៍នេះ គឺជារចនាសម្ព័ន្ធមួយដែលមាននៅថ្នាក់មូលដ្ឋាន ហើយសហករណ៍នេះមាននៅក្នុង -- យើងត្រូវពិចារណាថា តើសហករណ៍មាននៅក្នុងពេល៣ឆ្នាំនោះ ពិតប្រាកដឬទេ? ហើយសហករណ៍នេះ គំនិតចេញមកពីណា? ដូច្នេះ វាពាក់ព័ន្ធទៅនឹងរឿងបញ្ហា ដែលជាទំនាក់ទំនងព័ត៌មានផង ហើយក៏ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធផងដែរ។ សូមលោកប្រធានអនុញ្ញាត។

[១៥:៥៧:១៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៨:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញលោកមេធាវី!

**លោក ពេជ អង្គ៖**

បាទ ខ្ញុំមានការសោកស្ដាយដែលមានការជំទាស់ជាញឹកញយយ៉ាងនេះ ដែលធ្វើខ្ញុំឲ្យខាតពេល ប៉ុន្តែវានាំឲ្យមានការច្បាស់លាស់ផងដែរ។ ឃ្លាដែលខ្ញុំអានជូនអម្បាញ់មិញ -- សូមទោស លេខ ERN ដែលខ្ញុំបានអានជូនអម្បាញ់មិញ គឺដែលមានខ្លឹមសារដូចតទៅ "ក) ការទប់ស្កាត់កុំឲ្យតម្រូវដែលជំរុញដោយរបាយចំណូលក្នុងស្រុក ផ្ដោតលើផលិតផលនាំចូល។ ជាដំបូង គឺត្រូវផ្ទេរទីតាំង ដំណើរការរបស់អ្នកពន្លឿនល្បឿននៅបរទេស ដោយសារតែមានការនាំចូលទំនិញប្រើប្រាស់ ដែលលុបបំបាត់ឥទ្ធិពលកើនឡើងនៃវិយោគបរទេស។ ពេលនោះ គេអាចតម្រង់ទិសតម្រូវការដែលជំរុញដោយរបាយចំណូលថ្មីក្នុងឱកាសវិយោគស្វយ័តបរទេស ទៅកាន់ផលិតកម្មក្នុងស្រុក ដោយកម្រិតការនាំចូល។ ដូច្នេះ តម្រូវការក្នុងស្រុកត្រូវបំពេញដោយឧស្សាហកម្មខ្នាតតូច និងសប្បិកម្មជាតិ--"។ ជាបន្ត ខ្ញុំសូមបន្ត "តម្រូវការក្នុងស្រុក អាចត្រូវបំពេញដោយមិនត្រូវការទំហំវិយោគធំពេក ដោយរៀបចំជាសហករណ៍ផលិតកម្ម និងផ្គត់ផ្គង់ សំដៅបង្កើនផលិតភាពការងារ"។

[១៥:៥៩:៤៨]

នេះ គឺជាចំណុចមួយពាក់ព័ន្ធនឹងសហករណ៍ ហើយចំណុចបន្ទាប់ គឺនៅក្នុងនិក្ខេបបទរបស់លោក ខៀវ សំផន ដដែល និយាយអំពីបញ្ហាសហករណ៍ហ្នឹងដូចគ្នា។ គឺខ្មែរ ERN មានលេខ 00767441, ERN ជាភាសាអង់គ្លេស 00750636, ជាភាសាបារាំង 00236643 ហើយនៅក្នុងនោះមានឃ្លាមួយដែលនិយាយថា "យើងបានឃើញរួចមកហើយថា ភាពតូចចង្អៀតនៃទីផ្សារសម្រាប់ប្រទេសតូចមួយដូចជាប្រទេសកម្ពុជា អាចបង្អាក់មិនឲ្យមានរាល់កិច្ចខិតខំប្រឹងប្រែងដ៏ហ្មត់ចត់សម្រាប់ឧស្សាហូបនីយកម្ម។ ដោយសារហេតុនេះ រដ្ឋាភិបាលត្រូវខិតខំប្រមែប្រមូលប្រជាកសិករសម្រាប់ការជួយគ្នាទៅវិញទៅមក ខិតខំចាត់ចែងរៀបចំឲ្យមានសហករណ៍រៀបចំស្បៀង និងគ្រឿងឧបភោគបរិភោគ ហើយដែល -- ហើយនិងខិតខំអនុវត្តនយោបាយឥណទានកសិកម្មដែលមានការរៀបចំជាផែនការ" បញ្ចប់សម្រង់។ ហើយនៅក្នុងនេះ គឺដើម្បីបញ្ជាក់ជូនលោកមេធាវីការពារក្ដី គឺចំណុចនេះក៏និយាយអំពីបញ្ហាសហករណ៍ដូចគ្នាដែរ។

[១៦:០១:៤៨]

ហើយសម្រង់ចុងក្រោយនៃសៀវភៅនេះ គឺនៅក្នុងបុព្វកថារបស់និក្ខេបបទនេះ ដែលមាន ERN ជាភាសាខ្មែរ 00767296, ភាសាអង់គ្លេស 00750555, ភាសាបារាំង 00236473។ នៅក្នុងនេះ គឺ

ជាបុព្វកថាដែលបញ្ជាក់អំពីគោលដៅនៃការសរសេរនិក្ខេបបទនេះ។ អ៊ីចឹងឃ្លាដែល -- ខ្ញុំស្រង់ឃ្លាដូចតទៅ--

**លោក គង់ សំអុន៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

ផ្អាកសិនលោកមេធាវី!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

[១៦:០២:៥២]

**លោក គង់ សំអុន៖**

បាទ អរគុណលោកប្រធាន។ ខ្ញុំបាទ សូមឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានពីការប្រើពាក្យអម្បាញ់មិញរបស់លោកមេធាវី សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដែលលោកបានបង្ហាញថានៅក្នុងកថាខណ្ឌមុននេះមាននិយាយអំពីសហករណ៍។ ការពិតមិនមែនៗមាននិយាយតែពាក្យ "សហ-ករណ៍" នោះទេ ហើយក៏មិនបាននិយាយអំពីសហករណ៍ដែរ គឺនិយាយគឺប្រើពាក្យ "សហករណ៍"។ អ៊ីចឹងពាក្យ "សហករណ៍" គឺជាពាក្យមួយនៅក្នុងចង្កោមពាក្យដទៃទៀត នៅក្នុងប្រយោគនោះតែប៉ុណ្ណោះ គឺមិនបានពន្យល់លម្អិតអំពីសហករណ៍ទេ។ បាទ សូមអរគុណ ចំណុចនេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះក៏មិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធលើកឯកសារ ដាក់ឯកសារបង្ហាញឯកសារនៅក្នុងដំណើរការសវនាការនាពេលនេះ លម្អិតអំពីសហករណ៍ដែរ។ ពីព្រោះសហ-ករណ៍ ដែលលើកឡើងនេះគ្រាន់តែជារចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋានមួយប៉ុណ្ណោះ។ អង្គ-ជំនុំជម្រះមិនបានកំណត់នៅក្នុងសំណុំរឿង០០២/០១ មានអំពីអង្គហេតុជាក់លាក់ស្តីអំពីសហករណ៍ត្រាំកក់ ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះទេ។ សូមជ្រាប។

សូមអញ្ជើញបន្ត!

[១៦:០៤:១៤]

**លោក ពេជ អង្គ៖**

បាទ ខ្ញុំអាន សូមអានឃ្លានេះតែម្តង "និក្ខេបបទរបស់ខ្ញុំចែកជាពីរផ្នែក ក្នុងផ្នែកទី១ យើងនឹង

ខិតខំរកឲ្យឃើញពីភាពចាំបាច់សត្យានុម័តនៃឧស្សាហូបនីយកម្ម និងការអភិវឌ្ឍស្វយ័ត ដោយធ្វើការសិក្សាពីរចនាសម្ព័ន្ធសេដ្ឋកិច្ចបច្ចុប្បន្ន ពីយន្តការដែលជាប្រភពនៃរចនាសម្ព័ន្ធនោះ និងពីឥទ្ធពលរបស់យន្តការនេះទៅលើសង្វាក់នៃការអភិវឌ្ឍសេដ្ឋកិច្ចនាពេលក្រោយ។ នៅក្នុងផ្នែកទី២ យើងនឹងសិក្សាអំពីបញ្ហាឧស្សាហូបនីយកម្មផ្ទាល់តែម្តង ដោយព្យាយាមកំណត់ថា តើកំណែទម្រង់រចនាសម្ព័ន្ធមួយនឹងត្រូវអនុវត្តឡើងបែបណា ដើម្បីឲ្យរចនាសម្ព័ន្ធនេះអាចត្រូវបានប្រើជាមូលដ្ឋានរឹងមាំមួយដល់ឧស្សាហកម្ម - - ឧស្សាហូបនីយកម្ម និងកំណត់ថា តើការកែទម្រង់នោះទាមទារនូវលក្ខខណ្ឌអ្វីខ្លះ។ បាទខ្ញុំសូមបញ្ចប់សម្រង់នៃឯកសារនេះ ហើយខ្ញុំសូមអនុញ្ញាតវិលមកវីដេអូរបស់ខ្ញុំវិញ។ ខ្ញុំសូមទោសលោកប្រធាន ខ្ញុំនៅមិនច្រើនប៉ុន្មានទេ តែអាចចំណាយពេលរហូតទៅដល់១០នាទី។ អ៊ីចឹងពេលនេះខ្ញុំមើលទៅឃើញថាវាហួសពេលបន្តិចទៅហើយ សូមលោកប្រធានពិនិត្យ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃស្អែកហ្នឹង ទំនងចំណាយពេលវេលាប៉ុន្មានទៀត?

**លោក ពេជ អង្គ៖**

បាទ លោកប្រធាន ថ្ងៃនេះចំណាយពេលអាចថា ១ម៉ោង ហើយថ្ងៃស្អែកនេះអាចចំណាយពេលយ៉ាងច្រើន១ម៉ោង។ ដូច្នេះមិនគ្រប់ពេលកន្លះថ្ងៃទេ។ ដូច្នេះ មិនលើសពីពេលវេលាដែលផ្តល់ដោយអង្គជំនុំជម្រះទេ។ សូមអរគុណលោកប្រធាន។

[១៦:០៦:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី១៩ ខែតុលា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការដាក់បង្ហាញឯកសារភស្តុតាងបញ្ចប់នូវកិច្ចការ ពេលវេលារបស់ខ្លួន ហើយនឹងផ្តល់ឱកាសជូនទៅក្រុមមេធាវីការពារក្តី ដែលនឹងចាប់ផ្តើមពីក្រុមមេធាវីការពារក្តីលោក នួន ជា ដាក់បង្ហាញឯកសារភស្តុតាង។ សូមភាគី និង

សាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទពីររូប នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងពីររូបមកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*